

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ផែនការសកម្មភាពជាតិ
ស្តីពី
ការទប់ស្កាត់អំពើហិង្សាលើស្ត្រី
២០២៥-២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

ក្រសួងកិច្ចការនារី



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ផែនការសកម្មភាពជាតិ
ស្តីពី
ការទប់ស្កាត់អំពើហិង្សាលើស្ត្រី
ឆ្នាំ២០២៥-២០៣០



បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

ក្រសួងកិច្ចការនារី

បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តផ្តល់អាទិភាពលើការបង្កើនការវិនិយោគ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីនៅគ្រប់វិស័យនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ តាមរយៈការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលក្នុងនោះ **«ស្ត្រីគឺជាស្នូល»** ដើម្បីឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលនឹងប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ តាមរយៈការដាក់ចេញនូវការអនុវត្តច្បាប់ គោលនយោបាយ ផែនការជាតិនានា និងកម្មវិធីសំខាន់ៗ ដើម្បីធានាឱ្យស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ជាពិសេសក្រុមងាយរងគ្រោះឱ្យទទួលបានការការពារផ្លូវច្បាប់និងសេវាពហុវិស័យប្រកបដោយប្រសិទ្ធភាពនិងបរិយាបន្ន។

រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងកិច្ចការនារីជាសេនាធិការ បានដឹកនាំរៀបចំបង្កើត អនុវត្ត និងតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ដែលជាផែនការសកម្មភាពជាតិលើកទី៣ ក្នុងគោលដៅឱ្យគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដៃគូអភិវឌ្ឍ និងវិស័យឯកជន រួមគ្នាអនុវត្តក្នុងការបង្ការទប់ស្កាត់ផ្តល់កិច្ចអន្តរាគមន៍ និងកិច្ចការពារដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ និងក្រុមជនងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពខ្ពស់។ ក្រសួងកិច្ចការនារីបានសម្របសម្រួល និងដឹកនាំធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាពជាតិនេះ ក្នុងគោលបំណងចងក្រងមេរៀនអំពីភាពជោគជ័យនិងបញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ដែលការវាយតម្លៃនេះផ្តោតលើសមិទ្ធផលដែលសម្រេចបានភាពប្រទាក់ក្រឡា សក្តិសិទ្ធិភាព ផលជះ និរន្តរភាព លើសមភាពយេនឌ័រនិងសិទ្ធិមនុស្ស ដែលក្នុងនោះបានផ្តល់នូវអនុសាសន៍ចំនួន២៦ចំណុច សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ ឆ្នាំ២០២៥-២០៣០។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ ត្រូវបានរៀបចំឡើងក្នុងគោលដៅកាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បញ្ចកោណទី១ មុំទី៥ស្តីពីការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្នរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដោយមានការដាក់បញ្ចូលនូវសកម្មភាពគន្លឹះដែលនឹងត្រូវអនុវត្តរួមគ្នាដោយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។

ក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ ឱ្យទទួលបានជោគជ័យ គឺទាមទារឱ្យមានកិច្ចសហការ ការវិភាជធនធាន ការផ្តល់មធ្យោបាយ និងការប្តេជ្ញាចិត្តរួមគ្នាពីគ្រប់ប្រតិបត្តិករទាំងអស់ ដើម្បីប្រែក្លាយផែនការសកម្មភាពជាតិនេះឱ្យទៅជាសកម្មភាពជាក់ស្តែងនៅតាមវិស័យនីមួយៗ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាសូមកោតសរសើរនិងសូមថ្លែងអំណរគុណដល់ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួង ស្ថាប័ន ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ

និងផ្តល់ភាពអង់អាចដល់ស្ត្រី ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា ដែលបានផ្តល់ការគាំទ្រទាំងថវិកានិងបច្ចេកទេស ក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ ឆ្នាំ២០២៥-២០៣០ នេះ និងសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងសាធារណជនគ្រប់មជ្ឈដ្ឋានទាំងអស់ សូមបន្តគាំទ្រនិងរួមគ្នាអនុវត្តផែនការសកម្មភាពជាតិនេះឱ្យទទួលបានប្រសិទ្ធភាពនិងប្រសិទ្ធផល ដើម្បីឆ្លើយតបចំពោះតម្រូវការជនរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់និងក្រុមជនងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាព គ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្ន។

ថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៦

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

មាតិកា

បុព្វកថា i

មាតិកា iii

ពាក្យបំព្រួញ v

១- សារធាន ១

១.១- គោលនយោបាយ ១

១.១.១- ក្របខ័ណ្ឌជាតិ ១

១.១.២- ក្របខ័ណ្ឌអន្តរជាតិ ២

១.២- ស្ថានភាពអំពើហិង្សាលើស្ត្រី ២

១.២.១- អត្ថប្រយោជន៍នៃអំពើហិង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទ ៣

១.២.២- អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ៣

១.២.៣- អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ នៅវ័យក្មេង ៤

១.២.៤- ស្ត្រីដែលកាន់តែប្រឈមនឹងហានិភ័យងាយរងគ្រោះដោយអំពើហិង្សា ៤

១.២.៥- និយាមសង្គមដែលបង្កឱ្យគ្រោះថ្នាក់បណ្តាលឱ្យអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបន្តកើតឡើង និងជាឧបសគ្គរារាំងដល់ការស្វែងរកដំនួយ ៥

១.៣- លទ្ធផលសម្រេចបាន ៥

១.៣.១- ការបង្ការទប់ស្កាត់ ៥

១.៣.២- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ៧

១.៣.៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ ១១

១.៣.៤- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ១២

១.៤- បញ្ហាអាទិភាព ១៣

១.៤.១- ការបង្ការទប់ស្កាត់ ១៣

១.៤.២- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ១៤

១.៤.៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ ១៦

១.៤.៤- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ១៧

២- យុទ្ធសាស្ត្រ ១៧

យុទ្ធសាស្ត្រទី១ : ការបង្ការទប់ស្កាត់ ១៧

យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ១៧

យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ ១៨

យុទ្ធសាស្ត្រទី៤ : ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ១៨

៣- ផែនការសកម្មភាព ១៩

៣.១- វិសាលភាព ១៩

៣.២- តារាងអនុវត្តការងារ ១៩

៤- ការវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ៧៦

៥- គម្រោងចំណាយ ៧៧

៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ៧៧

៦.១- ការតាមដាន ត្រួតពិនិត្យ និងការតាមដានបន្ត ៧៧

៦.២- ការពិនិត្យមើលពាក់កណ្តាលអាណត្តិនិងការវាយតម្លៃចុងក្រោយ ៧៨

៧- សេចក្តីសន្និដ្ឋាន ៧៨

សន្លាឆ្រម ៧៩

គន្ថនិទ្ទេស ៨២

ពាក្យចំរ្ងេញ

កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ		One Stop Service Unit	OSSU
ការតាមដានត្រួតពិនិត្យវាយតម្លៃ និងរៀនសូត្រ		Monitoring, Evaluation and Learning	MEL
ការកេងប្រវ័ញ្ចនិងការរំលោភបំពានលើកុមារតាមប្រព័ន្ធអនឡាញ		OnLine Child Exploitation and Abuse	OCSEA
ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពកម្ពុជា		Cambodia Demographic and Health Survey	CDHS
ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ		Technical and Vocational Education and Training	TVET
ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ		Comprehensive Sexuality Education	CSE
ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមស្រុក		District Office of Social Affairs and Social Welfare	SASW
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	ក.ប	Ministry of Labour and Vocational Training	MLVT
ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	កបទ.សអ	Ministry of Foreign Affairs and International Cooperation	MFA.IC
ក្រសួងកិច្ចការនារី	ក.ក.ន.	Ministry of Women's Affairs	MoWA
ក្រសួងទេសចរណ៍	ក.ទ.ច.	Ministry of Tourism	MoT
ក្រសួងធម្មការនិងសាសនា	ក.ធ.ស.	Ministry of Cults and Religions	MoCAR
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	ក.ប.ទ.	Ministry of Post and Telecommunications	MPTC
ក្រសួងផែនការ	ក.ផ.ក.	Ministry of Planning	MoP
ក្រសួងពាណិជ្ជកម្ម	ក.ព.ណ.	Ministry of Commerce	MoC
ក្រសួងព័ត៌មាន	ក.ព.ម.	Ministry of Information	MoINFO
ក្រសួងមហាផ្ទៃ	ក.ម.ផ.	Ministry of Interior	MoI

ក្រសួងយុត្តិធម៌	ក.យ.	Ministry of Justice	MoJ
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	ក.វ.វ.ស.	Ministry of Culture and Fine Arts	MCFA
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ស.អ.យ.	Ministry of Social Affairs Veterans and Youth Rehabilitation	MoSVY
ក្រសួងសុខាភិបាល	ក.ស.ប.	Ministry of Health	MoH
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ក.ស.ហ.វ.	Ministry of Economy and Finance	MEF
ក្រសួងអប់រំ យុវជន និងកីឡា	អ.យ.ក.	Ministry of Education, Youth and Sport	MoEYS
ក្រសួងអភិវឌ្ឍន៍ជនបទ	ក.អ.ជ	Ministry of Rural Development	MRD
ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	ឧ.វ.ប.ន.	Ministry of Industry, Science, Techology and Innovation	MISTI
ក្រុមការងារបញ្ជោបយេនឌ័រ		Gender Mainstreaming Action Group	GMAG
ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ		GBV Response Groups	GBV-RG
ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ		Technical Working Group on Gender -Gender Based Violence	TWGG-GBV
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ	ក.ជ.ក.	Cambodia National Council for Children	CNCC
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី	ក.ជ.ក.ស.	Cambodian National Council for Women	CNCW
គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	គ.ជ.គ.ម.	National Committee for Disaster Management	NCDM
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស	គ.ជ.ប.ជ.	National Committee for Counter Trafficking	NCCT
គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ	គ.ជ.ស.ស.ខ		

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ	គ.ជ.អ.ប.	National Committee for Sub-National Democratic Development	NCDD
គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់	គ.ក.ន.ក.	Commune Committee for Women and Children	CCWC
គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា	គ.ស.ម.ក.	Cambodia Human Rigths Committee	CHRC
គំរូទប់ស្កាត់អំពើហិង្សាលើស្ត្រីកម្រិតបឋមតាមវិធីសាស្ត្រសាសា «ការចាប់ផ្តើម ការយល់ដឹង ការគាំទ្រ និងសកម្មភាព»		Start, Awareness, Support and Action	SASA
ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ		Law on Prevention of Domestic Violence and Protection of Victims	DV Law
បណ្ឌិត្យសភាកូមិន្នយុត្តិធម៌កម្ពុជា		Royal Academy of Judicial for Cambodia	RAJC
បទដ្ឋានអប្បបរមានៃសេវាសំខាន់ៗ		Minimum Service Standards	MSS
ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល		Health Management Information System	HMIS
ផែនការប្រតិបត្តិប្រចាំឆ្នាំ		Annual Operating Plan	AOP
ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ	ផ.យ.អ.ជ.	National Strategic Development Plan	NSDP
ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី		National Action Plan to Prevent Violence Against Women	NAPVAW
ពង្រឹងជំនាញទំនាក់ទំនង បង្កើនភាពអង់អាចដល់ស្ត្រី ជានាការផ្តល់សេវាកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យបរិយាកាសមានសុវត្ថិភាព ទប់ស្កាត់ការរំលោភបំពានក្មេងជំទង់និងកុមារ និងកែប្រែឥរិយាបថ ជំនឿ និងបទដ្ឋាន		Relationship skills strengthened, Empowerment of women, Services ensured, Poverty reduced, Envionmental made safe, Child and adolescent abuse and Transformed attitudes belief and norms	RESPECT

ភ្នាក់ងារនគរបាលយុត្តិធម៌		Judicial Police Agent	JPA
ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី		United Nation Entity for Gender Equality and the Empowerment of Women	UNWOMEN
មន្ត្រីនគរបាលយុត្តិធម៌		Judicial Police Officer	JPO
របាយការណ៍ប្រចាំឆ្នាំ		Annual Report	AR
រាជរដ្ឋាភិបាលកម្ពុជា		Royal Government of Cambodia	RGC
វិទ្យាស្ថានជាតិស្ថិតិ	វ.ជ.ស.	National Institute of Statistics	NIS
សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ		International Conference on Population and Development	ICPD
សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍		Association of Southeast Asia Nations	ASEAN
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា		Garment Manufacturing Association of Cambodia	GMAC
សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច		UN Declaration on the Rights of Indigenous People	UNDRIP
ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ		Lesbian, Bisexual, Trangender	LBT
ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកមានចម្ងល់អំពីភេទ អត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទ ឬហៅពាក្យរួមអ្នកស្រឡាញ់ភេទដូចគ្នា		Lesbian, Gay, Bisexual, Transgender, Intersex, and Queer or Questioning	LGBTIQ
អង្គការពលកម្មអន្តរជាតិ		International Labor Organization	ILO
អង្គការមិនមែនរដ្ឋាភិបាល		Non-government organisation	NGO
អង្គការសេវាសហគមន៍		Community Service Organisation	CSO
អង្គការសកម្មភាពលើពិការភាពនិងការអភិវឌ្ឍអន្តរជាតិ		Action on Disability and Development	ADD

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ	Convention on the Elimination of All Forms of Discrimination Against Women	CEDAW
អនុសញ្ញាស្តីពីសិទ្ធិកុមារ	Convention on the Rights of the Child	CRC
អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ	UN Convention on the Rights of Persons with Disabilities	CRPD
អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង	Child, Early and Forced Marriages and Unions	CEFMU
អំពើហិង្សាទាក់ទងនឹងយេនឌ័រ	Gender Based Violence	GBV
អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈបច្ចេកវិទ្យា	Technology Facilitated Gender Based Violence	TFGBV
អំពើហិង្សាពីដៃគូស្និទ្ធស្នាល	Intimate Partner Violence	IPV
អំពើហិង្សាលើកុមារ	Violence against Children	VAC
អំពើហិង្សាលើស្ត្រីតាមរយៈបច្ចេកវិទ្យា	Technology Facilitated Violence against Women	TFVAW
អំពើហិង្សាលើស្ត្រីនិងក្មេងស្រី	Violence against Women and Girls	VAWG
អំពើហិង្សាលើស្ត្រី	Violence against Women	VAW

១- សារធារ

១.១- គោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាអាទិភាពនៅក្នុងច្បាប់និងគោលនយោបាយ របស់ខ្លួន និងបានអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីចំនួន៣លើករួចមកហើយ គឺលើកទី១ ឆ្នាំ២០០៩-២០១៣ លើកទី២ ឆ្នាំ២០១៤-២០១៨ និងលើកទី៣ ឆ្នាំ២០១៩-២០២៣។ ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ គឺជាផែនការសកម្មភាពជាតិលើកទី៤ ដែលមានគោលបំណង ពង្រឹងបន្ថែមលើជោគជ័យនិងបទពិសោធដែលទទួលបានពីការអនុវត្តផែនការសកម្មភាពកន្លងមក ក៏ដូចជាឆ្លើយតប ចំពោះបញ្ហាប្រឈមដែលនៅសេសសល់ ដោយមានការចូលរួមគ្រប់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលព្រមទាំង សង្គមស៊ីវិល ក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅកម្ពុជា។

១.១.១- ក្របខ័ណ្ឌជាតិ

រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាច្រើនមានដូចខាងក្រោម ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនិងក្មេងស្រី៖

ក- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ខ- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

គ- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ និងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឃ- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។

ង- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។

ច- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។

ឆ- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

ជ- ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

ឈ- អនុសាសន៍ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ជុំទី៤ ដែលកម្ពុជាបានទទួលយកនៅឆ្នាំ២០២៤ អំពីសិទ្ធិ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ លក្ខណៈភេទ សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាព បន្តពូជ។

ញ- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១នៃរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ដ- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣។

ឋ- ផែនការយុទ្ធសាស្ត្រនារីភេនៈទី៦ ឆ្នាំ២០២៤-២០២៨ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាព អង់អាចដល់ស្ត្រីនិងក្មេងស្រី។

ឌ- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥។

ឍ- ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងផែនការសកម្មភាព ឆ្នាំ២០២៤-២០៣០ តាមដានអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទ ស្តីពីប្រជាជននិងអភិវឌ្ឍន៍។

ណ- ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០២២-២០២៤។

ត- គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០។

ថ- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣។

ទ- ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។

ធ- យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ឆ្នាំ២០១៧-២០២១។

ន- នីតិវិធីប្រតិបត្តិស្តង់ដាក្នុងការឆ្លើយតបនិងលើកកម្ពស់សីលធម៌សង្គមតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២៣។

ដ-ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី ឆ្នាំ២០១៧។

១.១.២- ក្របខ័ណ្ឌអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិ និងចូលរួមសកម្មភាពមួយចំនួនដើម្បីទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ក្នុងនោះរួមមាន៖

ក- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទក្នុងឆ្នាំ១៩៩២ និងពិធីសារតាមដម្រើសឆ្នាំ២០១០។

ខ- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៩២។

គ- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ។

ឃ- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារនិងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌។

ង- សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។

ច- ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ។

ឆ- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លេខ១៣២៥ ១៩២០ និងលេខ១៨៨៨ ដែលទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខ។

ជ- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៥ «សម្រេចសមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីនិងកុមារីទាំងអស់» រួមមានគោលដៅក្នុងការលុបបំបាត់អំពើហិង្សាគ្រប់ទម្រង់លើស្ត្រីនិងក្មេងស្រីនៅមជ្ឈដ្ឋានសាធារណៈនិងឯកជន រួមទាំងការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចប្រភេទផ្សេងៗទៀត។

បន្ថែមពីនេះ ព្រះរាជាណាចក្រកម្ពុជាក៏បានចូលរួមក្នុងការប្តេជ្ញាចិត្តថ្នាក់តំបន់តាមរយៈសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)ដែលមានគណៈកម្មាការអាស៊ានស្តីពីការលើកកម្ពស់និងការការពារសិទ្ធិស្ត្រីនិងកុមារ ដើម្បីការពារសិទ្ធិស្ត្រីផងដែរ។ ការប្តេជ្ញាចិត្តសំខាន់ៗនិងគោលការណ៍ណែនាំដែលបានផ្តល់ជូនតាមរយៈអាស៊ាន រួមមាន៖

ក- សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនៅអាស៊ាន ឆ្នាំ២០០៤។

ខ- សេចក្តីប្រកាសរបស់អាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៤។

គ- សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងការលុបបំបាត់អំពើហិង្សាលើកុមារ ឆ្នាំ២០១៣។

ឃ- ផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៦-២០២៥។

ង- សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ឆ្នាំ២០០៧។

ច- ឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ឆ្នាំ២០១៧។

ឆ- សេចក្តីថ្លែងការណ៍សិទ្ធិមនុស្សអាស៊ាន ឆ្នាំ២០១២។

ជ- អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ឆ្នាំ២០១៥។

ឈ- ផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

ញ- គោលការណ៍ណែនាំអាស៊ានសម្រាប់បង្កើតនីតិវិធីប្រតិបត្តិការស្តង់ដាជាតិសម្រាប់ការឆ្លើយតបដែលមានការសម្របសម្រួលចំពោះអំពើហិង្សាលើស្ត្រីនិងកុមារី ឆ្នាំ២០២៤។

ត- គោលការណ៍ណែនាំតំបន់អាស៊ានក្នុងការប្រមូលនិងប្រើប្រាស់ទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

១.២- ស្ថានភាពអំពើហិង្សាលើស្ត្រី

អំពើហិង្សាលើស្ត្រីនិងក្មេងស្រី គឺជាការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងឡាយណាដែលបណ្តាលឱ្យមានឬអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដល់ស្ត្រី រួមទាំងការគំរាមកំហែងនៃអំពើបែបនេះ រួមមានការបង្ខិតបង្ខំ ឬការដកហូតសិទ្ធិសេរីភាពដោយបំពាន ទោះកើតឡើងនៅកន្លែងសាធារណៈឬនៅក្នុងជីវិតឯកជនក៏ដោយ។ នៅទូទាំងពិភពលោក វិសមភាពយេនឌ័រនិងនិយាមសង្គម អាកប្បកិរិយានិងឥរិយាបថដែលបង្កគ្រោះថ្នាក់កើតចេញពីវិសមភាពយេនឌ័រ ត្រូវបានទទួលស្គាល់ថាជាមូលហេតុចម្បងដែលនាំឱ្យមានអំពើហិង្សាលើស្ត្រី។

នៅប្រទេសកម្ពុជា ស្ត្រីនិងក្មេងស្រី នៅគ្រប់កម្រិតនៃប្រាក់ចំណូល វប្បធម៌ និងវណ្ណៈសង្គមទាំងអស់ នៅតែបន្តរងគ្រោះដោយអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច។ ស្ត្រីរងគ្រោះដោយអំពើហិង្សា អាចនៅតាមផ្ទះ នៅកន្លែងធ្វើការនៅក្នុងសហគមន៍ និងតាមប្រព័ន្ធអនឡាញ។ ប្រភេទអត្រាប្រហ៊ាឡង់នៃអំពើហិង្សាលើស្ត្រី ដែលកើតមានញឹកញាប់ជាងគេនៅកម្ពុជា គឺប្រភេទអំពើហិង្សាពីដៃគូស្និទ្ធស្នាល អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ។

លើសពីនេះ ក៏មានការយល់ដឹងកាន់តែច្រើនផងដែរថា ស្ត្រីនិងក្មេងស្រីមកពីក្រុមខុសៗគ្នាបានជួបប្រទះការរើសអើងនិងវិសមភាពក្នុងទម្រង់ផ្សេងៗគ្នា និងមានភាពប្រទាក់ក្រឡាគ្នា ដែលធ្វើឱ្យពួកគេងាយនឹងរងគ្រោះដោយអំពើហិង្សា។ ក្រុមទាំងនេះ រួមមានជាអាទិ៍ស្ត្រីមានពិការភាព ស្ត្រីរស់នៅជាមួយមេរោគអេដស៍ឬរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ស្ត្រីចាស់ជរា ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ ពលករទេសន្តរប្រវេសន៍ជាស្ត្រី កម្មការិនីរោងចក្រ ស្ត្រីធ្វើការក្នុងវិស័យកម្សាន្តសប្បាយ និងស្ត្រីជាអ្នកធ្វើការផ្សេងទៀត ស្ត្រីតាមជនបទឬស្ត្រីក្រីក្រ ស្ត្រីក្នុងពន្ធនាគារ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីជនជាតិភាគតិចឬកាន់សាសនាភាគតិច។ និយាមសង្គម ការមាក់ងាយ និងការរើសអើង ជាកត្តាដែលនាំឱ្យហានិភ័យនៃអំពើហិង្សាមានការកើនឡើង ឬធ្វើឱ្យស្ត្រីកាន់តែជួបការលំបាកក្នុងការទទួលបាននូវកិច្ចការពារនិងសេវាសំខាន់ៗនានា។

រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល បានធ្វើការស្រាវជ្រាវយ៉ាងច្រើនដែលផ្តល់ការយល់ដឹងអំពីប្រហ៊ាឡង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសអំពើហិង្សាពីដៃគូស្និទ្ធស្នាល។ ការសិក្សាថ្នាក់ជាតិទាំងនេះមានសារៈសំខាន់សម្រាប់ផ្តល់ការយល់ដឹងអំពីបទពិសោធនៃការទទួលរងអំពើហិង្សារបស់ស្ត្រី និងបំពេញបន្ថែមដោយការសិក្សាតូចៗជាច្រើនឬការសិក្សាដែលផ្តោតលើក្រុមស្ត្រីផ្សេងៗ ដែលជួយផ្តល់ការយល់ដឹងអំពីនិន្នាការនៃអំពើហិង្សាលើស្ត្រីនៅកម្ពុជា។ ខាងក្រោមនេះជាសេចក្តីសង្ខេបលទ្ធផលរកឃើញការស្រាវជ្រាវថ្មីបំផុតនៅកម្ពុជា។

១.២.១- អត្រាប្រហ៊ាឡង់នៃអំពើហិង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទ

ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថា៖

ក- ស្ត្រីអាយុពី១៥-៤៩ឆ្នាំ ២១ភាគរយធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវចិត្ត ផ្លូវកាយ ឬផ្លូវភេទ ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្នឬដៃគូចុងក្រោយបំផុតនៅក្នុងជីវិតរបស់ពួកគេ។ អត្រានេះថយចុះពី២៩% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម២១% ក្នុងឆ្នាំ២០២២(ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០២២)។

ខ- ក្នុងចំណោមស្ត្រីគ្រប់វ័យ១០នាក់ មាន១នាក់កំពុងរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល នៅក្នុងការរស់នៅក្នុងទំនាក់ទំនងរបស់ពួកគេ។

គ- ស្ត្រីអាយុពី១៥-២៩ឆ្នាំ ១០ភាគរយធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវកាយឬផ្លូវភេទពីអ្នកដែលមិនមែនជាដៃគូរបស់ពួកគេ។

ឃ- ៤៣ភាគរយនៃស្ត្រីអាយុពី១៥-៤៩ ឆ្នាំ ដែលធ្លាប់មានប្តី ដៃគូស្និទ្ធស្នាល និងធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវកាយឬផ្លូវភេទ បានរាយការណ៍ថា ពួកគេធ្លាប់រងរបួសដោយសារតែអំពើហិង្សា ហើយស្ត្រីដែលធ្លាប់រងគ្រោះដោយអំពើហិង្សាបែបនេះ ក្នុងរយៈពេល១២ខែចុងក្រោយ ៤៥ភាគរយបានរាយការណ៍ថាធ្លាប់រងរបួស។ របួសដែលកើតឡើងញឹកញាប់បំផុតរួមមានដាច់រលាត់ ជាំ ឬឈឺ ៤១ភាគរយ បន្ទាប់មកគឺរបួសភ្នែក គ្រេច ភ្លាត់ធ្លឹង ឬរលាក ១៦ភាគរយ និងរបួសជ្រៅ បាក់ធ្លឹង បាក់ធ្មេញ ឬរបួសធ្ងន់ធ្ងរផ្សេងទៀត ៤ភាគរយ។

ង- ស្ត្រីអាយុពី១៥-៤៩ឆ្នាំ ៣ភាគរយធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវភេទ ហើយ២ភាគរយធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវភេទ ក្នុងរយៈពេល១២ខែមុនការអង្កេត។ ភាគរយនៃស្ត្រីដែលធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវភេទ បានថយចុះពី៦ភាគរយនៅឆ្នាំ២០១៤ មកនៅត្រឹម៣ភាគរយ នៅឆ្នាំ២០២១-២០២២។

១.២.២- អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា

ទម្រង់ថ្មីមួយនៃអំពើហិង្សាលើស្ត្រីដែលទើបលេចចេញ គឺជាអំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។ អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា គឺជាសកម្មភាពណាមួយដែលត្រូវបានប្រព្រឹត្តជាជំនួយធ្វើឱ្យកាន់តែធ្ងន់ធ្ងរ ឬរីកសាយភាយដោយការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានឬឧបករណ៍ឌីជីថលផ្សេងទៀត ដែលនាំឱ្យកើតមានឬទំនងជាអាច

បណ្តាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ ផ្លូវចិត្ត សង្គម នយោបាយ ឬសេដ្ឋកិច្ច ឬការរំលោភបំពានផ្សេងទៀត ទាក់ទងនឹងសិទ្ធិនិងសេរីភាព។ អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ត្រូវបានរាយការណ៍ជាទូទៅថាជាការបៀតបៀនផ្លូវភេទនិងការឃ្លាំមើល ហើយជារឿយៗវាជាការបំពារបំពានដោយប្រើរូបភាព ការធ្វើសារ ការបង្ហោះ និងការហៅទូរសព្ទដែលគេ មិនចង់បានជាដើម។ អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអំពើហិង្សាក្រៅប្រព័ន្ធអ៊ីនធឺណិត ដែលចាប់ផ្តើមពីក្រៅប្រព័ន្ធអ៊ីនធឺណិតនិងកាន់តែខ្លាំងតាមរយៈមធ្យោបាយឌីជីថល។ ទោះបីជាបច្ចុប្បន្នការស្រាវជ្រាវនៅមានកម្រិតក៏ដោយ ក៏មានភស្តុតាងដែលមានបង្ហាញថា ស្ត្រីនិងក្មេងស្រីបានរងផលប៉ះពាល់លើសលប់ ហើយក្រុមស្ត្រីខ្លះដែលងាយរងគ្រោះដោយអំពើហិង្សាក្រៅប្រព័ន្ធបច្ចេកវិទ្យា គឺងាយមានហានិភ័យខ្ពស់ដោយអំពើហិង្សាតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ក្នុងនោះ រួមមានទាំងស្ត្រីវ័យក្មេង ស្ត្រីដែលចេញមុខច្រើនជាសាធារណៈ អ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច និងជនជាតិភាគតិច ស្ត្រីចំណាកស្រុក និងស្ត្រីមានពិការភាពជាដើម។

អ្នកដែលត្រូវបានសម្ភាសប្រមូលធាតុចូល សម្រាប់ការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនេះ បានលើកឡើងថា ពួកគេបានមើលឃើញករណីអំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យាកាន់តែមានការកើនឡើង។ ភស្តុតាងបង្ហាញអំពីអត្រាប្រាំឡង់នៃអំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យាទាមទារឱ្យមានការពិចារណាយ៉ាងយកចិត្តទុកដាក់ នៅពេលរៀបចំការឆ្លើយតបនានា៖

ក- ការសិក្សាស្រាវជ្រាវស្តីពី «ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមរយៈប្រព័ន្ធបច្ចេកវិទ្យា» ឆ្នាំ២០២១ បង្ហាញថា កុមារអាយុចន្លោះពី១២ទៅ១៧ឆ្នាំ ដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត មាន១១ភាគរយ ធ្លាប់រងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធបច្ចេកវិទ្យា។

ខ- ការសិក្សាបែបគុណវិស័យស្តីពី «អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភបំពានតាមរយៈប្រព័ន្ធបច្ចេកវិទ្យា» ឆ្នាំ២០២៤ បង្ហាញថា អំពើហិង្សានិងការរំលោភបំពានតាមរយៈប្រព័ន្ធបច្ចេកវិទ្យាបានរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ចនិងសង្គម។ ការសិក្សានេះបានកំណត់ពីភាពចាំបាច់ក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ជាក់លាក់ ដើម្បីការពារស្ត្រីនិងក្មេងស្រីឱ្យរួចផុតពីការរំលោភបំពាននិងការបៀតបៀនតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។

១.២.៣- អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេង

ក- ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថា ជារួមភាគរយនៃស្ត្រីដែលរៀបការមុនអាយុ១៨ឆ្នាំ បានថយចុះពី២៥ភាគរយ មកនៅត្រឹម១៩ភាគរយ ខណៈដែលភាគរយសម្រាប់បុរសវិញបានធ្លាក់ចុះពី៩ភាគរយ មកនៅត្រឹម៦ភាគរយ។ ការវិភាគបន្ថែមលើទិន្នន័យនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា បានរកឃើញថា ការធ្លាប់រៀបអាពាហ៍ពិពាហ៍ឬអាពាហ៍ពិពាហ៍កុមារមានអត្រាខ្ពស់ នៅក្នុងខេត្តនភូមិភាគឦសាននៃប្រទេស រួមមានខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ហើយនិងខេត្តត្បូងឃ្មុំ។

ខ- ការសិក្សាមួយនៅក្នុងខេត្តចំនួន៩ ក៏បានរកឃើញផងដែរថា អត្រាប្រាំឡង់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅវ័យក្មេង នៅមានកម្រិតខ្ពស់ នៅក្នុងខេត្តរតនគិរី ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ដែលសុទ្ធតែជាខេត្តដែលមានប្រជាជន ជាជនជាតិដើមភាគតិចច្រើនជាងគេបំផុត។

១.២.៤- ស្ត្រីដែលកាន់តែប្រឈមនឹងហានិភ័យងាយរងគ្រោះដោយអំពើហិង្សា

ក- ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថា ស្ត្រីនៅតំបន់ជនបទទំនងជាជួបប្រទះអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដោយប្តី ដៃគូស្និទ្ធស្នាលបច្ចុប្បន្នឬចុងក្រោយបំផុតរបស់ពួកគេច្រើនជាងស្ត្រីនៅតំបន់ទីក្រុង២៣ភាគរយ ធៀបនឹង១៧ភាគរយ ធ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ពីស្វាមី/ដៃគូស្និទ្ធស្នាលបច្ចុប្បន្នឬថ្មីបំផុតរបស់ពួកគេ។

ខ- ខេត្តដែលមានអត្រាអំពើហិង្សាពីដៃគូស្និទ្ធស្នាលខ្ពស់បំផុត គឺខេត្តមណ្ឌលគិរី បន្ទាប់មកគឺខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង។ ខេត្តទាំងនេះ គឺជាខេត្តដែលមានប្រជាជនជាជនជាតិដើមភាគតិចក្នុងចំនួនច្រើន លើកលែងតែខេត្តបន្ទាយមានជ័យ។

គ- របាយការណ៍បែបគុណវិស័យដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានរកឃើញថា មានការកើនឡើងជាក់ស្តែងនូវអំពើហិង្សាលើស្ត្រីជនជាតិដើមភាគតិចបើធៀបនឹងរយៈពេលមុនឆ្នាំ២០១៥។

ឃ- ការសិក្សាមួយ នាឆ្នាំ២០២៤ ដែលធ្វើឡើងនៅក្នុងប្រទេសថៃ ទៅលើពលករទេសន្តរប្រវេសន៍ជាស្ត្រីមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បានរកឃើញថា ពលករទេសន្តរប្រវេសន៍ជាស្ត្រីទាំងនោះ គឺងាយរងគ្រោះដោយការរើសអើងនិងអំពើហិង្សា។ ក្នុងចំណោមអ្នកដែលបានឆ្លាប់ត្រូវបានគេរើសអើងចំនួន៦៣,២ភាគរយ បានរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាលក្នុងជីវិតរបស់ពួកគេ។

១.២.៥- និយាមសង្គមដែលបង្កឱ្យគ្រោះថ្នាក់បណ្តាលឱ្យអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបន្តកើតឡើង និងជាឧបសគ្គកាំងដល់ការស្វែងរកជំនួយ

ក- នៅឆ្នាំ២០២៣ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនបានរៀបចំការរៀនសូត្រពីការវិភាគលើទិន្នន័យដែលមានស្រាប់ទាក់ទងនឹងយេនឌ័រនិងនិយាមសង្គមដែលបង្កគ្រោះថ្នាក់ ដែលជាមូលហេតុនាំឱ្យកើតមានអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការវិនិយោគនាពេលបច្ចុប្បន្នក្នុងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ បានបង្ហាញឱ្យឃើញថា : បុរសត្រូវបានគេរំពឹងថាត្រូវមានអំណាចនិងមានប្រៀបលើស្ត្រី បុរសត្រូវតែរឹងមាំនិងស្ត្រីត្រូវតែទន់ភ្លន់ បុរសជាមេគ្រួសារនិងជាអ្នកសម្រេចចិត្តសំខាន់ៗ ស្ត្រីទទួលបន្ទុកការងារផ្ទះ អំពើហិង្សាគឺជារឿងដែលកើតមានក្នុងរង្វង់គ្រួសារឯកជន និងស្ត្រីគួរតែរក្សាភាពស្ងៀមស្ងាត់ចំពោះអំពើហិង្សាដើម្បីរក្សាគ្រួសារឱ្យបន្តនៅជុំគ្នា។ល។

ខ- ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថាការទទួលយករបស់ស្ត្រីនិងបុរសចំពោះការវាយដំប្រពន្ធដោយហេតុផលណាមួយគឺជាការបង្ហាញពីស្ថានភាពនៃការឱ្យតម្លៃស្ត្រីទាបក្នុងសង្គមទាក់ទងនឹងតួនាទីនិងសិទ្ធិអំណាចស្ត្រី។ នៅកម្ពុជា ស្ត្រី៣៧ភាគរយមានភាគរយខ្ពស់ជាងបុរស១៦ភាគរយអាយុ១៥-៤៩ឆ្នាំ យល់ស្របថា ប្តីប្រើអំពើហិង្សាលើប្រពន្ធជាការត្រឹមត្រូវ ដោយហេតុផលយ៉ាងតិចមួយក្នុងចំណោមហេតុផលជាក់លាក់។ ស្ត្រីនៅជនបទទំនងជាមានជំនឿនេះច្រើនជាងស្ត្រីនៅទីក្រុង។ អត្រានេះថយចុះពី៥០,៤ភាគរយនៅឆ្នាំ២០១៤ មក៣៧ភាគរយ នៅឆ្នាំ២០២១-២០២២ ។

គ- ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ បានរកឃើញថា ស្ត្រីដែលឆ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវកាយឬផ្លូវភេទ ៥៣ភាគរយមិនដែលស្វែងរកជំនួយឬប្រាប់នរណាម្នាក់អំពីអំពើហិង្សានោះឡើយ។ ស្ត្រីទំនងជាស្វែងរកជំនួយ បើពួកគេជួបប្រទះទាំងអំពើហិង្សាផ្លូវកាយ ទាំងផ្លូវភេទ។ ស្ត្រីភាគច្រើនស្វែងរកជំនួយពីគ្រួសារឬអ្នកជិតខាង ប៉ុន្តែ២១ភាគរយបានស្វែងរកជំនួយពីនគរបាល។ ទិន្នន័យបង្ហាញថា ស្ត្រីដែលឆ្លាប់រងគ្រោះដោយអំពើហិង្សាផ្លូវកាយឬផ្លូវភេទជាង៥០ភាគរយមិនបានប្រាប់នរណាម្នាក់ឡើយ។ អ្នកដែលបានរាយការណ៍បានប្រាប់គ្រួសាររបស់ពួកគេ៥៩ភាគរយ បន្ទាប់មកនគរបាល២១ភាគរយ។

ឃ- ការសិក្សាស្រាវជ្រាវស្តីពីអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាមួយប្រពន្ធនៅវ័យក្មេង បានរកឃើញថា មូលហេតុចម្បងនិងកត្តាពាក់ព័ន្ធផ្សេងៗទៀត រួមមានវិសមភាពយេនឌ័រ និយាមសង្គមនិងប្បធម៌ ដូចជាការអនុវត្តតាមប្រពៃណី និងការទទួលយកតាមវប្បធម៌នូវសកម្មភាពផ្លូវភេទក្នុងវ័យក្មេងជាដើម។

១.៣- លទ្ធផលសម្រេចបាន

១.៣.១- ការបង្ការទប់ស្កាត់

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ ឆ្នាំ២០១៩-២០២៣ មានប៉ុន្មានស្ត្រីបង្ការទប់ស្កាត់គ្រប់ជ្រុងជ្រោយ ដោយផ្តោតលើការឆ្លើយតបចំពោះបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ និងបង្កើនចំណេះដឹងឥរិយាបថ និងជំនាញ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ទំនាក់ទំនងដែលគ្មានអំពើហិង្សាសម្រាប់ឃុវជន គ្រួសារនិងកុមារ

នៅក្នុងសហគមន៍និងកន្លែងធ្វើការ ក៏ដូចជាតាមរយៈវប្បធម៌និងប្រព័ន្ធផ្សព្វផ្សាយ។ យុទ្ធសាស្ត្របង្ការទប់ស្កាត់ដោយប្រើប្រាស់វិធីសាស្ត្រអកិក្រម ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងអកិក្រមអន្តរវិស័យ ដែលមានការចូលរួមពីម្ចាស់សិទ្ធិនិងអ្នកដែលមានកាតព្វកិច្ចត្រូវបំពេញ។

ក្រសួងកិច្ចការនារី សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងវិស័យឯកជន បានដឹកនាំសម្របសម្រួលការផ្សព្វផ្សាយសារលើកកម្ពស់ការយល់ដឹងជាសាធារណៈដោយប្រើប្រាស់វិធីសាស្ត្រដោយផ្ទាល់ និងតាមប្រព័ន្ធបណ្តាញសង្គម ជាពិសេសក្នុងកំឡុងយុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ជារៀងរាល់ឆ្នាំ ដែលអនុលោមតាមប្រធានបទសកល។

ក្រសួងកិច្ចការនារីបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាសេវាអប្បបរមាសម្រាប់អ្នកផ្តល់សេវា មានបញ្ចូលការផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងការលើកកម្ពស់ការយល់ដឹងអំពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់ ការអត់ឱនឱ្យអំពើហិង្សានិងការពារជនរងគ្រោះនិងជនងាយរងគ្រោះអ្នកនៅរស់ពីអំពើហិង្សា រួមទាំងក្រុមស្ត្រីដែលមានអត្តសញ្ញាណចម្រុះក្នុងការស្វែងរកជំនួយ។

យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ដែលជំរុញឥរិយាបថសមភាពយេនឌ័រ និងវិធីសាស្ត្របែបអហិង្សា ការគោរពអត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទចម្រុះ ក៏ដូចជាពង្រឹងជំនាញ ចំណេះដឹង ឥរិយាបថ និងការប្រាស្រ័យទាក់ទងក្នុងគ្រួសារដែលវិជ្ជមាននិងអហិង្សា នឹងត្រូវបន្តអនុវត្តដោយក្រសួងកិច្ចការនារីនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ក្រសួងកិច្ចការនារីបានរៀបចំយុទ្ធសាស្ត្រអប់រំផ្សព្វផ្សាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ នៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់និយាមសង្គមនិងយេនឌ័របែបវិជ្ជមាន ដោយប្រើប្រាស់ថ្នាលបណ្តាញសង្គម និងទំនាក់ទំនងនានា ដូចជាតេឡេក្រាម ហ្វេសប៊ុក យូធូប តិកតុក និងគេហទំព័ររបស់ក្រសួងកិច្ចការនារីជាដើម។ យុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ បានផ្តល់ការអប់រំផ្សព្វផ្សាយដល់ប្រជាជនប្រមាណ៣,៩លាននាក់។

គំរូទប់ស្កាត់អំពើហិង្សាលើស្ត្រីកម្រិតបឋមតាមវិធីសាស្ត្រសាសា «ការចាប់ផ្តើម ការយល់ដឹង ការគាំទ្រ និងសកម្មភាព» ត្រូវបានអង្គការសេកម្មភាពលើពិការភាពនិងការអភិវឌ្ឍអន្តរជាតិយកមកកែសម្រួល ដើម្បីកៀរគរការគាំទ្រនានា ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានពិការភាព។

ក្រសួងអប់រំ យុវជន និងកីឡា បានពង្រីកវិសាលភាពនៃការអនុវត្តឧបករណ៍អប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ ដែលបានបញ្ចូលអំពើហិង្សាទាក់ទងនឹងយេនឌ័រ ភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជក្នុងកម្មវិធីសិក្សានៅសាលារដ្ឋ(ថ្នាក់ទី៥-១២)និងឯកជន ជាមួយកុមារក្រៅសាលារៀននិងសហគមន៍។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានយកចិត្តទុកដាក់ក្នុងការចូលរួមចំណែកលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យសិទ្ធិមនុស្សទាំងថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានផ្តល់សេវាប្រឹក្សាច្បាប់ និងមេធាវីជួយការពារក្តីដោយឥតបង់ថ្លៃដល់ជនក្រីក្រនិងអ្នកដែលត្រូវបានមេធាវីបដិសេធមិនព្រមការពារក្តី និងបានបង្កើតឱ្យមានក្រុមមេធាវីស្ម័គ្រចិត្ត ក្នុងការផ្តល់កិច្ចអន្តរាគមន៍ទាំងផ្នែកមនុស្សធម៌និងផ្នែកច្បាប់ដល់ជនងាយរងគ្រោះ រួមមានជនក្រីក្រ ស្ត្រី កុមារ ជនមានពិការភាព និងអ្នកជាប់ឃុំដែលគ្មានមេធាវី។ល។ លើសពីនេះ ការបណ្តុះបណ្តាលអ្នកផ្តល់សេវាជួរមុខអំពីស្តង់ដាសេវាអប្បបរមាផ្សេងៗ ត្រូវបានធ្វើឡើងនៅក្នុងតំបន់ដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

នៅកន្លែងធ្វើការ ការបៀតបៀនផ្លូវភេទគ្រប់ទម្រង់ត្រូវបានហាមឃាត់និងចាត់វិធានការយ៉ាងតឹងរឹង។ ការប្រញ្ជាប់ការយល់ដឹងពីបញ្ហានេះ ត្រូវបានអនុវត្តដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស អង្គការសង្គមស៊ីវិល អ្នកគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន រោងចក្រកាត់ដេរ និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។

ក្រុមការងារអន្តរក្រសួង(ក្រសួងកិច្ចការនារីនិងក្រសួងព័ត៌មាន)ទទួលបន្ទុកពង្រឹងសមត្ថភាពនិងត្រួតពិនិត្យការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី បានកត់សម្គាល់ឃើញថា មានតែមួយចំនួនក្នុងការអនុវត្តតាមប្រការទាំង១៥នៃក្រមប្រតិបត្តិនេះ។ ភាពដោគដ័យមួយ គឺការរាយការណ៍ព័ត៌មានស្របតាម

ប្រការ២ ដែលបានចែងថា«ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនត្រូវរាយការណ៍ព័ត៌មានដែលរៀបរាប់លម្អិត បង្ហាញខ្លឹមសារលម្អិតឬរូបភាពលម្អិតអំពីសកម្មភាពហិង្សាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីឬអំពើរំលោភបំពានផ្លូវភេទ ដែលបង្កឱ្យមានភាពតានតឹងក្នុងអារម្មណ៍ ចំពោះអ្នកអាន អ្នកស្តាប់ អ្នកទស្សនា ឬអ្នកពាក់ព័ន្ធនោះទេ»។

កម្មវិធីទូរសព្ទដៃ «អេបសុវត្ថិភាពយើង» ត្រូវបានផ្តួចផ្តើមឡើងដោយក្រសួងកិច្ចការនារី ក្រោមជំនួយថវិកានិងបច្ចេកទេសពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន និងសហការអនុវត្តដោយអង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា ក្នុងគោលបំណងឱ្យអ្នកប្រើប្រាស់ ជាពិសេសជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានភាពងាយស្រួលក្នុងការតភ្ជាប់ព័ត៌មានស្វែងរកសេវាជំនួយ លេខទូរសព្ទជំនួយបន្ទាន់ និងកិច្ចអន្តរាគមន៍នានា ដែលផ្តល់នូវព័ត៌មានសំខាន់ៗ ដូចជា (១) ការលើកកម្ពស់ការយល់ដឹងពីអំពើហិង្សានិងការបៀតបៀនផ្លូវភេទ និង(២) តភ្ជាប់បណ្តាញទំនាក់ទំនងសម្រាប់ការបញ្ជូនជនរងគ្រោះទៅកាន់សេវាគាំទ្រផ្សេងៗ ដែលសមស្របនិងទាន់ពេលវេលា។ ក្រុមគោលដៅនៃកម្មវិធីនេះ រួមមានកម្មករ កម្មការិនី ស្ត្រីក្នុងសហគមន៍ សិស្ស និស្សិត។

កម្មវិធីទូរសព្ទចល័ត My Journey ត្រូវបានបង្កើតឡើងដោយភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីនិងដាក់ឱ្យប្រើប្រាស់ ដែលអាចផ្តល់ព័ត៌មានសំខាន់ៗគួរឱ្យទុកចិត្ត និងអាចយកទៅអនុវត្តតាមដល់ពលករទេសន្តរប្រវេសន៍ជាស្ត្រីកម្ពុជាអំពីសិទ្ធិរបស់ពួកគេ និងសេវាដែលពួកគេមានសិទ្ធិទទួលបាន នៅក្នុងប្រទេសគោលដៅនិងនៅប្រទេសកម្ពុជា។

កម្មវិធីទូរសព្ទដៃ «សុខភាពយុវជន» របស់ក្រសួងអប់រំ យុវជន និងកីឡាដែលគាំទ្រដោយក្រសួងកិច្ចការនារីមានបញ្ចូលព័ត៌មានស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ មកដល់ពេលនេះ កម្មវិធីនេះត្រូវបានគេទាញយកមកប្រមាណជា៣០ ០០០ដង។

វិធីសាស្ត្រមិត្តជួយមិត្ត ត្រូវបានរៀបចំឡើង ដើម្បីផ្តល់វេទិកា សម្រាប់ចែករំលែកព័ត៌មានអំពីហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈក្រុមអនឡាញដូចជាBreakthrough និងក្រុមពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលជួបគ្នាផ្ទាល់ជាដើម។ វិធីសាស្ត្រមិត្តជួយមិត្តក៏ត្រូវបានប្រើប្រាស់ជាមួយយុវជនអប់រំមិត្តនៅក្នុងកម្មវិធីអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយផងដែរ ដើម្បីពង្រីកការផ្សព្វផ្សាយទៅកាន់យុវជនផ្សេងទៀត។

នគរបាលកំពុងអនុវត្តវិធីសាស្ត្រ «នគរបាលនិងសហគមន៍» ដើម្បីបង្កើនការចូលរួមជាមួយសហគមន៍ សំដៅទប់ស្កាត់អំពើហិង្សាលើស្ត្រីឱ្យបានកាន់តែប្រសើរ។

នគរបាលនិងអាជ្ញាធរមូលដ្ឋានបានអនុវត្តសកម្មភាពបង្កើនការយល់ដឹងអំពីច្បាប់នានាទាក់ទងនឹងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងចែកចាយខិត្តបណ្ណនិងផ្ទាំងរូបភាពនៅក្នុងសហគមន៍។ ក្រសួងមហាផ្ទៃរាយការណ៍ថា បានធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ ព្រមទាំងធ្វើអន្តរាគមន៍និងការពារជនរងគ្រោះចំនួន ៨ ៤៧០លើក ដែលមានអ្នកចូលរួមសរុបចំនួន១៧៦ ២៧១នាក់ (ស្រី៨១ ៥៩១នាក់)។

ការវិភាគកម្រិតទីពីរនៃការស្រាវជ្រាវដែលមានស្រាប់លើនិយាមសង្គមដែលបង្កគ្រោះថ្នាក់ ត្រូវបានធ្វើឡើងដោយក្រសួងកិច្ចការនារីដោយមានការគាំទ្រពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ដើម្បីស្វែងយល់ថា តើការស្រាវជ្រាវបច្ចុប្បន្នបានបង្ហាញអ្វីខ្លះអំពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់ ដែលរួមចំណែកនាំឱ្យអំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើង។

១.៣.២- កិច្ចការពារផ្តួចប្បាប់និងសេវាពហុវិស័យ

ការរៀបចំស្តង់ដាសេវាអប្បបរមា ដើម្បីណែនាំអំពីការផ្តល់សេវាប្រកបដោយគុណភាព និងការសម្របសម្រួលឱ្យកាន់តែប្រសើរនិងទាន់ពេលវេលា ត្រូវបានរៀបចំកន្លងមក រួមមាន៖

- គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ក្រសួងកិច្ចការនារី ដើម្បីផ្តល់ការណែនាំអំពីវិធីសាស្ត្រផ្តោតលើជនរងគ្រោះ ក្នុងការបញ្ជូនជនរងគ្រោះទៅកេសេវាក្នុងចំណោមអ្នកផ្តល់សេវានានា (សុខាភិបាល នគរបាល យុត្តិធម៌ និងសេវាសង្គម)។

- បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ក្រសួងកិច្ចការនារីនិងក្រសួងសុខាភិបាល ផ្តល់ការណែនាំអំពីក្រមសីលធម៌ជំនាញទំនាក់ទំនងផ្តោតលើជនរងគ្រោះ និងផ្តល់ការគាំទ្រចិត្តសង្គម រួមទាំងការចូលរួមជាមួយជនរងគ្រោះ ការប៉ាន់ប្រមាណសុវត្ថិភាព និងការរៀបចំផែនការសុវត្ថិភាព ការផ្តល់ព័ត៌មានអំពីសេវា ការបង្កើតជម្រើសដោយផ្អែកលើតម្រូវការនិងបំណងប្រាថ្នារបស់ជនរងគ្រោះ និងបទដ្ឋានទាំងនេះក៏ណែនាំផងដែរអំពីក្រមសីលធម៌ក្នុងការធ្វើទំនាក់ទំនង ការចងក្រងបណ្តាញ និងការបញ្ជូនបន្តរវាងអ្នកផ្តល់សេវា ការត្រួតពិនិត្យនិងការថែទាំខ្លួនឯង ជាដើម។
- គោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រីនិងកុមារនៅកម្ពុជារបស់ក្រសួងកិច្ចការនារី ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការណែនាំដល់ភ្នាក់ងារ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី និងអ្នកផ្តល់សេវាផ្សេងទៀត អំពីការអនុវត្តច្បាប់និងរបៀបនៃការជួយជនរងគ្រោះដែលធ្វើការពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ខ្លឹមសារគោលការណ៍ណែនាំទាំងនេះផ្តល់ការណែនាំអំពីការអនុវត្តច្បាប់។
- គោលការណ៍ណែនាំនានាស្តីពីការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាល រួមមានគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារក្នុងប្រព័ន្ធសុខាភិបាល និងសៀវភៅណែនាំគ្លីនិកសម្រាប់ការឆ្លើយតបចំពោះអំពើហិង្សាពីដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទ និងសៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងផ្នែកសុខាភិបាលដូចជាគោលការណ៍ណែនាំស្តីពីការថែទាំសុខភាពរបស់ស្ត្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សា គោលការណ៍ណែនាំស្តីពីការធ្វើកោសល្យវិច័យ និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីការធ្វើកោសល្យវិច័យដោយឥតគិតថ្លៃ និងទម្រង់ដែលត្រូវបំពេញ។
- គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទគ្រួសារប្រកបដោយការឆ្លើយតបយេនឌ័រនិងការត្រួតពិនិត្យករណីអំពើហិង្សលើស្ត្រី ត្រូវបានរៀបចំឡើង ដើម្បីធានាថា ការសម្រុះសម្រួលត្រឹមករណីរឿងរដ្ឋប្បវេណីតែប៉ុណ្ណោះ និងត្រូវបានធ្វើឡើងដោយមានការយល់ព្រមនិងស្របតាមច្បាប់របស់កម្ពុជា ព្រមទាំងការណែនាំនៅក្នុងកញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា។ ដំណើរការនេះត្រូវតែផ្តល់វិធានការការពារដូចគ្នាឬច្រើនជាងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដល់ជនរងគ្រោះ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ឆ្លើយតបចំពោះករណីកិច្ចការពារកុមារ ដែលមានបញ្ហាលទាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រលើកុមារ ដូចជាករណីរំលោភសេពសន្តវៈ ឬអំពើហិង្សាផ្លូវភេទផងដែរ។

ការសម្របសម្រួលរវាងវិស័យសំខាន់ៗ ក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី កំពុងធ្វើឡើងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដើរតួនាទីជាយន្តការថ្នាក់ជាតិ ក្នុងការដឹកនាំសម្របសម្រួល រៀបចំ អនុវត្ត និងតាមដានត្រួតពិនិត្យផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងដើម្បីឱ្យក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលអាចចែករំលែកព័ត៌មានអំពីវឌ្ឍភាពបញ្ហាប្រឈម និងដំណោះស្រាយក្នុងការអនុវត្តការងារដែលមានក្នុងផែនការសកម្មភាពជាតិ។ ក្រសួងកិច្ចការនារីគឺជាប្រធានក្រុមការងារ និងមានលេខាធិការដ្ឋានជាជំនួយដល់ក្រុមការងារនេះ។ ក្រុមការងារនេះមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២៨ និងដៃគូអភិវឌ្ឍ សង្គមស៊ីវិលចំនួន២៧។
- ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្តនិងស្រុក-ខណ្ឌ(យន្តការថ្នាក់ក្រោមជាតិ ដែលបង្កើតឡើងក្រោមគណៈម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ(គ.ក.ស.ក)រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងពង្រឹងកិច្ចសហការរវាងអ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលសេវាឆ្លើយតបករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា។ ដឹកនាំនិងសម្របសម្រួលដោយប្រធានគ.ក.ស.ក អភិបាលរងខេត្ត ក្នុងការសម្របសម្រួលនិងការឆ្លើយតបជួរមុខពីសំណាក់

អ្នកផ្តល់សេវាសំខាន់ៗ ដូចជាកិច្ចការនារី សុខាភិបាល សង្គមកិច្ច នគរបាលនិងយុត្តិធម៌ និងតួអង្គរដ្ឋនិងមិនមែនរដ្ឋ ដែលពាក់ព័ន្ធ។ យន្តការទាំងនេះលើកកម្ពស់ការចែករំលែកព័ត៌មានអំពីសេវាអាទិភាពនិងសកម្មភាពបង្ការ ទប់ស្កាត់នានា ការបង្កើតការឆ្លើយតបដោយមានការចូលរួមសម្របសម្រួលគ្នាជាប្រព័ន្ធចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការពង្រឹងសមត្ថភាពការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការអនុវត្តល្អៗក្នុងការឆ្លើយតប។ ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួន១១ ត្រូវបានបង្កើតនៅរាជធានី ខេត្ត និងនៅថ្នាក់ស្រុកចំនួន៥៣ក្នុងចំណោមស្រុកចំនួន១៦៣ទូទាំងប្រទេសកម្ពុជា។

- បន្ទប់ផ្តល់ប្រឹក្សាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានរៀបចំចំនួន៤៦បន្ទប់នៅក្រសួងកិច្ចការនារី នៅខេត្តនិងឃុំគោលដៅ ដើម្បីផ្តល់កន្លែងឯកជនសម្រាប់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- ក្រសួងកិច្ចការនារី សហការជាមួយក្រសួងសុខាភិបាល បានបង្កើតកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅទីតាំងចំនួន១១នៅក្នុងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្នុងគោលបំណង «បង្កើននូវការផ្តល់សេវាជួយដល់ជនរងគ្រោះប្រកបដោយគុណភាព មានប្រសិទ្ធភាពនិងទាន់ពេលវេលា ជាមួយអ្នកផ្តល់សេវាពាក់ព័ន្ធ»។

ការបណ្តុះបណ្តាលអ្នកផ្តល់សេវាជួរមុខអំពីស្តង់ដាសេវាអប្បបរមាផ្សេងៗ ត្រូវបានធ្វើឡើងនៅក្នុងតំបន់ដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងយេនឌ័រ។

- កញ្ចប់បណ្តុះបណ្តាលត្រូវបានបង្កើតឡើងសម្រាប់ស្តង់ដាសេវាអប្បបរមានីមួយៗ (សូមពិនិត្យមើលខាងលើ) ដែលជួយឱ្យការឆ្លើយតបចំពោះករណីនានាកាន់តែល្អ តាមរយៈការអនុវត្តជំនាញប្រាស្រ័យទាក់ទងដំបូង របៀបធ្វើការជាមួយជនរងគ្រោះ ចំណេះដឹងផ្នែកច្បាប់ និងការបញ្ជូនទៅកសេវាពាក់ព័ន្ធកាន់តែល្អប្រសើរ។ គ្រូបង្គោលនៅក្រសួងកិច្ចការនារីបានធ្វើការពង្រឹងសមត្ថភាពបន្តដល់ក្រុមគ្រូបង្គោលនៃមន្ទីរកិច្ចការនារី ដែលជាខេត្តមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីឱ្យពួកគាត់បន្តចែករំលែកចំណេះដឹងនៃកញ្ចប់សេវាទាំងនេះ ទៅដល់សមាជិកក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុក ក្រោមការគាំទ្រពីកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាពនិងសមធម៌ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល។
- ផ្នែកសុខាភិបាលនៅក្នុងខេត្តគោលដៅ បានទទួលការបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំសុខាភិបាលសម្រាប់ឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈក្រសួងសុខាភិបាល។
- សៀវភៅគោលសម្រាប់គ្រូស្តីពីការប្រយុទ្ធប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតឡើងដើម្បីបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជ្រើសរើសថ្មីនៅបណ្ឌិត្យសភានគរបាលកម្ពុជា។ សៀវភៅគោលនេះ ផ្តោតលើការបង្កើនការយល់ដឹងរបស់នគរបាលអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការកសាងជំនាញទំនាក់ទំនងដើម្បីធ្វើការឆ្លើយតបឱ្យបានកាន់តែប្រសើរ។
- ការបណ្តុះបណ្តាលត្រូវបានផ្តល់ដល់អ្នកផ្តល់សេវាជួរមុខ ស្តីពីការឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រីអំពីការគ្រប់គ្រងករណី ជំនាញទំនាក់ទំនងការសម្របសម្រួលសេវា និងទិន្នន័យរដ្ឋបាលជាដើម។
- ការបណ្តុះបណ្តាលកន្លងមក ត្រូវបានដល់នគរបាលប្រឆាំងការជួញដូរមនុស្ស នគរបាលអធិការដ្ឋាននស្រុកនិងនគរបាលប៉ុស្តិ៍ ដើម្បីកសាងសមត្ថភាពឆ្លើយតបរបស់នគរបាល រួមទាំងការធ្វើឱ្យកាន់តែប្រសើរនូវការប្រាស្រ័យទាក់ទង និងការងារនគរបាលសហគមន៍។
- វិទ្យាស្ថានជាតិសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងរៀបចំមេរៀន ដើម្បីជាជ្រើងជំនាញសង្គមកិច្ច ហើយមានមេរៀនមួយអំពីការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រក៏ត្រូវបានរៀបចំឡើងផងដែរ។

វឌ្ឍនភាពផ្សេងទៀតដែលមានការទទួលស្គាល់កាន់តែច្រើនឡើងអំពីសារៈសំខាន់នៃការមានប្រកផ្សេងៗគ្នា ដើម្បីឱ្យស្ត្រីដែលរងគ្រោះដោយអំពើហិង្សាអាចទទួលបានសេវា។

- ក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារីទាំង២៥រាជធានីខេត្ត បានបង្កើតបណ្តាញទូរសព្ទផ្តល់ជំនួយ និងបានធ្វើការពង្រឹងសមត្ថភាពអំពីរបៀបផ្តល់ប្រឹក្សាពីចម្ងាយ និងវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់បណ្តាញទូរសព្ទផ្តល់ជំនួយ។ បណ្តាញទូរសព្ទផ្តល់ជំនួយនេះ ក៏បានផ្តល់ជំនួយដល់ពលករទេសន្តរប្រវេសន៍ជាស្ត្រីដែលប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រផងដែរ។
- ក្រសួងកិច្ចការនារីបានបង្កើតប្រព័ន្ធឆ្លើយតបដោយស្វ័យប្រវត្តិ ដែលភ្ជាប់ចំពោះទំព័រហ្វេសប៊ុករបស់ខ្លួន ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងព័ត៌មាននៃសេវានានា ដល់សាធារណជនជាពិសេសស្ត្រីរងគ្រោះដោយអំពើហិង្សា។
- ក្រសួងកិច្ចការនារីបានបង្កើតកម្មវិធីទូរសព្ទដៃ «អេបសុវត្ថិភាពយើង» ដែលអាចផ្តល់ព័ត៌មានអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ សេវា និងការគាំទ្រផ្សេងៗ ព្រមទាំងមានភ្ជាប់ទំនាក់ទំនងទៅកាន់ជំនួយបន្ទាន់ផងដែរក្នុងគោលបំណងដើម្បីឱ្យអ្នកប្រើប្រាស់ ជាពិសេសសជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានភាពងាយស្រួលក្នុងការតភ្ជាប់ព័ត៌មានស្វែងរកសេវាជំនួយ លេខទូរសព្ទជំនួយបន្ទាន់ និងកិច្ចអន្តរាគមន៍នានា ដែលផ្តល់នូវព័ត៌មានសំខាន់ៗ (១) ការលើកកម្ពស់ការយល់ដឹងពីអំពើហិង្សានិងការបៀតបៀនផ្លូវភេទ (២) តភ្ជាប់បណ្តាញទំនាក់ទំនងសម្រាប់ការបញ្ជូនជនរងគ្រោះទៅកាន់សេវាគាំទ្រផ្សេងៗ ដែលសមស្របនិងទាន់ពេលវេលា។ ក្រុមគោលដៅនៃកម្មវិធីនេះ រួមមានកម្មករ កម្មការិនី ស្ត្រីក្នុងសហគមន៍ សិស្ស និស្សិត។
- កម្មវិធីទូរសព្ទចល័ត My Journey បញ្ចូលព័ត៌មានអំពីសេវាសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងត្រូវបានភ្ជាប់ទៅនឹងបញ្ជីព័ត៌មានទំនាក់ទំនង ទៅកាន់អ្នកផ្តល់សេវានៅថ្នាក់ជាតិនិងថ្នាក់តំបន់។
- អង្គការបណ្តាញទូរសព្ទជំនួយសម្រាប់កុមារកម្ពុជា បានពង្រីកបណ្តាញទូរសព្ទផ្តល់ជំនួយ២៤ម៉ោងរបស់ខ្លួនដើម្បីផ្តល់ព័ត៌មាននានានិងព័ត៌មានអំពីការបញ្ជូនទៅរកសេវាដល់ស្ត្រីដែលប្រឈមនឹងអំពើហិង្សា រាប់បញ្ចូលទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រីផងដែរ។

សៀវភៅផែនទីសេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក នៅក្នុងខេត្តមួយចំនួនដើម្បីគាំទ្រដល់ការបញ្ជូនទៅរកសេវាសំខាន់ៗ។

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតបទប្បញ្ញត្តិសុខភាពសិក្សា បទប្បញ្ញត្តិប្រឹក្សាកុមារ និងការអប់រំវិន័យបែបវិជ្ជមាន។ កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីលើកទឹកចិត្តឱ្យយុវជននិងបុគ្គលិកអប់រំប្រើប្រាស់កម្មវិធីទូរសព្ទដៃ NoDrug។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនិងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តកិច្ចសហប្រតិបត្តិការដើម្បីអនុវត្តគម្រោងស្តីពី«ការផ្តល់សេវាការពារក្តីជូនស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សា» ដែលមិនមានលទ្ធភាពស្វែងរកសេវាមេធាវី សំដៅជួយឱ្យពួកគេទទួលបានការការពារសិទ្ធិតាមផ្លូវច្បាប់ ក្នុងគោលដៅរួមចំណែកពង្រឹងការអនុវត្តច្បាប់និងពន្លឿនដំណើរការកាត់ក្តីឱ្យទាន់ពេលវេលាដើម្បីទប់ស្កាត់ និងឆ្លើយតបដល់ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

ពីឆ្នាំ២០២០ដល់ឆ្នាំ២០២៣ សាលាដំបូងខេត្តចំនួន៧ បានចេញដីកាការពារសរុបចំនួន២៣ (ក្រសួងយុត្តិធម៌)។

ប្រព័ន្ធប្រមូលទិន្នន័យឌីជីថលស្តីពីការផ្តល់សេវានិងបញ្ជូនលើករណីអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ក្រសួងកិច្ចការនារី ក្នុងគោលបំណងជួយពង្រឹងការគ្រប់គ្រងករណីពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ក្រុមការងារក្នុងក្រសួងកិច្ចការនារី និងថ្នាក់ក្រោមជាតិ និងបានអនុវត្តសាកល្បងដោយមន្ត្រីមន្ទីរកិច្ចការនារីចំនួន៨ខេត្ត ដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ត្រូវបានពង្រីកវិសាលភាព ដើម្បីបញ្ចូលព័ត៌មានលម្អិតនិងរបាយការណ៍តាមប្រភេទអំពីសេវាដែលត្រូវបានផ្តល់ដល់ស្ត្រីនិងកុមារងងឿលប៉ះពាល់ដោយអំពើហិង្សា។

បញ្ជីត្រួតពិនិត្យតាមដានគុណភាពសេវាត្រូវបានបង្កើតឡើងដោយក្រសួងកិច្ចការនារី ដើម្បីពិនិត្យនិងតាមដានការសម្របសម្រួលផ្តល់សេវាចាំបាច់ៗ ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយគុណភាព រួមមាន: គោលការណ៍ណែនាំស្តីពីកិច្ចការការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រីនិងកុមារនៅកម្ពុជា គោលការណ៍ណែនាំស្តីពីការកម្រិតការប្រើប្រាស់ ការសម្រុះសម្រួលក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបញ្ជីត្រួតពិនិត្យការពេញចិត្តទទួលនិងផ្តល់សេវាត្រូវបានរៀបចំនិងអនុវត្តសាកល្បង។

ឧបករណ៍ពិនិត្យតាមដានចំនួន២ ដែលបានបង្កើតនិងអនុវត្ត គឺ (១) ការបង្កើតនិងដាក់ឱ្យប្រើប្រាស់បទដ្ឋានសេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង(២) ការប្រមូលទិន្នន័យពីការឆ្លុះបញ្ចាំងដំណើរការរបស់ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលគាំទ្រដោយកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាពនិងសមធម៌ និងអនុវត្តដោយក្រុមការងារក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារីដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជារៀងរាល់ឆ្នាំ និងមានការបដិភាគថវិការដ្ឋនិងអង្គការដៃគូគាំទ្រ។

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលរក្សានូវលទ្ធភាពនៃការប្រើប្រាស់ «ការសម្របសម្រួលនិងការផ្សះផ្សា» ដោយអាជ្ញាធរជាតិសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយសារវាពឹងផ្អែកលើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ (រួមទាំងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ)។ មាត្រា២និង១១នៃព្រះរាជក្រឹត្យចែងថា វិវាទដែលអាចដោះស្រាយដោយប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមមានវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទផ្សេងទៀតដែលកំណត់ដោយច្បាប់ ដូចដែលអាចត្រូវបានព្រមព្រៀងស្នើសុំឬទទួលយកដោយភាគី។ វិវាទមួយចំនួនត្រូវបានលើកលែង : មាត្រា២មិនរាប់បញ្ចូល«វិវាទដែលមិនស្ថិតនៅក្រោមការសម្របសម្រួលនិងការផ្សះផ្សាដូចមានចែងក្នុងច្បាប់» ហើយមាត្រា១១មិនរាប់បញ្ចូល«បទល្មើសព្រហ្មទណ្ឌលើកលែងតែមានចែងដោយច្បាប់»។

១.៣.៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

ក- ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយ

- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១នៃរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្រនារីរតន:ទី៦ ឆ្នាំ២០២៤-២០២៨ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥
- ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងផែនការសកម្មភាព ឆ្នាំ២០២៤-២០៣០ តាមដានអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទស្តីពីប្រជាជននិងអភិវឌ្ឍន៍
- ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា ឆ្នាំ២០២២-២០២៤
- គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០
- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣
- ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១
- យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ឆ្នាំ២០១៧-២០២១
- ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានពីអំពើហិង្សាលើស្ត្រី ឆ្នាំ២០១៧។

ខ- យន្តការថ្នាក់ជាតិ

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ក្រសួងកិច្ចការនារី
- គណៈកម្មាធិការជាតិលើកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ក្រុមការងារបញ្ជាបយេនឌ័រតាមក្រសួង ស្ថាប័ន
- ក្រុមការងារបច្ចេកទេសយេនឌ័រ
- ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហគ្រិនភាពស្ត្រី។

គ- ថ្នាក់ក្រោមជាតិ

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- មន្ទីរកិច្ចការនារីរាជធានី ខេត្ត
- ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្តនិងថ្នាក់ស្រុក
- កន្លែងផ្តល់សេវាចម្រុះឆ្លើយតបជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅមន្ទីរពេទ្យបង្អែករាជធានី ខេត្ត
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។

១.៣.៤- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានប្រើប្រាស់បានពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មទៅជាទម្រង់សាមញ្ញជាងមុន។ ឧបករណ៍នេះត្រូវបានប្រើប្រាស់ដោយសមាជិកនៃក្រុមការងារនេះ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុមលេខាធិការដ្ឋានក្រសួងកិច្ចការនារី។ អាទិភាពសំខាន់មួយគឺការរៀបចំទម្រង់របាយការណ៍និងប្រព័ន្ធមួយ សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗប្រើប្រាស់ ដើម្បីរាយការណ៍ពីការអនុវត្តសកម្មភាពនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

បញ្ជីត្រួតពិនិត្យតាមដានគុណភាពសេវាត្រូវបានបង្កើតឡើងដោយក្រសួងកិច្ចការនារី ដើម្បីពិនិត្យនិងតាមដានការសម្របសម្រួលផ្តល់សេវាចាំបាច់ ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយគុណភាព រួមមាន : គោលការណ៍ណែនាំស្តីពីកិច្ចការការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រីនិងកុមារនៅកម្ពុជា គោលការណ៍ណែនាំស្តីពីការកម្រិតការប្រើប្រាស់ ការសម្រុះសម្រួលក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបញ្ជីត្រួតពិនិត្យការពេញចិត្តទទួលនិងផ្តល់សេវាត្រូវបានរៀបចំនិងអនុវត្តសាកល្បង។

ឧបករណ៍ពិនិត្យតាមដានចំនួន២ ដែលបានបង្កើតនិងអនុវត្ត (១) ការបង្កើតនិងដាក់ឱ្យប្រើប្រាស់បទដ្ឋានសេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង(២) ការប្រមូលទិន្នន័យពីការឆ្លុះបញ្ចាំងដំណើរការអនុវត្តក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលគាំទ្រដោយកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាពនិងសមធម៌ និងអនុវត្តដោយក្រុមការងារក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារីដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជារៀងរាល់ឆ្នាំ និងមានការបដិភាគគាំទ្រដោយថវិការដ្ឋនិងអង្គការដៃគូអភិវឌ្ឍ។

ការវាយតម្លៃផែនការសកម្មភាពជាតិលើកទី៣ ត្រូវបានធ្វើឡើងដែលបានកំណត់ភាពជោគជ័យ បញ្ហាប្រឈម និងអាទិភាពសំខាន់ៗដែលបានណែនាំសម្រាប់ផែនការសកម្មភាពជាតិលើកទី៤នេះ។

ក្នុងកំឡុងពេលនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ការស្រាវជ្រាវសំខាន់ៗមួយចំនួនត្រូវបានអនុវត្តៈ

- ការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ ត្រូវបានបញ្ចប់ដោយមានបញ្ចូលម៉ូឌុលអំពើហិង្សាក្នុងគ្រួសារ។
- ក្នុងកំឡុងពេលដែលមានការរាតត្បាតនៃជំងឺកូវីដ១៩ បើតាមរបាយការណ៍នានា មានការសិក្សាជាច្រើនត្រូវបានធ្វើឡើងដើម្បីស្វែងយល់អំពីស្ថានភាពនៃក្រុមផ្សេងៗគ្នា រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រីផងដែរ។ ការសិក្សាទាំងនោះបានបញ្ចូលចំណុចសំខាន់ៗមួយចំនួនស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជាការទទួលបានសេវាជាដើម។
- ការសិក្សាមួយដែលពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ស្តីពីនិយាមសង្គម បង្កគ្រោះថ្នាក់ ដែលនាំឱ្យអំពើហិង្សាទាក់ទងនឹងយេនឌ័របន្តកើតឡើងត្រូវបានធ្វើឡើង។ ក្នុងបរិបទដែលកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័សនៅកម្ពុជា ទិន្នន័យថ្មីៗមានសារៈសំខាន់ ដើម្បីស្វែងយល់អំពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់នាពេលបច្ចុប្បន្ន។
- ការសិក្សាស្រាវជ្រាវស្តីពីអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ត្រូវបានរៀបចំនិងប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់។ ការសិក្សានេះផ្តោតលើខេត្តចំនួន៩និងបានផ្តល់ទិន្នន័យសំខាន់ៗស្តីពីអត្រាប្រកាំឡង់ មូលហេតុនិងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង។

១.៤- បញ្ហាអាទិភាព

១.៤.១- ការបង្ការទប់ស្កាត់

ទោះបីជាផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ ឆ្នាំ២០១៩-២០២៣ មានយុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រប់ជ្រុងជ្រោយ ផ្តោតលើបរិបទសំខាន់ៗសម្រាប់ការផ្លាស់ប្តូរដែលមានដើម្បីលើកកម្ពស់និងពង្រឹងទំនាក់ទំនងប្រកបដោយសមភាពយេនឌ័រ គ្មានអំពើហិង្សា និងការធ្វើឱ្យកាន់តែប្រសើរនូវឥរិយាបថនិងការអនុវត្តនានាក៏ដោយ ប៉ុន្តែធនធានសម្រាប់អនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់ទាំងនេះនៅមិនទាន់បានទូលំទូលាយ ជាពិសេសនៅសហគមន៍ជាច់ស្រយាល។ ការទប់ស្កាត់អំពើហិង្សាលើស្ត្រី គឺជាការទទួលខុសត្រូវរបស់គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាកិច្ចការនារី សង្គមកិច្ច សុខាភិបាល ព័ត៌មាន នគរបាល អ្នកដឹកនាំសាសនា អ្នកដឹកនាំសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវសហការគ្នាដើម្បីប្រើប្រាស់អភិក្រមទប់ស្កាត់ ដោយមានការសម្របសម្រួលគ្នា ផ្អែកលើកស្តុតាង និងស្របតាមស្ថានភាពនៅកម្ពុជា។

សកម្មភាពបង្ការទប់ស្កាត់ជាច្រើនដែលបានអនុវត្តកន្លងមក គឺផ្តោតតែទៅលើការលើកកម្ពស់ការយល់ដឹង ឬជាការអនុវត្តសកម្មភាពដោយពឹងផ្អែកលើថវិកាគម្រោង ដែលជារឿយៗមានលក្ខណៈប៉ាត់ប៉ាយ បែកខ្ញែក និងមិនគ្រប់ជ្រុងជ្រោយឡើយ។ ទន្ទឹមនឹងការលើកកម្ពស់ការយល់ដឹងដែលមានសារៈសំខាន់ដើម្បីបំពេញបន្ថែមដល់យុទ្ធសាស្ត្រនានា ការកៀរគរចលនាសហគមន៍និងសកម្មភាពផ្សេងទៀតផ្តោតលើការផ្លាស់ប្តូរនិយាមសង្គមដែលមានការប្រែប្រួល គឺមានសារៈសំខាន់ណាស់ ដោយសារតែការលើកកម្ពស់ការយល់ដឹងតែមួយមុខ គឺមិនមានប្រសិទ្ធភាពក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីឡើយ ទោះបីជាមានការផ្សព្វផ្សាយព័ត៌មានអំពីសេវានិងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់ផ្សេងៗមានសារៈសំខាន់យ៉ាងណាក៏ដោយ។

នៅប្រទេសកម្ពុជា ទិន្នន័យដែលអាចរកបានស្តីពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់នៅមានកម្រិតនៅឡើយ ហើយទិន្នន័យភាគច្រើនមានអាយុកាលលើសពី១០ឆ្នាំ។ ហេតុនេះ ត្រូវមានការស្រាវជ្រាវបែបគុណភាពស៊ីជម្រៅ និងបរិមាណភាពស៊ីជម្រៅ ដោយមានបញ្ចូលក្រុមស្ត្រីដែលមានអត្តសញ្ញាណចម្រុះ ដូចជាយេនឌ័រ និន្នាការភេទ ជនជាតិ សាសនា ឋានៈសង្គម។ល។

ដើម្បីយល់កាន់តែច្បាស់អំពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់នាពេលបច្ចុប្បន្ន និងនាំឱ្យអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតែបន្តកើតឡើង ហើយដែលអាចជួយឱ្យគេយល់កាន់តែច្បាស់ ដើម្បីរៀបចំសកម្មភាពបង្ការទប់ស្កាត់បានល្អបំផុត។

ក្របខ័ណ្ឌក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានបង្កើតឡើងដោយអង្គការសុខភាពពិភពលោក និងភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី ដោយភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុច៥.២ ការបញ្ចប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិជាក្របខ័ណ្ឌដែលបានដាក់ចេញនូវបច្ចេកទេសនិងយុទ្ធសាស្ត្រ ដោយផ្តោតលើការពង្រឹងទំនាក់ទំនង ការផ្តល់ភាពអង់អាចដល់ស្ត្រី ការធានាថាមានសេវាកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យបរិយាកាសមានសុវត្ថិភាព ទប់ស្កាត់ការរំលោភបំពានលើកុមារនិងក្មេងវ័យជំទង់ និងការផ្លាស់ប្តូរអាកប្បកិរិយា ជំនឿ និងបទដ្ឋានដែលបង្កគ្រោះថ្នាក់។

ការយល់ដឹងជាសកលកាន់តែច្រើនឡើងអំពីចំណុចប្រទាក់ក្រឡាគ្នានៃអំពើហិង្សាលើស្ត្រីនិងអំពើហិង្សាលើកុមារ។ ពជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដល់ការទប់ស្កាត់ទាំងអំពើហិង្សាលើកុមារនិងអំពើហិង្សាលើស្ត្រីជាមួយនឹងផែនការសកម្មភាពជាតិនិងយុទ្ធសាស្ត្រនានា ដែលបច្ចុប្បន្នកំពុងត្រូវបានធ្វើបច្ចុប្បន្នកម្ម។

កម្មវិធីទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍កុមារនិងការមានផ្ទៃពោះវ័យជំទង់នៅខេត្តតេនគិរី ត្រូវបានអនុវត្តនៅគ្រប់ស្រុកទាំងអស់នៅក្នុងខេត្តនេះ ហើយថវិកាចំណាយរបស់គម្រោងនេះ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ខេត្ត ដោយមានការវិភាជថវិកាផ្សេងៗសម្រាប់ការអនុវត្តគម្រោងនេះ។ បច្ចុប្បន្នផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេងនិងការមានផ្ទៃពោះនៅវ័យជំទង់ ត្រូវបានធ្វើការសិក្សាប៉ាន់ប្រមាណ និងកំពុងដំណើរការរៀបចំផែនការសកម្មភាពជាតិនេះ។

អំពើហិង្សាលើស្ត្រីក្នុងទម្រង់ថ្មីៗ កំពុងលេចឡើងជាបន្តបន្ទាប់។ អ្នកត្រូវបានសម្ភាសផ្តល់ព័ត៌មាន ក្នុងដំណើរការបង្កើតផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានលើកឡើងអំពីការកើនឡើងនៃអំពើហិង្សាតាមប្រព័ន្ធអនឡាញ ឬតាមរយៈប្រព័ន្ធបច្ចេកវិទ្យាមកលើយុវជននិងស្ត្រី។ ស្ត្រីវ័យក្មេង អ្នកសារព័ត៌មានជាស្ត្រី ឥស្សរជនសាធារណៈ និងអ្នកការពារសិទ្ធិមនុស្ស ត្រូវបានគេមើលឃើញជាពិសេសក្នុងការរងគ្រោះចំពោះអំពើហិង្សាប្រភេទនេះ។ ការបង្កើនការយល់ដឹង និងការបង្កើតយុទ្ធសាស្ត្រថ្មីតាមតម្រូវការគឺជារឿងចាំបាច់ដែលត្រូវបានណែនាំតាមរយៈការអនុវត្តជាសកល ដើម្បីឆ្លើយតបចំពោះហានិភ័យថ្មីៗទាំងនេះ។

ឱកាសពង្រីកការអនុវត្តវិធីសាស្ត្រមិត្តជួយមិត្តទាំងជួបផ្ទាល់ ទាំងតាមអនឡាញ គឺជាវិធីសាស្ត្រដែលអាចជួយឱ្យស្ត្រីនិងយុវជនរៀនសូត្រពីគ្នាទៅវិញទៅមក និងចែករំលែកបទពិសោធក្នុងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរបៀបសុវត្ថិភាពនិងភាពជឿជាក់។

ការចូលរួមរបស់បុរសក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីត្រូវបានកំណត់ថាជាអាទិភាព ប៉ុន្តែនៅមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់អំពីវិធីសាស្ត្រផ្តោតលើភស្តុតាង ដើម្បីជំរុញការចូលរួមរបស់បុរសនិងក្មេងប្រុសក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

ការប្រមូលទិន្នន័យជាប្រព័ន្ធសម្រាប់តាមដានវិភាគ ឬរាយការណ៍អំពីប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៃការអនុវត្តផែនការសកម្មភាពជាតិនៅមានកម្រិតនៅឡើយ។ ជាការចាំបាច់ដែលត្រូវមានការបង្កើនការវិនិយោគ ដើម្បីតាមដានវាស់វែង និងសិក្សាពីការអនុវត្តផែនការសកម្មភាពជាតិទាក់ទងនឹងយុទ្ធសាស្ត្រទប់ស្កាត់នៅគ្រប់វិស័យ ដើម្បីស្វែងយល់អំពីអ្វីដែលមានប្រសិទ្ធភាពនិងអ្វីដែលមិនដំណើរការ ក្នុងការជំរុញការអនុវត្តផែនការសកម្មភាពជាតិកាន់តែមានប្រសិទ្ធភាព។

១.៤.២- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ

ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ជាតិ គឺជាយន្តការសំខាន់សម្រាប់ចែករំលែកព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ ការមានសមាជិកច្រើនក្នុងក្រុមការងារនេះ ពិបាកក្នុងការប្រមូលផ្តុំនិងរបាយការណ៍ឱ្យចំគោលដៅនិងទាន់ពេលវេលា។ បញ្ហានេះអាចដោះស្រាយបានតាមរយៈការកាត់បន្ថយចំនួនសមាជិក

ឬការបង្កើតឱ្យមានអនុគណៈកម្មការដោះដើម។ លើសពីនេះទៀត ការផ្លាស់ប្តូរមន្ត្រីបង្គោលរបស់ក្រសួង ស្ថាប័ន អាចមានផលប៉ះពាល់លើជំនាញបច្ចេកទេសក្នុងការរៀបចំកម្មវិធីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ដែលចាំបាច់ក្នុងការសម្របសម្រួលការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឱ្យមានប្រសិទ្ធភាព។

ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក គឺជាយន្តការដ៏រឹងមាំ ដើម្បីសម្របសម្រួលការឆ្លើយតបជាប្រព័ន្ធចំពោះករណីអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាលើពលករទេសន្តរប្រវេសន៍ជាស្ត្រី។ បច្ចុប្បន្នក្រុមការងារនេះមិនទាន់បានពង្រីកគ្រប់ទូទាំងប្រទេស និងសមត្ថភាពក្រុមការងារនៅមានកម្រិត។ ដូច្នេះត្រូវធ្វើការពង្រីកនិងពង្រឹងសមត្ថភាពក្រុមការងារ ដើម្បីឱ្យមានការឆ្លើយតបសេវាកាន់តែប្រសើរ។ ជាមួយគ្នានេះដែរ ការគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែជាបញ្ហាប្រឈម ហេតុនេះចាំបាច់ត្រូវការពង្រឹងដំណើរការគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈការបង្កើតនីតិវិធីប្រតិបត្តិការស្តង់ដានៃការគ្រប់គ្រងករណីនឹងពង្រឹងការឆ្លើយតបដែលមានការសម្របសម្រួលដោយផ្តោតលើជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ការបញ្ចូលការគិតគូរអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅក្នុងការឆ្លើយតបក្នុងគ្រាអាសន្ន និងផែនការគ្រប់គ្រងគ្រោះមហន្តរាយ មានសារៈសំខាន់ណាស់ ដើម្បីជានាថា ហានិភ័យត្រូវបានវាយតម្លៃនិងកាត់បន្ថយមកនៅកម្រិតទាបប្រកបដោយប្រសិទ្ធភាពក្នុងកំឡុងពេលមានវិបត្តិ ដូចជាកូវីដ១៩ ទឹកជំនន់ គ្រោះធម្មជាតិ ឬមនុស្សធម៌ផ្សេងទៀត។

គ្រូបង្គោលរបស់ក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារី បានទទួលការពង្រឹងសមត្ថភាព និងបានផ្តល់ការបណ្តុះបណ្តាលអំពីកញ្ចប់សេវាសំខាន់ៗនេះទៅដល់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅថ្នាក់ខេត្តនិងថ្នាក់ស្រុក។ ទោះជាយ៉ាងណាក៏ដោយ ចំនួនគ្រូបង្គោលទាំងនេះមិនទាន់គ្រប់គ្រាន់នៅឡើយ ក្នុងការបំពេញតម្រូវការទៅតាមការបណ្តុះបណ្តាលបន្តអំពីកញ្ចប់សេវាសំខាន់ៗ ដូចជាបទដ្ឋានសេវាអប្បបរមានិងគោលការណ៍ណែនាំពាក់ព័ន្ធ។ លើសពីនេះ ការផ្លាស់ប្តូរមន្ត្រីក៏ជាបញ្ហាប្រឈមផងដែរ ដែលទាមទារឱ្យមានការបណ្តុះបណ្តាលឡើងវិញ ឬវគ្គរំលឹកឡើងវិញជាដើម។

ក្នុងនោះ ក៏មានបញ្ហាប្រឈមសម្រាប់ជនបង្គោលនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ផងដែរ ដោយសារពួកគាត់នឹងមិនទទួលបានឱកាសក្នុងការបណ្តុះបណ្តាលពីកញ្ចប់សេវាសំខាន់ៗនោះទេ ប្រសិនជាពួកគាត់មិនមែនជាសមាជិកនៃក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ទោះបីជាពួកគាត់គឺជាអ្នកផ្តល់សេវាជួរមុខដល់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រក៏ដោយ។

ក្នុងន័យមិនទុកនរណាម្នាក់ចោលពីមជ្ឈដ្ឋានផ្សេងៗគ្នា គឺជាអាទិភាពមួយដែលគួរមានការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មកញ្ចប់បណ្តុះបណ្តាល ដើម្បីជានាឱ្យមានការផ្តោតគ្រប់គ្រាន់លើនិយាមសង្គមដែលបង្កគ្រោះថ្នាក់ចំពោះក្រុមជាក់លាក់ និងជំរុញការអនុវត្តយុទ្ធសាស្ត្រផ្តល់សេវាដែលឆ្លើយតបចំពោះក្រុមស្ត្រីនិងក្មេងស្រីដែលមានអត្តសញ្ញាណចម្រុះ តាមរយៈអន្តរាគមន៍ដែលសមស្របនិងមានផាសុកភាពសមរម្យ។

ផែនទីសេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រមានសារៈសំខាន់ក្នុងការផ្តល់ព័ត៌មានអំពីជម្រើសសេវា ប៉ុន្តែការធ្វើបច្ចុប្បន្នកម្មគឺជាបញ្ហាប្រឈមដែលនៅតែបន្តកើតមាន។ ការកំណត់និងបង្កើតវេទិកាឌីជីថលរួមសម្រាប់សៀវភៅផែនទីសេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមប្រព័ន្ធអនឡាញអាចធ្វើឡើងបានដោយផ្អែកលើព័ត៌មានដែលមាននៅក្នុងគោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះ។ ផែនទីសេវានេះ ត្រូវធ្វើបច្ចុប្បន្នកម្មដើម្បីជួយទៅដល់អ្នកផ្តល់សេវាពាក់ព័ន្ធ។

ទោះបីជាមានភាពល្អប្រសើរខ្លះៗក៏ដោយ ការទទួលបានការការពារផ្លូវច្បាប់ រួមទាំងការចោទប្រកាន់ករណីអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្តវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍ថាជាបទល្មើសព្រហ្មទណ្ឌ និងការប្រើប្រាស់ជីកាការពារនៅមានកម្រិត។ មានជនរងគ្រោះមួយចំនួនតូចតែប៉ុណ្ណោះដែលធ្លាប់ទទួលបានសំណងនិងការអន្តរាគមន៍ក្រៅប្រព័ន្ធតុលាការ ប៉ុន្តែការដោះស្រាយបែបនេះនៅតែបន្តប្រើប្រាស់។

ការទទួលបានជម្រកសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមសហគមន៍នៅមានកម្រិតនៅឡើយ ជ្បិតជម្រើសជម្រកសុវត្ថិភាពនៅមានចំនួនតិចតួច។

ការផ្តល់ការគាំទ្រដំបូងដែលផ្តល់ដោយអ្នកផ្តល់សេវាផ្ទាល់មានភាពប្រសើរជាងមុន ប៉ុន្តែក៏នៅមានចំណុចខ្វះខាតមួយចំនួន ដូចជាជំនាញផ្តល់ប្រឹក្សានិងមធ្យោបាយបញ្ជូនបន្តជាដើម។

កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានបង្កើតនិងដំណើរការ គឺជាកន្លែងតែមួយ ដែលសម្របសម្រួលសេវាពហុវិស័យ។ ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រអាចត្រូវការសេវាច្រើនជាងមួយ ហើយការឆ្លើយតបផ្នែកសុខភាព និងការធ្វើកោសល្យវិច័យកាន់តែប្រសើរជាងមុន ជាពិសេសករណីហិង្សាផ្លូវភេទ។ កន្លែងផ្តល់សេវាចម្រុះនេះមិនទាន់បានពង្រីកឱ្យបាន២៥រាជធានី ខេត្ត នេះជាឱកាសមួយដើម្បីពង្រឹងនិងពង្រីកកន្លែងផ្តល់សេវាចម្រុះ តាមរយៈការភ្ជាប់ទៅនឹងដំណើរការគ្រប់គ្រងករណីឱ្យកាន់តែល្អប្រសើរ ក្នុងការផ្តល់ការគាំទ្រការបញ្ជូនទៅកសេវាសំខាន់ៗជាច្រើនទៀត។

រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល បានបណ្តុះបណ្តាលស្តីពីសេវាឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រដល់នគរបាល ប៉ុន្តែការពង្រឹងសមត្ថភាពនេះនៅមិនទាន់បានទូលំទូលាយនៅឡើយ។

ក្នុងការឆ្លើយតបទៅនឹងតម្រូវការចំពោះមុខរបស់ជនរងគ្រោះ កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កម្មវិធីកសាងជំនាញការងារនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកម្មវិធីផ្សេងៗត្រូវបានរៀបចំនិងអនុវត្ត ប៉ុន្តែការទទួលបានសេវាគាំទ្រពីការប្រកបមុខរបរចិញ្ចឹមជីវិតសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅមានកម្រិតនៅឡើយ។

ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ផ្តល់លទ្ធភាពឱ្យគេអាចយល់កាន់តែច្បាស់និងរៀបចំការណែនាំកាន់តែប្រសើរ ដើម្បីឆ្លើយតបចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការការពារកុមារបានកំណត់តួនាទីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដោយបានចាត់តាំងជនបង្គោលម្នាក់ឱ្យឆ្លើយតបចំពោះករណីការពារកុមារ។ ចាំបាច់ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់ពីអ្នកដែលមានតួនាទីឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

កន្លងមកបញ្ហាប្រឈមចម្បង គឺថវិកាសម្រាប់គាំទ្រការផ្តល់សេវានិងការឆ្លើយតបចំពោះករណីអំពើហិង្សា ជាពិសេសនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ថវិកាសម្រាប់គាំទ្រការអនុវត្តសកម្មភាពជាអាទិភាពនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើម្បីផ្តល់សេវាដល់ជនរងគ្រោះនៅមានកម្រិតនៅឡើយ។

ក្រសួងកិច្ចការនារីបានដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធប្រមូលទិន្នន័យឌីជីថលស្តីពីការផ្តល់សេវានិងបញ្ជូនករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការប្រើប្រាស់ប្រព័ន្ធនេះនៅមានកម្រិតនៅឡើយ ពោលគឺអនុវត្តសាកល្បងតែនៅក្នុងខេត្តមួយចំនួនតែប៉ុណ្ណោះ។ អ្នកផ្តល់សេវាសុខភាពមានប្រព័ន្ធថ្មីមួយផ្សេងទៀតសម្រាប់កត់ត្រាពីហិង្សាទាក់ទងនឹងយេនឌ័រ ប៉ុន្តែប្រព័ន្ធនេះមិនទាន់ត្រូវបានដាក់ឱ្យប្រើប្រាស់បានពេញលេញនៅឡើយទេ។ ចំណែកឯនគរបាលនិងអាជ្ញាធរមូលដ្ឋានភាគច្រើនកត់ត្រាតែករណីដែលត្រូវបានកំណត់ថាមានភាពធ្ងន់ធ្ងរប៉ុណ្ណោះ ដែលនាំឱ្យមានការរាយការណ៍មិនមានភាពគ្រប់ជ្រុងជ្រោយនិងទិន្នន័យនៅមានចន្លោះខ្វះខាត។ ក្នុងន័យនេះ ពុំទាន់មានប្រព័ន្ធប្រើប្រាស់ប្រមូលទិន្នន័យឌីជីថលរួមមួយនោះឡើយ។

ការរៀបចំនិងអនុវត្តគោលនយោបាយនិងវិធានការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័របង្កើនឱ្យមានការចូលរួមពីវិស័យឯកជននិងក្រុមនៅក្នុងសហគមន៍ ដូចជាភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ បណ្តាញមិត្តជួយមិត្ត អ្នកដឹកនាំសាសនា ជាបុរស ស្ត្រី និងភាគីពាក់ព័ន្ធផ្សេងទៀត។

១.៤.៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

ផ្អែកលើការអនុវត្តសកម្មភាពទប់ស្កាត់អំពើហិង្សាលើទាក់ទងនឹងយេនឌ័រកន្លងមក បានបង្ហាញឱ្យឃើញសារៈសំខាន់ច្បាប់ស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ទាមទារឱ្យធ្វើវិសោធនកម្ម ដើម្បីធានាបាននូវអនុលោមភាពនិងសង្គតិភាពទៅនឹងច្បាប់ជាតិនិងអន្តរជាតិថ្មីៗ។

១.៤.៤- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ត្រូវបានកំណត់ថាជាបញ្ហាប្រឈមសំខាន់មួយ ដ្បិតការរាយការណ៍អំពីការអនុវត្តសកម្មភាពនៅមានកម្រិត សូចនាករទំនងជាមានច្រើនពេក និងគ្មានទិន្នន័យដើមគ្រាសម្រាប់ប្រៀបធៀបក្នុងការវាស់វែង។ ដើម្បីធានាថាការបង្ការទប់ស្កាត់ត្រូវបានវាស់វែងឱ្យបានគ្រប់គ្រាន់ ត្រូវមានធនធាន ឧបករណ៍ និងយន្តការតាមដានឱ្យច្បាស់លាស់បន្ថែម។

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អនុវត្តផែនការសកម្មភាពជាតិឱ្យបានកាន់តែប្រសើរ ត្រូវតែរៀបចំច្បាស់លាស់ជាងមុន ជាមួយនឹងអាទិភាពដែលត្រូវបានដាក់ចេញក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

ទិន្នន័យព័ត៌មាននិងរបាយការណ៍ប្រចាំឆ្នាំដែលគ្រប់ជ្រុងជ្រោយមានសារៈសំខាន់ណាស់ក្នុងការបង្ហាញអំពីវឌ្ឍនភាព ភាពប្រឈម និងការកែលម្អឱ្យប្រសើរឡើង ក្នុងការឆ្លើយតបចំពោះបញ្ហាជាអាទិភាព ឈានទៅសម្រេចលទ្ធផលនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

២- យុទ្ធសាស្ត្រ

គោលដៅរួមនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី រួមទាំងក្រុមដែលមានហានិភ័យខ្ពស់ តាមរយៈការបង្កើតកិច្ចអន្តរាគមន៍ ការបង្ការទប់ស្កាត់ ការបង្កើនការឆ្លើយតប ការទទួលបានសេវាប្រកបដោយគុណភាព និងការសម្របសម្រួលពហុវិស័យនិងកិច្ចសហការ។

យុទ្ធសាស្ត្រសំខាន់ៗចំនួន៤ ត្រូវបានកំណត់ជាយុទ្ធសាស្ត្រចម្បងដែលត្រូវផ្តោតការយកចិត្តទុកដាក់ រួមមាន៖

យុទ្ធសាស្ត្រទី១ : ការបង្ការទប់ស្កាត់

យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ

យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

យុទ្ធសាស្ត្រទី៤ : ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ។

ផ្អែកលើយុទ្ធសាស្ត្រទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១ : ការបង្ការទប់ស្កាត់

យុទ្ធសាស្ត្រនេះមានគោលបំណងបង្កើតនិងអនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់សម្របសម្រួល ដើម្បីជួយណែនាំវិធានការទប់ស្កាត់ដោយផ្អែកលើភស្តុតាងនិងការសម្របសម្រួលដោយមានភាគីពាក់ព័ន្ធទាំងអស់។

ក- វិធីសាស្ត្រសម្របសម្រួលសម្រាប់ការបង្ការទប់ស្កាត់

ខ- ការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី

គ- ការអប់រំនិងយុវជន

ឃ- គ្រួសារនិងកូនៗ

ង- សហគមន៍និងកន្លែងធ្វើការ

ច- វប្បធម៌និងប្រព័ន្ធផ្សព្វផ្សាយ។

យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ

ក្នុងកិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ យុទ្ធសាស្ត្រថ្មីនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងបន្ថែមទៀតលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិ ដោយផ្តោតលើការបន្តកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗស្តីពីតួនាទីនិងការទទួលខុសត្រូវក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងពង្រីកយន្តការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីធានាថា ជនរងគ្រោះទទួលបានសេវាពហុវិស័យ។

ក- ការសម្របសម្រួលជាពហុវិស័យ និងគុណភាពនៃសេវាចាំបាច់

ខ- ការគ្រប់គ្រងករណីនិងប្រព័ន្ធទិន្នន័យរដ្ឋបាលចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

គ- សេវាសុខាភិបាល

ឃ- នគរបាលនិងយុត្តិធម៌

ង- សេវាសង្គម។

យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

យុទ្ធសាស្ត្រនេះមានគោលបំណងធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីជានាបាននូវអនុលោមភាពនិងសង្គតិភាពទៅនឹងច្បាប់ជាតិនិងអន្តរជាតិថ្មីៗ។

ក- ការពិនិត្យលើបទដ្ឋានគតិយុត្ត

ខ- ការពិនិត្យលើគោលនយោបាយនិងការពង្រឹងស្ថាប័ន។

យុទ្ធសាស្ត្រទី៤ : ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

យុទ្ធសាស្ត្រនេះមានគោលបំណងដើម្បីជានាថាក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ មានភាពជាក់ស្តែងនិងអាចអនុវត្តបានតាមរយៈដំណើរការរៀបចំផែនការការងារប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ដែលបំពេញបន្ថែមដោយការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការពិនិត្យឡើងវិញចុងក្រោយ។

ក- ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ខ- ការរៀនសូត្រនិងការសិក្សាស្រាវជ្រាវ។

៣- ផែនការសកម្មភាព

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ គឺផ្អែកលើចក្ខុវិស័យរបស់ផែនការយុទ្ធសាស្ត្រនារីរតន: ដែលលើកឡើងថា «ពលរដ្ឋកម្ពុជាទាំងពីរភេទមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយស្ត្រីគួរទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន»។ ផែនការសកម្មភាពជាតិនេះមានគោលបំណងជំរុញឱ្យស្ត្រីមានលទ្ធភាពចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសង្គមនិងការសម្រេចចិត្តជាសាធារណៈលើមូលដ្ឋានស្មើភាពជាមួយបុរស រួមទាំងផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីធានាបាននូវស្វ័យភាពនិងសុខុមាលភាពរបស់គ្រួសារនិងសហគមន៍។

៣.១- ទិសាលភាព

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ គ្របដណ្តប់លើ៖

- គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍ
- អង្គការមិនមែនរដ្ឋាភិបាល
- អង្គការផ្អែកលើជំនឿ សាសនា
- ជនរងគ្រោះនិងក្រុមងាយរងគ្រោះ
- សាធារណជនទូទៅ
- វិស័យឯកជន។

៣.២- គោលអនុវត្តការងារ

អភិក្រមសម្រាប់ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី គឺផ្តល់នូវមូលដ្ឋានច្បាស់លាស់សម្រាប់កិច្ចអន្តរាគមន៍ តាមរយៈការសម្របសម្រួលនិងកិច្ចសហការដើម្បីបង្កើនសមត្ថភាពនិងពង្រីកកិច្ចខិតខំប្រឹងប្រែង ក្នុងគោលបំណងកាត់បន្ថយនិងបង្កើនការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីដើម្បីផ្តល់កិច្ចការពារដល់ជនរងគ្រោះនិងកូនរបស់ពួកគេឱ្យមានប្រសិទ្ធភាព គុណភាព និងបានទាន់ពេលវេលា។

គោលបំណងរួម : អំពើហិង្សាលើស្ត្រីនិងក្មេងស្រីគ្រប់រូប ត្រូវបានកាត់បន្ថយតាមរយៈការបង្កើនកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ ការឆ្លើយតបកាន់តែប្រសើរ លទ្ធភាពទទួលបានសេវាប្រកបដោយគុណភាព និងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាពហុវិស័យ

សូចនាករគោលបំណងរួមទី១ : សមាមាត្រស្ត្រីនិងក្មេងស្រីដែលធ្លាប់ជាដៃគូដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅរងគ្រោះដោយអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតកាលក្នុងរយៈពេល១២ខែមុន(SDG 5.2.1) (ប្រភពទិន្នន័យ : CDHS)

សូចនាករគោលបំណងរួមទី២ : សមាមាត្រនៃស្ត្រីនិងក្មេងស្រីដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅទទួលរងអំពើហិង្សាផ្លូវភេទដោយមនុស្សផ្សេងក្រៅពីដៃគូស្និទ្ធស្នាល(SDG 5.2.2) (ប្រភពទិន្នន័យ : CDHS)

សូចនាករគោលបំណងរួមទី៣ : សមាមាត្រនៃក្មេងស្រីនិងស្ត្រីដែលមានអាយុពី២០-២៤ឆ្នាំដែលបានរៀបការឬរួមរស់ជាមួយគ្នាមុនអាយុ១៥ឆ្នាំ និងមុនអាយុ១៨ឆ្នាំត្រូវបានកាត់បន្ថយ។ (SDG 5.3.1) (ប្រភពទិន្នន័យ : CDHS)

សូចនាករគោលបំណងរួមទី៤ : ប្រជាជនកម្ពុជាកាត់បន្ថយការទទួលយកអំពើហិង្សាលើស្ត្រី។ (ប្រភពទិន្នន័យ : CDHS)

១- យុទ្ធសាស្ត្រទី១ : ការបង្ការទប់ស្កាត់

គោលបំណង : កាត់បន្ថយអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរយៈយុទ្ធសាស្ត្របង្ការទប់ស្កាត់បឋម ដែលមានការសម្របសម្រួលជាពហុវិស័យជាមួយក្រសួង និងស្ថាប័នដែលផ្តោតទៅលើអ្នកពាក់ព័ន្ធសំខាន់ៗ និងនៅទីកន្លែងផ្សេងៗ ដើម្បីឆ្លើយតបចំពោះនិយាមសង្គមបង្កគ្រោះថ្នាក់ ដែលបន្តឱ្យកើតមានអំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងដើម្បីឆ្លើយតបចំពោះកត្តាហានិភ័យផ្សេងៗ។

យុទ្ធសាស្ត្រគន្លឹះ : វិធីសាស្ត្រសម្របសម្រួលសម្រាប់ការបង្ការទប់ស្កាត់

លទ្ធផលទី១ : ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ មានភាពប្រសើរឡើងនៅគ្រប់កម្រិត រួមទាំងកិច្ចសហការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អ្នកផ្តល់សេវា និងវិស័យឯកជន ក្នុងការអនុវត្តកិច្ចអន្តរាគមន៍ទប់ស្កាត់បឋមផ្អែកលើកស្តង់ដែលឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី រួមទាំងក្រុមស្ត្រីដែលមានអត្តសញ្ញាណចម្រុះដោយការចូលរួមរបស់បុរសនិងក្មេងប្រុស។

សូចនាករលទ្ធផលនិងដំណើរការ៖

១ក- ការកសាងយុទ្ធសាស្ត្របង្ការទប់ស្កាត់បឋមជាពហុវិស័យដ៏គ្រប់ជ្រុងជ្រោយមួយដោយផ្អែកលើកស្តង់ដែលអនុវត្តបាន ត្រូវបានរៀបចំនិងអនុវត្តនៅក្នុងប្រទេសកម្ពុជា។ (ស៊ីចង្វាក់គ្នាជាមួយ SDGs និងក្របខ័ណ្ឌក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី)។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	ក្របខ័ណ្ឌពេលវេលា						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
១.១- យុទ្ធសាស្ត្រទប់ស្កាត់ដែលមានការសម្របសម្រួល ត្រូវបានបង្កើតឡើង និងសាកល្បង ជាយុទ្ធសាស្ត្រដែលផ្អែកលើកស្តុតាងនៃវិធានការដែលមានប្រសិទ្ធភាព និងបានបញ្ជាក់ពីកិច្ចអន្តរាគមន៍សម្រាប់ស្ត្រីនិងក្មេងស្រី ដែលមានសាវតារអត្តសញ្ញាណចម្រុះ។	ក- ចំនួនគំរូនៃការបង្ការទប់ស្កាត់ផ្អែកលើកស្តុតាងដែលត្រូវបានសាកល្បងនៅកម្ពុជា រួមទាំងគំរូដែលបានកែសម្រួលយុទ្ធសាស្ត្រទៅតាមតម្រូវការរបស់ស្ត្រីនិងក្មេងស្រី ដែលមានសាវតារចម្រុះ។ គំរូនានាដែលត្រូវបានសាកល្បងនៅក្នុងប្រភេទនៃការពង្រឹងទំនាក់ទំនង ការបង្កើនភាពអង់អាចដល់ស្ត្រី ការកាត់បន្ថយភាពក្រីក្រ ការធានាបរិយាកាសប្រកបដោយសុវត្ថិភាព ការបង្ការទប់ស្កាត់ការរំលោភបំពានក្មេងជំទង់និងកុមារ និងការកែប្រែនិយាមសង្គមដែលបង្កគ្រោះថ្នាក់។ ចំណុចដៅ : ៥ ខ- ការកើនឡើងនៃចំនួនតួអង្គពាក់ព័ន្ធសំខាន់ៗនៅក្នុងវដ្តនិតិបាលនិងសង្គមស៊ីវិល ដែលដឹកនាំវិធានការទប់ស្កាត់ ស្របតាមយុទ្ធសាស្ត្រដែលបានព្រមព្រៀងគ្នា។	ក- ពង្រឹងសមត្ថភាពរបស់តួអង្គសំខាន់ៗនៅក្នុងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងសង្គមស៊ីវិល ស្តីពីការអនុវត្តល្អដូចជា ក្របខ័ណ្ឌក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅក្នុងការទប់ស្កាត់បឋមដែលដោះស្រាយបុព្វហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកត្តាហានិភ័យរបស់ក្រុមផ្សេងៗនៅកម្ពុជា។ ខ- ពង្រឹងសមត្ថភាពតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងការឆ្លើយតបទំនាក់ទំនងរវាងអំពើហិង្សាលើស្ត្រីនិងអំពើហិង្សាលើកុមារ។ គ- ប៉ាន់ប្រមាណ/ពិនិត្យឡើងវិញដើម្បីកំណត់រកគំរូនៃការងារទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលអនុវត្តក្របខ័ណ្ឌអន្តរជាតិបែបនេះ ដូចជាក្របខ័ណ្ឌក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី សម្រាប់ការ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • អ.យ.ក. • ក.ប • ក.ម.ផ. • ក.ព.ម. • ក.ធ.ស. • ស.អ.យ. • ក.អ.ដ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		សាកល្បងនិងការអនុវត្តតាមនៅក្នុងបរិបទកម្ពុជា។ ឃ- ស្រាវជ្រាវស្តីពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់និងកត្តាហានិភ័យដែលត្រូវដោះស្រាយនៅក្នុងយុទ្ធសាស្ត្រទប់ស្កាត់រួមបញ្ចូលសម្រាប់ក្រុមស្ត្រីដែលមានសាវតារអត្តសញ្ញាណចម្រុះ។ ង- បង្កើតយុទ្ធសាស្ត្រមួយដែលមានគំរូដោយផ្អែកលើភស្តុតាងនិងការរៀនសូត្រសម្រាប់គំរូទប់ស្កាត់ ដែលបានសាកល្បងនៅកម្ពុជា ដែលពង្រឹងទំនាក់ទំនង បង្កើនភាពអង់អាចដល់ស្ត្រី កាត់បន្ថយភាពក្រីក្រ ធានាបរិយាកាសប្រកបដោយសុវត្ថិភាព ទប់ស្កាត់ការរំលោភបំពានកុមារ និងកែប្រែបទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ រួមទាំងទំនាក់ទំនងរវាងអំពើហិង្សាលើស្ត្រីនិងកុមារ។ ច- សាកល្បងគំរូកម្មវិធីទប់ស្កាត់ដោយផ្អែកលើយុទ្ធសាស្ត្រទប់ស្កាត់ដែលបានអនុម័ត។								

		ឆ- ផ្តល់សុពលភាពនិងទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចផ្លូវការស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច។ ជ- កំណត់នូវយុទ្ធសាស្ត្រក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ដោយតម្រូវឱ្យមានការចូលរួមរបស់ស្ត្រី ជាសមាជិកភាព។								
១.២- ក្រុមបុរសនិងក្រុមយុវជន មានការចូលរួមយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី។	ក- ចំនួនកម្មវិធីបង្ការទប់ស្កាត់ដែលមានកំណើនការចូលរួមយ៉ាងសកម្មរបស់ក្រុមបុរសនិងក្រុមយុវជន រួមទាំងអ្នកដែលប្រឈមមុខនឹងហានិភ័យនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលមានអត្តសញ្ញាណនិងសាវតារចម្រុះ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១	ក- រៀបចំនិងផ្សព្វផ្សាយយុទ្ធសាស្ត្រជំរុញការចូលរួមរបស់ក្រុមបុរសនិងក្រុមយុវជន និងសេចក្តីណែនាំស្តីពីការបំពេញបន្ថែមលើយុទ្ធសាស្ត្រទប់ស្កាត់ តាមវិធីដ៏សមស្របដើម្បីជំរុញការចូលរួមរបស់ក្រុមបុរសនិងក្រុមយុវជននិងក្រុមមនុស្សមានឥទ្ធិពល។ ខ- ផ្តល់ការអភិវឌ្ឍសមត្ថភាពស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាដល់ក្រុមបុរសនិងក្រុមយុវជនជនបង្គោល ក្នុងជួរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • អ.យ.ក. • ក.ម.ផ. • ក.ជ.ស. • ក.អ.ដ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		គ- រៀបចំកម្មវិធីបង្ការទប់ស្កាត់គំរូដោយផ្អែកលើយុទ្ធសាស្ត្រដែលមានការចូលរួមរបស់បុរសនិងក្មេងប្រុស រួមទាំងសម្រាប់ក្រុមស្ត្រី ដែលមានសាវតារចម្រុះ។								
១.៣- ការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងស្ត្រីវ័យក្មេង តាមរយៈការគំរាមកំហែងដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។	ក-ចំនួនយុទ្ធនាការផ្អែកតាមការចូលរួមយុទ្ធនាការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា(តាមបណ្តាញសង្គម)។	ក- សិក្សាស្រាវជ្រាវ/ការវិភាគស្ថានភាពដើម្បីកសាងការយល់ដឹងអំពីអំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា រួមទាំងការប្រើប្រាស់បញ្ញាសិប្បនិម្មិត។ ខ- រៀបចំពិនិត្យនិងកំណត់ប្រភេទមាតិកា ពាក្យពេចន៍ រូបភាព វីដេអូ និងសកម្មភាពផ្សេងៗ ដែលចាត់ទុកថាជាអំពើហិង្សាលើប្រព័ន្ធអនឡាញ និងមានផលប៉ះពាល់ដល់វប្បធម៌ សេដ្ឋកិច្ចសង្គមកម្ពុជា ដើម្បីជាមូលដ្ឋានក្នុងការរកដំណោះស្រាយនានាដើម្បីដកហូតចេញពីប្រព័ន្ធអនឡាញ។ គ- ផលិតសម្ភារៈនិងវីដេអូអប់រំស្តីពីការអនុវត្តល្អៗ និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ប.ទ. • គ.ជ.ស.ស.ខ **ស្ថាប័នដៃគូចូលរួម៖** • អ.យ.ក. • ក.ម.ផ. • ក.ព.ម. • ស.អ.យ. • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល • រដ្ឋបាលថ្នាក់ក្រោមជាតិ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		ឃ-រៀបចំយុទ្ធនាការនិងវេទិកា ផ្សព្វផ្សាយពីអំពើហិង្សាលើស្ត្រី តាមរយៈប្រព័ន្ធបច្ចេកវិទ្យាទាំង ថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ ក្រោមជាតិ។ ង- អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាក្នុង ការឆ្លើយតបនិងលើកកម្ពស់ សីលធម៌សង្គមតាមប្រព័ន្ធ អនឡាញ។ ច- លើកកម្ពស់យុទ្ធនាការ ផ្សព្វផ្សាយអប់រំ និងប្រមូល ព័ត៌មានស្តីពីការទប់ស្កាត់អំពើ ហិង្សាលើស្ត្រីនិងកុមារតាម បណ្តាញសង្គមនិងបញ្ញា សិប្បនិម្មិត។ ឆ- សម្រាប់នីតិវិធីប្រតិបត្តិស្តង់ដា របស់នាយកដ្ឋានប្រឆាំងបទ ល្មើសបច្ចេកវិទ្យា មានប្រព័ន្ធ ទូរសព្ទជំនួយបន្ទាន់ ទំព័រ ហ្វេសប៊ុក នាយកដ្ឋានប្រឆាំង បទល្មើសបច្ចេកវិទ្យា និងលេខ ទូរសព្ទ ០២៣ ៧២៦ ៨២២ និងលេខ ០៣១ ៦០១ ២៣៤៥។								

យុទ្ធសាស្ត្រគន្លឹះ : ការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី

លទ្ធផលទី**២** : ស្ថិយភាពផ្នែកស្ថានភាពសេដ្ឋកិច្ចនិងសង្គមរបស់ស្ត្រីនិងក្មេងស្រី ត្រូវបានពង្រឹង។

សូចនាករលទ្ធផលនិងដំណើរការ៖

២ក- ចំនួនស្ត្រីកាន់តែច្រើនដែលកំណត់អត្តសញ្ញាណរបស់ខ្លួន និងលើកឡើងនូវបញ្ហាដែលជាកង្វល់ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំគោលនយោបាយនិងកម្មវិធីផ្សេងៗ។

២ខ- ចំនួនស្ត្រីដែលងាយប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចូលរួមកាន់តែច្រើនឡើងក្នុងសកម្មភាពបង្កើនប្រាក់ចំណូល។

២គ- ស្ត្រីដែលមានហានិភ័យមានប្រាក់ចំណូលកើនឡើង និងលទ្ធភាពទទួលបានដើមទុន។

២ឃ- ស្ត្រីដែលមានហានិភ័យ មានភាពអង់អាចក្នុងការធ្វើសេចក្តីសម្រេចចិត្តលើប្រាក់ចំណូលដែលពួកគេរកបាន(CDHS)។

២.១- ការពង្រឹងសមត្ថភាពដឹកនាំរបស់ស្ត្រីដើម្បីចូលរួមក្នុងវិធានការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រជាពិសេសស្ត្រីមកពីក្រុមអត្តសញ្ញាណចម្រុះ។	ក- ចំនួននិងប្រភេទវិធានការទប់ស្កាត់ ដែលនិយាយអំពីនិយាមសង្គមដែលបង្កគ្រោះថ្នាក់ រួមទាំងក្រុមស្ត្រីដែលមានសាវតារអត្តសញ្ញាណចម្រុះ។ ខ- ចំនួនអនុសាសន៍ដែលផ្តោតអាទិភាពលើអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដែលមានសាវតារចម្រុះ។ ទិន្នន័យដើមគ្រា : ១ ចំណុចដៅ : ៤	**ក-** ពង្រឹកការអភិវឌ្ឍសមត្ថភាពសម្រាប់ស្ត្រីដែលមានសាវតារចម្រុះ ស្តីពីជំនាញដឹកនាំការអនុវត្តល្អក្នុងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការស្វែងរកការគាំទ្រមតិ។ **ខ-** គាំទ្រដល់ការរៀបចំកិច្ចសន្ទនានាសម្រាប់ស្ត្រីដែលមានសាវតារអត្តសញ្ញាណចម្រុះ ដើម្បីលើកឡើងពីអនុសាសន៍ដែលបានកំណត់ស្តីពីការដោះស្រាយនិយាមសង្គមនិងយេនឌ័រ ដែលបង្កគ្រោះថ្នាក់និងសមភាពយេនឌ័រ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ធ.ស. • អ.យ.ក. • ក្រុមស្ត្រី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

២.២- ពលករទេសន្តរប្រវេសន៍ជាស្ត្រី យុវជន និងក្រុមស្ត្រីដទៃទៀត បានពង្រឹងបណ្តាញគាំទ្រ តាមរយៈការពង្រឹងទំនាក់ទំនង ទីភ្នាក់ងារ និងភាពធន់ ដើម្បីជួយគ្នាទៅវិញទៅមក និងសម្រេចបានសិទ្ធិរបស់ពួកគេ។	ក- ចំនួនបណ្តាញគាំទ្រមិត្តភក្តិដែលបានបង្កើតនិងប្រតិបត្តិការ។ ខ- ចំនួនកិច្ចសន្ទនាអំពីយេនឌ័រដែលផ្តោតលើពលករទេសន្តរប្រវេសន៍ជាស្ត្រី។ ទិន្នន័យដើមគ្រា : ១ ចំណុចដៅ : ៥ ក្រុមប្តី/កិច្ចសន្ទនា គ- កំណើននៃបណ្តាញគាំទ្រមិត្តក្នុងសង្គមដើម្បីគាំទ្រការបញ្ជូនករណីអំពីហិង្សាលើស្ត្រី និងការគាំទ្រសម្រាប់អំពើហិង្សាលើស្ត្រីដែលផ្តល់ដោយសមាជិកបណ្តាញគាំទ្រមិត្ត ឬ Gender Café។	**ក-** ពង្រឹកការប្រើប្រាស់គំរូបណ្តាញមិត្តគាំទ្រមិត្តដើម្បីជំរុញការចូលរួមរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី យុវជន និងក្រុមស្ត្រីផ្សេងទៀតដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ **ខ-** ពង្រឹកការប្រើប្រាស់គំរូកិច្ចសន្ទនាអំពីយេនឌ័រដល់ពលករទេសន្តរប្រវេសន៍ជាស្ត្រី។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ប • ក្រុមស្ត្រី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

២.៣-ជម្រើសកាន់តែច្រើនសម្រាប់ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីដែលត្រូវបានអនុវត្តសម្រាប់ស្ត្រីដែលប្រឈមនឹងហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនកម្មវិធីថ្មីៗ ដើម្បីពង្រឹងការបង្កើតប្រាក់ចំណូលសម្រាប់ស្ត្រីដែលស្ថិតក្នុងក្រុមដែលមានហានិភ័យ។ ខ- ចំនួនកម្មវិធីថ្មីៗសម្រាប់បណ្តុះបណ្តាលជំនាញការងារ ការគាំទ្រ និងការស្វែងរកការងារដល់ក្រុមស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ឬក្រុមស្ត្រីដែលមានហានិភ័យ និងក្រុមស្ត្រីផ្សេងទៀត។	**ក**- អនុវត្តកម្មវិធីដូចជាការបណ្តុះបណ្តាលជំនាញផ្សេងៗ និងជួយរកការងារសម្រាប់ក្រុមស្ត្រីដែលរងគ្រោះដោយអំពើហិង្សា និងក្រុមស្ត្រីដែលងាយរងគ្រោះ រួមមានក្រុមស្ត្រីដែលមានសាវតារអត្តសញ្ញាណចម្រុះ។ **ខ**- បង្កើនលទ្ធភាពទទួលបានដើមទុន ក្នុងគោលបំណងធ្វើអាជីវកម្មប្រកបដោយបរិយាបន្នសម្រាប់ក្រុមស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ក្រុមស្ត្រីដែលមានហានិភ័យ រួមទាំងក្រុមស្ត្រីដែលមានអត្តសញ្ញាណចម្រុះ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ប • ក.អ.ជ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល • វិស័យឯកជន	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : ការអប់រំនិងយុវជន

លទ្ធផលទី៣ : យុវជននិងមនុស្សវ័យជំទង់កាន់តែមានចំណេះដឹងនិងជំនាញក្នុងការលើកកម្ពស់និងកសាងទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រនិងអហិង្សា ដើម្បីផ្លាស់ប្តូរឥរិយាបថ អាកប្បកិរិយា និងការអនុវត្តដោយគោរពសិទ្ធិមនុស្ស (រួមមានសិទ្ធិសុខភាពផ្លូវភេទ សិទ្ធិសុខភាពបន្តពូជ សមភាពយេនឌ័រ និងទំនាក់ទំនងផ្លូវភេទ)។

សូចនាករលទ្ធផលនិងដំណើរការ៖

៣ក- សមាមាត្រនៃមនុស្សវ័យជំទង់ និងបុរសនិងស្ត្រីវ័យក្មេងដែលមិនយល់ស្របថា អំពើហិង្សាលើស្ត្រីគឺមានភាពយុត្តិធម៌ក្នុងគ្រប់កាលៈទេសៈ (CDHS)។

៣ខ- សមាមាត្រនៃមនុស្សវ័យជំទង់ និងបុរសនិងស្ត្រីវ័យក្មេងដែលរាយការណ៍អំពីការប្រើប្រាស់ការអនុវត្តអហិង្សាបែបវិជ្ជមាននៅក្នុងទំនាក់ទំនងជាមួយមិត្តភក្តិ និងដៃគូស៊ីឧស្សាអារម្មណ៍ពួកគេ។

៣គ- កម្មវិធីស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់ ត្រូវបានរៀបចំឡើងនិងអនុវត្ត។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៣.១- កិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ ត្រូវបានអនុវត្តលើក្រុមបុរសនិងក្រុមយុវជន នៅក្នុងនិងក្រៅសាលារៀន។	ក- ចំនួនខេត្តគោលដៅដែលអនុវត្តកញ្ចប់ឧបករណ៍អប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយឬឧបករណ៍អប់រំសុខភាពបន្តពូជ ដែលលើកឡើងពីសិទ្ធិផ្លូវភេទ សមភាពយេនឌ័រ និងឥរិយាបថផ្លូវភេទទំនាក់ទំនងប្រកបដោយភាពសុខដុមរមនា និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ល។ ចំណុចដៅ : ៥ ខេត្តថ្មី ប្រភពព័ត៌មាន : របាយការណ៍តាមកាលកំណត់	**ក-** ពង្រីកការអនុវត្តកញ្ចប់ឧបករណ៍អប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយទៅកាន់សាលារៀន និងសហគមន៍គោលដៅ ដើម្បីផ្សព្វផ្សាយដល់យុវជនទាំងក្នុងនិងក្រៅសាលារៀន(មិត្តអប់រំមិត្ត)។ ខ- ផ្តល់វគ្គបណ្តុះបណ្តាលអំពីឧបករណ៍អប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយតាមអនឡាញ។ គ- បង្កើតក្រុមមិត្តអប់រំមិត្តដែលត្រូវបានបណ្តុះបណ្តាលស្តីពីឧបករណ៍អប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយនៅតាមសាលារៀន និងគោលដៅសាធារណៈ(ក្រុមប្រឹក្សាកុមារយុវជន)។ ឃ- អនុវត្តការអប់រំវិន័យបែបវិជ្ជមាននៅតាមសាលារៀន។ ង- គាំទ្រការអភិវឌ្ឍប្រព័ន្ធកិច្ចការពារកុមារនៅតាមសាលារៀន និងគោលដៅទីសាធារណៈ។	**ស្ថាប័នដឹកនាំ៖** • អ.យ.ក. **ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • ក.ស.ប. • ក.ព.ម. • គណៈកម្មាធិការសុខភាពសិក្សា • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល • សាលារៀន	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

៣.២-សហគមន៍ដែលមានអត្រាខ្ពស់នៃអាពាហ៍ពិពាហ៍វ័យក្មេង បង្ហាញការយល់ដឹងកាន់តែច្រើនអំពីគ្រោះថ្នាក់នៃការអនុវត្តបែបនេះ និងបង្ហាញការទទួលយកកាន់តែខ្លាំងនូវកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង ។	ក- ចំនួនសកម្មភាពដើម្បីគាំទ្រការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង ។ ទិន្នន័យដើមគ្រា : ១ ខេត្ត ចំណុចដៅ : ៥ ខេត្តថ្មី ជាមួយនឹងសកម្មភាពប្រឆាំងនឹងអាពាហ៍ពិពាហ៍នៅវ័យក្មេង នៅតាមសហគមន៍។ ប្រភពព័ត៌មាន : របាយការណ៍តាមកាលកំណត់	ក- រៀបចំនិងអនុវត្តវិធានការនានា (យុទ្ធនាការ កិច្ចសន្ទនា វគ្គបណ្តុះបណ្តាល។ល។) ដោយផ្អែកលើការស្រាវជ្រាវស្តីពីផលប៉ះពាល់ផ្លូវកាយ ផ្លូវចិត្ត និងសុខភាពផ្លូវភេទ ព្រមទាំងផ្នែកសេដ្ឋកិច្ច) ដែលអាចបង្កគ្រោះថ្នាក់ដោយសារការរៀបអាពាហ៍ពិពាហ៍វ័យក្មេង ដោយផ្តោតគោលដៅលើក្រុមមានហានិភ័យ។ ខ- ចងក្រងនិងអនុវត្តគំរូមិត្តអប់រំមិត្តតាមសហគមន៍និងក្នុងសាលារៀនដើម្បីកសាងការយល់ដឹងរបស់យុវជនស្តីពីផលអន្តរាយនៃអាពាហ៍ពិពាហ៍វ័យក្មេង ។ គ- គាំទ្រសហគមន៍(ឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន យុវជន និងអ្នកផ្តល់សេវា) ឱ្យចាត់វិធានការដើម្បីលុបបំបាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង។	**ស្ថាប័នដឹកនាំ៖** • ស.អ.យ. • អ.យ.ក. • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • ក.ស.ប. • ក.ព.ម. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល • រដ្ឋបាលថ្នាក់ក្រោមជាតិ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : គ្រួសារនិងកូនៗ

លទ្ធផលទី៤ : បង្កើតកម្មវិធីពុកម៉ែល្អ កូនល្អ និងអ្នកម្តាយឆ្នើម តាមរយៈពង្រឹងចំណេះដឹង ការយល់ដឹង និងជំនាញការចិញ្ចឹមកូនបែបវិជ្ជមានរបស់ឪពុក ម្តាយ អាណាព្យាបាល និងអ្នកថែទាំ ដើម្បីកសាងគ្រួសារនិងបរិយាកាសប្រកបដោយសុវត្ថិភាព សមភាពយេនឌ័រ និងអហិង្សា មានភាពល្អប្រសើរឡើង។

សូចនាករលទ្ធផលនិងដំណើរការ៖

៤ក- សមាមាត្រនៃការថយចុះចំនួនស្ត្រីមានអាយុចាប់ពី១៥ឆ្នាំឡើងទៅដែលរាយការណ៍ពីភាពរងគ្រោះដោយអាកប្បកិរិយាត្រួតត្រា។

៤ខ- សមាមាត្រនៃចំនួនប្រជាជនដែលមានមាត្រដ្ឋានអាកប្បកិរិយាវិសមភាពយេនឌ័រ(CDHS Gender Attitudes Scale)។

៤គ- សមាមាត្រនៃកុមារអាយុពី១-១៧ឆ្នាំ ដែលបានរងគ្រោះដោយការដាក់ទណ្ឌកម្មខាងរាងកាយ ឬការឈ្លានពានខាងផ្លូវចិត្តដោយអ្នកថែទាំកាលពីខែមុន(SDG 16.2.1)។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៤.១- យុទ្ធសាស្ត្រនិងឧបករណ៍ទាក់ទងនឹងកម្មវិធីពុកម៉ែល្អ កូនល្អ និងអ្នកម្តាយឆ្នើម តាមរយៈការចិញ្ចឹមកូនបែបវិជ្ជមាន ត្រូវបានអនុវត្ត ដោយមានបុរសកាន់តែច្រើនចូលរួមអនុវត្ត។	ក- ការអនុវត្តកម្មវិធី ពុកម៉ែល្អ កូនល្អ និងអ្នកម្តាយឆ្នើម ត្រូវបានអនុវត្តនិងត្រូវពង្រីក។ ទិន្នន័យដើមគ្រា : ១២ភាគរយនៃការកើនឡើងចំនួនបុរសដែលចូលរួមក្នុងកម្មវិធីពុកម៉ែល្អ កូនល្អ និងអ្នកម្តាយឆ្នើម។	ក- ធ្វើបច្ចុប្បន្នកម្មវិធីសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន និងកញ្ចប់ឧបករណ៍ជាមួយនឹងវីដេអូខ្លីៗសម្រាប់ប្រើប្រាស់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ ខ- ពង្រីកការអនុវត្តកញ្ចប់ឧបករណ៍ទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមានទៅកាន់គោលដៅថ្មី។ គ- បង្កើតយុទ្ធសាស្ត្រដែលមានការចូលរួមពីបុរស ដើម្បីអនុវត្តកញ្ចប់ឧបករណ៍ទាក់ទង	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ស.អ.យ. **ស្ថាប័នដៃគូចូលរួម៖** • អ.យ.ក. • ក.ប.ទ. • ក.ម.ផ. • ក.ស.ប. • ក.ធ.ស. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		នឹងកម្មវិធីពុកម៉ែល្អ កូនល្អនិង អ្នកម្តាយឆ្នើម តាមរយៈការ ចិញ្ចឹមកូនបែបវិជ្ជមាន។								
៤.២- កិច្ចអន្តរាគមន៍ ដើម្បីលើកកម្ពស់ភាព អង់អាចដល់ស្ត្រីសម្រាប់ទំនាក់ទំនង ប្រកបដោយសមធម៌យេនឌ័រសម្រាប់ គូស្វាមីភរិយា ត្រូវបានរំលេចនៅកម្មវិធី ផ្សេងៗ ដូចជា ផែនការគ្រួសារ និងការ ប្រឹក្សាយោបល់សម្រាប់គូស្វាមីភរិយា គូស្នេហ៍មុនពេលរៀបការ និងដៃគូ ស្និទ្ធស្នាល។	ក- ចំនួនកម្មវិធីដែលបានបញ្ចូលនូវ ការផ្តល់ភាពអង់អាចដល់ស្ត្រី។ ចំណុចដៅ : កម្មវិធី/វិស័យថ្មី ឬ អន្តរាគមន៍**ចំនួន៣**ដែលរួមបញ្ចូល គោលការណ៍ពង្រឹងអំណាច	ក- ផ្តល់ការគាំទ្រនិងកិច្ច អន្តរាគមន៍នានាដល់ប្តីប្រពន្ធ ដើម្បីធ្វើឱ្យប្រសើរឡើងនូវ ជំនាញក្នុងការដោះស្រាយ បញ្ហាដោយការប្រាស្រ័យ ទាក់ទងបែបអហិង្សា ការ ដោះស្រាយវិវាទ និងបំណិន ជីវិតដែលធ្វើឱ្យពួកគេលើក កម្ពស់ទំនាក់ទំនងប្រកប ដោយសមធម៌យេនឌ័រ ការ គោរពគ្នាដោយអហិង្សា និង មានភាពសុខដុមរមនា ព្រមទាំងចេះគាំទ្រការងារ ទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ខ- អនុវត្តកម្មវិធីលើកកម្ពស់សុខ ភាព និងកម្មវិធីហិរញ្ញវត្ថុ និង កម្មវិធីគាំទ្រផ្សេងៗទៀត សម្រាប់ស្ត្រីនៅកម្ពុជា។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ធ.ស. (អ្នកដឹកនាំ សាសនា) • កម្មវិធីជំនួយសង្គម ក្រោម ស.អ.យ. និង សហវ **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ស.ប. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : សហគមន៍និងកន្លែងធ្វើការ

លទ្ធផលទី៥ : បរិយាកាសកន្លែងធ្វើការនិងសហគមន៍ មានភាពរាក់ទាក់និងសុវត្ថិភាពចៀសផុតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនគ្រប់រូបភាព។

សូចនាករលទ្ធផលនិងដំណើរការ៖

៥ក- សមាមាត្រនៃចំនួនសមាជិកសហគមន៍ឬនិយោជិតនៅកន្លែងធ្វើការគោលដៅ ដែលមិនយល់ស្របថា អំពើហិង្សាលើស្ត្រី គឺជារឿងត្រឹមត្រូវគ្រប់កាលៈទេសៈ។

៥ខ- សមាមាត្រនៃចំនួនបុគ្គលិកឬសមាជិកសហគមន៍ដែលបានរាយការណ៍ពីបទពិសោធនៃភាពរងគ្រោះដោយការបៀតបៀនផ្លូវភេទពីនរណាម្នាក់ដែលមិនមែនជាដៃគូស្និទ្ធស្នាលរបស់ពួកគេក្នុងរយៈពេល១២ខែចុងក្រោយនេះ។

៥គ- សមាមាត្រនៃចំនួនបុគ្គលិកឬសមាជិកសហគមន៍ដែលរាយការណ៍ពីបទពិសោធនៃភាពរងគ្រោះដោយការរំលោភបំពានពាក្យសម្តីពីនរណាម្នាក់ដែលមិនមែនជាដៃគូស្និទ្ធស្នាលរបស់ពួកគេក្នុងរយៈពេល១២ខែចុងក្រោយនេះ។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៥.១- សមាជិកសហគមន៍ត្រូវបានកៀរគរតាមរយៈគំរូថ្មី ដែលជំរុញការចូលរួមពីស្ត្រី បុរស និងអ្នកដឹកនាំសហគមន៍ក្នុងវិធានការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនវិធានការដែលសហគមន៍ប្រឆាំងនឹងអំពើហិង្សា ទាក់ទងនឹងយេនឌ័រ តាមរយៈគំរូនៃការកៀរគរការចូលរួមពីសហគមន៍។ ទិន្នន័យដើមគ្រា : គំរូថ្មីចំនួន៥ ចំណុចដៅ : ១៦៥៥ឃុំ សង្កាត់	ក- កំណត់និងបង្កើតគំរូកៀរគរការចូលរួមពីសហគមន៍ ដើម្បីអនុវត្តផ្អែកលើកស្តុតាងស្តីពីវិធានការដែលមានប្រសិទ្ធភាពនិងរួមបញ្ចូលទាំងក្រុមស្ត្រី និងក្មេងស្រីដែលមានសាវតារអត្តសញ្ញាណចម្រុះ។ ខ- ផ្តល់ការគាំទ្របច្ចេកទេសជាបន្តបន្ទាប់ ដើម្បីអនុវត្តគំរូនោះដោយមានបញ្ចូលនូវផែនការសកម្មភាពផងដែរ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • រដ្ឋបាលថ្នាក់ក្រោមជាតិ **ស្ថាប័នដៃគូចូលរួម៖** • ក.ទ.ច • ក.ម.ផ. • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

៥.២- ក្រសួង ស្ថាប័នរដ្ឋាភិបាល សមាគមន៍ សហគ្រាសក្រុមហ៊ុន រោងចក្រ និយោជក សហជីព អនុវត្តគោលនយោបាយ ពិធីសារ និងយន្តការដែលបានព្រមព្រៀងគ្នាពាក់ព័ន្ធនឹងកម្មវិធី កន្លែងធ្វើការមានសុវត្ថិភាពនិងសុខភាពការងារ និងគ្មានអំពើហិង្សា។	ក- ការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងយន្តការបណ្តឹងផ្សេងៗ។ ទិន្នន័យដើមគ្រា : ៥៤ ចំណុចដៅ : កន្លែងធ្វើការថ្មីចំនួន ១០	ក- បន្តជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តស្តីពី សុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងប្រឆាំងនឹងអំពើហិង្សានៅកន្លែងធ្វើការ ដោយមានការចូលរួមពីវិស័យឯកជន។ ខ- បន្តអនុវត្តយន្តការទទួលពាក្យបណ្តឹងនិងផ្តល់ការគាំទ្រវត្តបណ្តុះបណ្តាលដើម្បីអនុវត្ត។ គ- បន្តការផ្សព្វផ្សាយសកម្មភាពសុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងការបញ្ឈប់អំពើហិង្សានៅកន្លែងការងារ។	**ស្ថាប័នដឹកនាំ៖** • ក.ប **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • ដៃគូអភិវឌ្ឍ • វិស័យឯកជន • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
៥.៣- គំរូវិធីសាស្ត្រការងារនគរបាលនិងសហគមន៍ ត្រូវបានអនុវត្តដើម្បីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនឃុំ/សង្កាត់ ដែលអនុវត្តការងារនគរបាលនិងសហគមន៍ដើម្បីបង្ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១	ក- កម្មវិធីពង្រឹងសមត្ថភាពស្តីពីវិធីសាស្ត្រការអនុវត្តការងារនគរបាលនិងសហគមន៍ដល់មន្ត្រីនគរបាលបុស្តិ៍រដ្ឋបាលដើម្បីអនុវត្តការងារនគរបាលនិងសហគមន៍ក្នុងការបង្ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។	**ស្ថាប័នដឹកនាំ៖** • នគរបាលជាតិ • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

៥.៤- អ្នកផ្តល់សេវាសាធារណៈ និងសង្គមស៊ីវិល រួមទាំងក្រុមស្ត្រី ក្រុមនិយោជិត ក្រុមសាសនា និងអ្នកស្ម័គ្រចិត្ត ត្រូវបានកៀរគរនិងផ្តល់ធនធាន ដើម្បីដឹកនាំសកម្មភាពបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដើម្បីឆ្លើយតបនឹងនិយាមសង្គមដែលបង្កគ្រោះថ្នាក់ក្នុងសហគមន៍។	ក- ចំនួនក្រុមថ្មីដែលអនុវត្តសកម្មភាពសហគមន៍ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីដែលកំពុងប្រឈមនឹងនិយាមសង្គមដែលបង្កគ្រោះថ្នាក់និងរួមទាំងក្រុមស្ត្រីដែលមានសាវតាអត្តសញ្ញាណចម្រុះ។	ក- រៀបចំនិងអនុវត្តកម្មវិធីនានាដែលលើកកម្ពស់ភាពជាបុរសល្អ ដូចជាការសន្ទនា ការតាំងពិព័រណ៍សិល្បៈ និងសកម្មភាពផ្សេងៗទៀត។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • វិស័យឯកជន • អង្គការសង្គមស៊ីវិល • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
៥.៥- ស្ត្រីពលករទេសន្តរប្រវេសន៍មានការយល់ដឹងអំពីសិទ្ធិរបស់ខ្លួននិងការពារមិនឱ្យមានអំពើហិង្សាលើស្ត្រីនៅក្នុងវដ្តនៃការធ្វើទេសន្តរប្រវេសន៍។	ក- ក្រុមមិត្តអប់រំមិត្ត ពលករទេសន្តរប្រវេសន៍ជាស្ត្រីដែលបង្កើនការយល់ដឹងអំពីសិទ្ធិនិងចំណេះដឹងរបស់ពួកគេអំពីសេវាឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ៥	ក- ផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិដល់ស្ត្រីដែលកំពុងធ្វើការដើម្បីបង្កើនការយល់ដឹងអំពីកិច្ចការពារផ្សេងៗ ដោយផ្តោតជាពិសេសលើស្ត្រីពលករទេសន្តរប្រវេសន៍ក្នុងប្រទេសនិងក្រៅប្រទេសនៅថ្នាក់ក្រោមជាតិ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ប • ក.ម.ផ. • វិស័យឯកជន • អង្គការសង្គមស៊ីវិល • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : វប្បធម៌និងប្រព័ន្ធផ្សព្វផ្សាយ

លទ្ធផលទី**៦** : ការលើកកម្ពស់សមភាពយេនឌ័រ និយាមសង្គម និងសារអប់រំបែបអហិង្សាតាមរយៈប្រព័ន្ធផ្សព្វផ្សាយ រួមទាំងបណ្តាញផ្សព្វផ្សាយសង្គម។

សូចនាករលទ្ធផលនិងដំណើរការ៖

៦ក- ភាគរយនៃក្រុមគោលដៅចូលរួមយុទ្ធនាការផ្សព្វផ្សាយដែលបានបង្ហាញពីការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានចំពោះអំពើហិង្សាលើស្ត្រី។

៦ខ- ពាក្យសម្តីមិនសមរម្យ ឬពាក្យសម្តីដែលមានលក្ខណៈវិសមភាពយេនឌ័រ និងការរើសអើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាពត្រូវបានកាត់បន្ថយ។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៦.១- អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយបានបង្កើនសមត្ថភាពក្នុងការរាយការណ៍ករណីអំពើហិង្សាលើស្ត្រី ស្របតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី។	ក- ចំនួនរបាយការណ៍ត្រួតពិនិត្យលើការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ២ ខ- ការថយចុះចំនួនអត្ថបទ និងករណីនៃការរាយការណ៍ព័ត៌មានមិនត្រឹមត្រូវ និងគ្មានក្រមសីលធម៌ស្តីពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ឧបករណ៍តាមដាននិងនីតិវិធីសម្រាប់តាមដានការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រីត្រូវបានរៀបចំនិងអនុវត្តដោយមានជាយន្តការសម្រាប់ការរាយការណ៍ប្រចាំឆ្នាំ និងយន្តការផ្តល់មតិត្រឡប់។ ខ- ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់អ្នកសារព័ត៌មាន និងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី។	**ស្ថាប័នដឹកនាំ៖** • ក.ព.ម. **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • វិស័យឯកជន • សមាគមពាក់ព័ន្ធ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		គ- ផ្តល់ការអភិវឌ្ឍសមត្ថភាពស្តីពីច្បាប់ស្តីពីរបបសារព័ត៌មាននិងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។								
៦.២- យុទ្ធសាស្ត្រនិងយុទ្ធនាការបង្ការទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានអំពីអំពើហិង្សា និងការប្រាស្រ័យទាក់ទងត្រូវបានរៀបចំនិងអនុវត្ត។	ក- យុទ្ធសាស្ត្រការប្រាស្រ័យទាក់ទងត្រូវបានបង្កើតនិងអនុវត្ត។ ទិន្នន័យដើមគ្រា : ០ ចំណុចដ : ៥	ក- រៀបចំយុទ្ធសាស្ត្រ ដោយមានភ្ជាប់ជាមួយនឹងសារបង្ការទប់ស្កាត់អំពើហិង្សា និងយុទ្ធសាស្ត្រសម្រាប់អនុវត្តកម្មវិធី។	**ស្ថាប័នដឹកនាំ៖** • ក.ព.ម. • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.វ.វ.ស. • ក.ប.ទ. • ក.ម.ផ. • ក.ទ.ច.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ **គោលបំណង** : បង្កើនការផ្តល់សេវានិងការឆ្លើយតបប្រកបដោយគុណភាព ដែលសមស្របចំពោះតម្រូវការផ្សេងៗគ្នារបស់ស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សា										
យុទ្ធសាស្ត្រគន្លឹះ : ការសម្របសម្រួលជាពហុវិស័យ និងគុណភាពនៃសេវាចាំបាច់ លទ្ធផលទី៧ : ការសម្របសម្រួលនិងភ្ជាប់ទំនាក់ទំនងរវាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ អ្នកផ្តល់សេវា និងសង្គមស៊ីវិលនៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើន។ **សូចនាករលទ្ធផលនិងដំណើរការ៖** ៧ក- ក្រសួង ស្ថាប័ន អ្នកផ្តល់សេវា និងសង្គមស៊ីវិល បង្កើនការផ្តល់និងចែករំលែកព័ត៌មានអំពីទិន្នន័យ ការរាយការណ៍នានា និងបញ្ជូនស្ត្រីរងគ្រោះដោយអំពើហិង្សាទៅការសេវាចាំបាច់នានាបានល្អប្រសើរជាងមុន(ទិន្នន័យរដ្ឋបាល)។									

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៧.១- ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានពង្រឹងនិងបានដំណើរការប្រកបដោយប្រសិទ្ធភាព។	ក- ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័ររៀបចំកិច្ចប្រជុំទៀងទាត់ស្របតាមតួនាទីនិងភារកិច្ចដែលបានធ្វើបច្ចុប្បន្នកម្ម។ ចំណុចដៅ : ចំនួនកិច្ចប្រជុំទៀងទាត់៣-៤ដងក្នុងមួយឆ្នាំ។ ខ- ការកើនឡើងនៃចំនួនផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ដែលបញ្ចប់ដោយសមាជិកក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទិន្នន័យដើមគ្រា : ៥ផែនការប្រតិបត្តិប្រចាំឆ្នាំ ០របាយការណ៍ប្រចាំឆ្នាំ(ពាក់ព័ន្ធនឹងលទ្ធផលគន្លឹះ១៤.១-)។	ក- ពិនិត្យមើលនិងធ្វើបច្ចុប្បន្នកម្មលើសេចក្តីសម្រេចតួនាទីនិងភារកិច្ច ដោយបញ្ចូលតួនាទីនិងភារកិច្ច ការទទួលខុសត្រូវនិងសមាជិកភាពនៃក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយផ្អែកលើការវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣។ ខ- ក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមដានអំពីវឌ្ឍនភាព បញ្ហាប្រឈម និងកំណត់រកដំណោះស្រាយក្នុងការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ ដោយប្រើប្រាស់ក្របខ័ណ្ឌ ផែនការប្រតិបត្តិ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក្រសួង ស្ថាប័នពាក់ព័ន្ធ • ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	ចំណុចដៅ : ១០ផែនការប្រតិបត្តិប្រចាំឆ្នាំ ៥របាយការណ៍ប្រចាំឆ្នាំដែលបានបូកសរុបចេញពី១០ផែនការប្រតិបត្តិប្រចាំឆ្នាំ។ គ- ចំនួនវិធានការដែលបានអនុវត្តដើម្បីកែលម្អការអនុវត្តផែនការសកម្មភាពជាតិ ដោយផ្អែកលើការវិភាគរបាយការណ៍ប្រចាំឆ្នាំ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ៥	ប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។							
៧.២- ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលជាយន្តការសម្របសម្រួលជាពហុវិស័យក្នុងការដឹកនាំការសម្របសម្រួលសេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រសំខាន់ៗនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ត្រូវបានពង្រីកនិងបានដំណើរការប្រកបដោយប្រសិទ្ធភាព។	ក- កិច្ចប្រជុំទៀងទាត់របស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ(៤ដង/១ឆ្នាំ) ក្នុងខេត្តចំនួន១០ដែលជាក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រមានស្រាប់ និងខេត្តចំនួន៥ដែលទើបបង្កើតពង្រីកក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្មី ស្របតាមតួនាទីនិងភារកិច្ច និង	ក- ធ្វើបច្ចុប្បន្នកម្មលើសេចក្តីសម្រេចស្តីពីតួនាទីនិងភារកិច្ចរបស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ដោយធានាឱ្យមានការផ្តោតការយកចិត្តទុកដាក់លើការសម្របសម្រួល និងពង្រឹងការឆ្លើយតបស្របតាមបទដ្ឋានអប្បបរមានៃការផ្តល់សេវា។ ខ- ពង្រីកក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សា	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ម.ផ. • រដ្ឋបាលថ្នាក់ក្រោមជាតិ **ស្ថាប័នដៃគូចូលរួម៖** • ក្រសួង ស្ថាប័នពាក់ព័ន្ធ • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ • ថវិកាថ្នាក់ខេត្ត ស្រុក ឃុំ។

	បទដ្ឋានអប្បបរមានៃសេវាសំខាន់ៗនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ដែលបានធ្វើបច្ចុប្បន្នកម្មចុងក្រោយ ដោយមានសមាជិក៧០%ចូលរួម។ ចំណុចដៅ : ៧០% ៣ដង/១ឆ្នាំ សម្រាប់ខេត្តចំនួន១៥។ ប្រភពព័ត៌មាន : របាយការណ៍តាមកាលកំណត់។ ខ- ចំនួនក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្មីដែលត្រូវបានបង្កើត។ ចំណុចដៅ : ១៥ ក្រុមថ្មី គ- ភាគរយនៃសមាជិកក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានបង្កើនចំណេះដឹងស្តីពីតួនាទីនិងភារកិច្ច នីតិវិធីប្រតិបត្តិស្តង់ដា និងបទដ្ឋាន និងគោលការណ៍ណែនាំសេវា។	ទាក់ទងនឹងយេនឌ័រនៅតាមខេត្តនិងស្រុកដែលមិនទាន់មានក្រុមការងារនេះ។ គ- រៀបចំសិក្ខាសាលាតម្រង់ទិសស្តីពីតួនាទីនិងភារកិច្ចក្នុងការទទួលខុសត្រូវរបស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។ ឃ- ផ្តល់ការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលរំលឹកស្តីពីបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗ និងធ្វើបច្ចុប្បន្នកម្ម(ច្បាប់ ការបញ្ជូនការពិគ្រោះយោបល់កម្រិតមូលដ្ឋាន) និងនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងករណីនៅតាមខេត្តគោលដៅ។ ង- ប្រជុំជាទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយក្នុងការផ្តល់សេវាដោយក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័ររៀងរាល់៣ខែ។							

		ច- ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធអំពីការរៀបចំក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័ររវាងខេត្តនិងខេត្ត ស្រុកនិងស្រុក ឆ- ពិនិត្យតាមដានការអនុវត្តក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយប្រើប្រាស់ឧបករណ៍ : (១) ការបង្កើតនិងដាក់ឱ្យប្រើប្រាស់បទដ្ឋានសេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង(២) ការប្រមូលទិន្នន័យពីការឆ្លុះបញ្ចាំងដំណើរការរបស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ជ- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំដើម្បីវាយតម្លៃវឌ្ឍនភាព និងកំណត់រកផ្នែកដែលត្រូវកែលម្អ។								

៧.៣- អំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងការឆ្លើយតបក្នុងគ្រាមានអាសន្ន និងគ្រោះមហន្តរាយ។	ក- ចំនួនយន្តការឆ្លើយតបក្នុងគ្រាមានអាសន្នដែលបានដាក់បញ្ចូលអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ពង្រឹងសមត្ថភាពអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងក្រុមការងារឆ្លើយតបក្នុងគ្រាអាសន្នដែលស្ថិតក្រោមអង្គភាពនៃកិច្ចការពារដែលអាចធ្វើការងារក្នុងគ្រាអាសន្ន។ ខ- បញ្ចូលប្រធានបទអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងកម្មវិធីរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ គ- រៀបចំកិច្ចប្រជុំតាមកាលកំណត់របស់ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាមានអាសន្ន។ ឃ- ចែករំលែកបទពិសោធពីការអនុវត្តល្អក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាមានអាសន្ន។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • គ.ជ.ស.ម. • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
៧.៤- ពិធីសារសម្រាប់ការបញ្ជូនឆ្លងដែន ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីផ្តល់ការណែនាំដល់អ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការផ្តល់សេវាប្រកបដោយគុណភាពដល់ជនរង	ក- ចំនួននីតិវិធីប្រតិបត្តិស្តង់ដាឬពិធីសារសម្រាប់អ្នក ផ្តល់សេវាពាក់ព័ន្ធ ត្រូវបានបង្កើតនិងអនុវត្ត។	ក- បង្កើតពិធីសារនិងប្រព័ន្ធសម្រាប់ទំនាក់ទំនង និងការបញ្ជូនឆ្លងដែន ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗក្នុងការ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ស.អ.យ.	X	X					អង្គការដៃគូ

គ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រីនៅក្រៅប្រទេស ឬដែលបានធ្វើមាតុភូមិនិវត្តន៍។	ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១ ខ- ចំនួននៃការបញ្ជូនឆ្លងដែនស្របតាមស្តង់ដានៃការអនុវត្តល្អនៅថ្នាក់ជាតិ តំបន់ និងសកល។	ឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានការចូលរួមពីអ្នកផ្តល់សេវានិងអាជ្ញាធរពាក់ព័ន្ធ ដើម្បីឆ្លើយតបចំពោះពលករទេសន្តរប្រវេសន៍ជាស្ត្រី និងធានាការផ្តល់ជាតុចូលពីក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និងដៃគូយុទ្ធសាស្ត្រផ្សេងទៀត លើពិធីសារ ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសផ្សេងទៀតទាក់ទងនឹងពលករដែលធ្វើការនៅក្រៅប្រទេស។ ខ- ពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តពិធីសារឬអនុស្សរណៈនៃការយោគយល់គ្នា។	**ស្ថាប័នដៃគូចូលរួម៖** • ក.ប. • ក.ម.ផ. • កបទ.សអ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							
៧.៥- មន្ត្រីស្ថានទូត មន្ត្រីកុងស៊ុល និងអនុព័ន្ធការងារ ផ្តល់កិច្ចអន្តរាគមន៍ឆ្លើយតបនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។	ក- នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់មន្ត្រីស្ថានទូតកម្ពុជាត្រូវបានបង្កើតនិងអនុវត្តឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- រៀបចំនីតិវិធីប្រតិបត្តិស្តង់ដា ការគាំទ្របច្ចេកទេសនិងការបណ្តុះបណ្តាលសម្រាប់មន្ត្រីស្ថានទូតមន្ត្រីកុងស៊ុលអនុព័ន្ធការងារ និងអ្នកទទួលបន្ទុក	**ស្ថាប័នដឹកនាំ៖** • កបទ.សអ **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន.	X	X					អង្គការដៃគូ

	ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១ ខ- ចំណេះដឹងរបស់មន្ត្រីស្ថានទូត មន្ត្រីកុងស៊ុល អនុព័ន្ធការងារ អំពីវិធីសាស្ត្រនិងយន្តការក្នុងការជួយជនរងគ្រោះដោយអំពើហិង្សាមានការកើនឡើង។	ផ្តែកការងារឆ្លើយតបចំពោះស្ត្រីដែលរងគ្រោះដោយអំពើហិង្សា។ ខ- ដាក់បញ្ចូលគោលគំនិតអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជល់មន្ត្រីនៅវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ។ គ- អភិវឌ្ឍសមត្ថភាពមន្ត្រីស្ថានទូត មន្ត្រីកុងស៊ុល និងអនុព័ន្ធការងារ ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា និងការអនុវត្តល្អសម្រាប់ការ ឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	• ក.ម.ផ. • ក.ប • ដៃគូអភិវឌ្ឍ							
៧.៦- អ្នកផ្តល់សេវាបានកែលម្អការអនុវត្តរបស់ខ្លួនក្នុងការផ្តល់សេវាសំខាន់ៗដែលមានគុណភាពកាន់តែមានប្រសិទ្ធភាពស្របតាមបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗ រួមទាំងការផ្តល់សេវាដល់ក្រុមស្ត្រីដែលមានអត្តសញ្ញាណចម្រុះ។	ក- ចំនួនវគ្គបណ្តុះបណ្តាលអំពីកញ្ចប់សេវាចាំបាច់ដែលធ្វើបច្ចុប្បន្នកម្មរួមបញ្ចូលសមភាពយេនឌ័រ បរិយាបន្នពិការភាព និងសង្គម។ ចំណុចដៅ : ៤	ក- ធ្វើបច្ចុប្បន្នកម្មកញ្ចប់សេវាចាំបាច់ដើម្បីដោះស្រាយនិយាមសង្គមដែលបង្កគ្រោះថ្នាក់ និងលើកកម្ពស់សេវាមានសមភាពយេនឌ័រ បរិយាបន្នពិការភាព និងសង្គម។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ម.ផ. • ក.យ. • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	ខ- ចំនួនគ្រូបង្គោលដែលត្រូវបានបំប៉នសមត្ថភាព អំពីកញ្ចប់សេវាចាំបាច់ ដែលបានធ្វើបច្ចុប្បន្នកម្ម។ ទិន្នន័យដើមគ្រា : ៥ ចំណុចដៅ : ៣០	ខ- កំណត់ក្រុមគោលដៅដែលជាគ្រូបង្គោល(ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល) ដើម្បីពង្រឹងសមត្ថភាពអំពីកញ្ចប់សេវាចាំបាច់ ដែលបានធ្វើបច្ចុប្បន្នកម្ម។	អង្គការសង្គមស៊ីវិល							
	គ- ភាគរយស្ត្រីមកពីក្រុមចម្រុះអត្តសញ្ញាណដែលស្វែងរកសេវាបានកើនឡើង។	គ- កំណត់យុទ្ធសាស្ត្រនិងលុបបំបាត់ឧបសគ្គ ដូចជាភាសាឧបសគ្គរូបវន្តដែលរឹតត្បិតលទ្ធភាពទទួលបានសេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។								
	ឃ- ចំនួនបន្ទប់ប្រឹក្សាយោបល់ផ្លូវចិត្តសម្រាប់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាមករកសេវាពីអ្នកផ្តល់សេវា។ ទិន្នន័យដើមគ្នា : ១៩ ចំណុចដៅ : ៥០	ឃ- ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីអំពីការបង្កើតនិងការប្រើប្រាស់បន្ទប់ប្រឹក្សាយោបល់សម្រាប់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សានៅតាមមូលដ្ឋានផ្តល់សេវានានា។								

៧.៧- នគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារីអនុវត្តតួនាទី ដោយមានការណែនាំច្បាស់លាស់អំពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- សេចក្តីសម្រេចស្តីពីតួនាទីនិងភារកិច្ចសម្រាប់នគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី ដែលបានធ្វើបច្ចុប្បន្នកម្ម ត្រូវបានបង្កើតនិងអនុវត្ត។ ចំណុចដៅ : ១ ខ- នគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី កំពុងផ្តល់ការឆ្លើយតបប្រកបដោយគុណភាពនៅក្នុងតួនាទីរបស់ពួកគេ។	ក- ធ្វើបច្ចុប្បន្នកម្មតួនាទីនិងទំនួលខុសត្រូវរបស់នគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី ទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា មានតភ្ជាប់ទំនាក់ទំនងជាមួយនីតិវិធីប្រតិបត្តិស្តង់ដានៃការគ្រប់គ្រងករណី។ ខ- អភិវឌ្ឍសមត្ថភាពរបស់នគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី លើតួនាទីនិងការទទួលខុសត្រូវ និងជំនាញពាក់ព័ន្ធក្នុងការអនុវត្តបទដ្ឋានអប្បបរមានៃការផ្តល់សេវា។ (មានទំនាក់ទំនងទៅនឹងចំណុច ៧.២-)	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.យ. • ក.ម.ផ. • ស.អ.យ.	X	X					• ថវិការដ្ឋ • អង្គការដៃគូ

៧.៨- ក្រសួងកិច្ចការនារីបាននិងកំពុងអនុវត្តគួនាទីត្រួតពិនិត្យតាមដាន ដើម្បីជំរុញឱ្យមានការផ្តល់សេវាចាំបាច់ប្រកបដោយគុណភាពដល់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្របតាមបទដ្ឋានអប្បបរមានៃការផ្តល់សេវា និងធានាការរួមបញ្ចូលជាតុចូលពីជនរងគ្រោះ។	ក- ចំនួនរបាយការណ៍ចុះត្រួតពិនិត្យតាមដាន ដែលនាំឱ្យមានការកែលម្អគុណភាពនៃសេវា(អ្នកផ្តល់សេវាអនុវត្តការកែលម្អដោយផ្អែកលើអនុសាសន៍ត្រួតពិនិត្យតាមដាន)។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១៥	ក- ធ្វើបច្ចុប្បន្នកម្មបញ្ជីត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • ស.អ.យ. • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
	ខ- សេវាចាំបាច់សំខាន់ៗត្រូវបានពង្រឹងដោយផ្អែកលើធាតុចូលពីជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ចំណុចកែលម្អ ៥ ដោយផ្អែកលើយោបល់ត្រឡប់ពីជនរងគ្រោះ	ខ- ពង្រឹងសមត្ថភាពក្រុមការងារក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី អំពីបញ្ជីត្រួតពិនិត្យលើកញ្ចប់សេវាចាំបាច់ និងការអនុវត្តល្អបំផុតក្នុងការត្រួតពិនិត្យតាមដាន។							
	គ- ជនរងគ្រោះដែលស្វែងរកសេវាកាន់តែពេញចិត្តនឹងគុណភាពសេវា។	គ- តាមដានលើបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗដោយផ្តោតលើអ្នកផ្តល់សេវាជួរមុខតាមរយៈការប្រើប្រាស់បញ្ជីត្រួតពិនិត្យដែលពាក់ព័ន្ធ។							

		ឃ- ពិនិត្យតាមដានដោយប្រើប្រាស់ឧបករណ៍បញ្ជីត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយប្រើប្រាស់ឧបករណ៍ : (១) ការបង្កើតនិងដាក់ឱ្យប្រើប្រាស់បទដ្ឋានសេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង(២) ការប្រមូលទិន្នន័យពីការឆ្លុះបញ្ចាំងដំណើរការរបស់ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ។								
៧.៩- ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសមត្ថភាពក្នុងការរៀបចំថវិកា និងវិភាជថវិកាក្នុងការស្វែងរកមតិគាំទ្រដើម្បីបង្កើនកញ្ចប់ថវិកា។	ក- ក្រសួង ស្ថាប័នពាក់ព័ន្ធមានគម្រោងថវិកាច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ពង្រឹងសមត្ថភាពក្រសួងស្ថាប័នពាក់ព័ន្ធ ស្តីពីការរៀបចំថវិកាដែលឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ខ- ជំរុញការអនុវត្តយុទ្ធសាស្ត្រដើម្បីបង្កើនការផ្តល់ថវិកាប្រកបដោយចីរភាពសម្រាប់សេវាឆ្លើយតប។	**ស្ថាប័នដឹកនាំ៖** • ក.ស.ហ.វ • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក្រសួង ស្ថាប័ន នៃ TWGG-GBV	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : ការគ្រប់គ្រងករណីនិងប្រព័ន្ធទិន្នន័យរដ្ឋបាល

លទ្ធផលទី៨ : ការគ្រប់គ្រងករណី ការប្រមូល និងការរាយការណ៍ទិន្នន័យ ដែលផ្តោតលើជនរងគ្រោះ ត្រូវបានពង្រឹងនិងមានការសម្របសម្រួល។

សូចនាករលទ្ធផលនិងដំណើរការ៖

៨ក- សមាមាត្រស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាស្វែងរកសេវាគាំទ្រកើនឡើង។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
៨.១- ប្រព័ន្ធគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដើម្បីធានាវិធីសាស្ត្រដែលផ្តោតការយកចិត្តទុកដាក់ចំពោះជនរងគ្រោះនៅក្នុងដំណើរការទាំងមូល ស្របតាមនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងករណី។	ក- នីតិវិធីប្រតិបត្តិស្តង់ដាណែនាំការគ្រប់គ្រងករណីត្រូវបានបង្កើតឡើងនិងអនុវត្ត។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១ ខ- កំណើនភាគរយនៃជនរងគ្រោះដែលទទួលបានសេវាគ្រប់គ្រងករណីប្រកបដោយគុណភាពស្របតាមនីតិវិធីប្រតិបត្តិស្តង់ដា។ គ- កិច្ចប្រជុំតាមអ៊ីនធឺណិតស្តីពីករណី ត្រូវបានរៀបចំឡើងជាទៀងទាត់ ដោយមានការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវពីជនរងគ្រោះ។	ក- វាយតម្លៃលើការអនុវត្តបច្ចុប្បន្នក្នុងការគ្រប់គ្រងករណីដើម្បីយល់កាន់តែច្បាស់អំពីជាតុចូលសំខាន់ៗ ដើម្បីកែលម្អ រួមទាំងប្រព័ន្ធឌីជីថល ការភ្ជាប់ទំនាក់ទំនងរវាងវិស័យនានា ដូចជា កិច្ចការពារកុមារ សេវាសុខភាព និងច្បាប់ និងឯកជនភាព ការរក្សាការសម្ងាត់ និងការការពារទិន្នន័យ។ ខ- បង្កើតនិងអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងករណីដែលប្រមូលផ្តុំនិងកែលម្អដំណើរការក្នុងបទដ្ឋានអប្បបរមានៃការផ្តល់សេវា ដែលមានស្រាប់ និង	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		ជានាថា ការគ្រប់គ្រងករណីត្រូវបានអនុវត្តដោយប្រើប្រាស់វិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ គ- កំណត់ដំណើរការនៃការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាឱ្យបានច្បាស់សម្រាប់ការពិគ្រោះករណីជាមួយវិស័យផ្សេងទៀត សម្រាប់ការគ្រប់គ្រងករណីដែលរួមបញ្ចូលដំណើរការយល់ព្រមពីភាគីពាក់ព័ន្ធ។ ឃ- រៀបចំការណែនាំអំពីវិធីបញ្ជូនច្បាស់លាស់ដោយឆ្លើយតបទៅនឹងជនរងគ្រោះជាមនុស្សពេញវ័យនិងកុមារ។ ង- ផ្តល់ការអភិវឌ្ឍសមត្ថភាពរួមទាំងការបណ្តុះបណ្តាលការណែនាំ និងការហ្វឹកហ្វឺនដល់អ្នកគ្រប់គ្រងករណី និងភាគីពាក់ព័ន្ធស្តីពីរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការគ្រប់គ្រងករណី។								

៨.២- ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមអនុវត្តឆ្លើយតបចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមានការណែនាំច្បាស់លាស់ ស្របតាមបទដ្ឋានជាតិ។	ក- នីតិវិធីប្រតិបត្តិស្តង់ដាឬតួនាទីនិងការកិច្ចច្បាស់លាស់ដែលបានកំណត់អំពីតួនាទីរបស់ការិយាល័យសង្គមកិច្ចនិងសុខុមាល ភាពសង្គមក្នុងការឆ្លើយតបចំពោះករណី អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមានយន្តការបញ្ជូនច្បាស់លាស់ និងភ្ជាប់ទំនាក់ទំនងទៅនឹងការគ្រប់គ្រងករណី និងកិច្ចការពារកុមារ។ ចំណុចដៅ : ១ (អាចទាក់ទងនឹងចំណុច ៨.១-)	ក- នីតិវិធីប្រតិបត្តិស្តង់ដានិងសេចក្តីសម្រេចស្តីពីតួនាទី និងភារកិច្ចរបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធានាការបញ្ជាក់យ៉ាងច្បាស់អំពីតួនាទីនិងការទទួលខុសត្រូវក្នុងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងតួនាទីក្នុងការគ្រប់គ្រងករណី។ ខ- អភិវឌ្ឍសមត្ថភាពដល់មន្ត្រីការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើតួនាទីនិងភារកិច្ច ដែលបានព្រមព្រៀង រួមទាំងតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងករណី និងបទដ្ឋានអប្បបរមានៃការផ្តល់សេវា។	**ស្ថាប័នដឹកនាំ៖** • ក.ម.ផ. • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល		X	X				អង្គការដៃគូ
៨.៣- អាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានីខេត្ត កំពុងឆ្លើយតបនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយផ្អែកលើតួនាទីនិងភារកិច្ចច្បាស់លាស់ ឬនីតិវិធីប្រតិបត្តិស្តង់ដា។	ក- នីតិវិធីប្រតិបត្តិស្តង់ដាឬតួនាទីនិងការកិច្ចច្បាស់លាស់ដែលបានកំណត់អំពីតួនាទីរបស់ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមថ្នាក់ក្រុង	ក- ប៉ាន់ប្រមាណក្នុងការកំណត់ការអនុវត្តបច្ចុប្បន្ន និងណែនាំតួនាទីនិងការទទួលខុសត្រូវសម្រាប់អាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី	**ស្ថាប័នដឹកនាំ៖** • ក.ម.ផ. • ក.ក.ន.	X	X	X	X	X	X	• ប៉ារិការដ្ឋ • អង្គការដៃគូ

	ស្រុក ខណ្ឌ ក្នុងការឆ្លើយតបចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងវិធីបញ្ជូន និងភ្ជាប់ទំនាក់ទំនងទៅនឹងកិច្ចការពារកុមារ។ ចំណុចដៅ : ១ (ទាក់ទងនឹងចំណុច៨.១-)	ខេត្ត ក្នុងការឆ្លើយតបចំពោះអំពើហិង្សទាក់ទងនឹងយេនឌ័រ រួមទាំងវិធីបញ្ជូន។ ខ- រៀបចំគោលការណ៍ណែនាំទាក់ទងនឹងតួនាទីនិងការកិច្ចឬនីតិវិធីប្រតិបត្តិស្តង់ដា ដោយផ្អែកលើក្របខ័ណ្ឌច្បាប់ក្នុងប្រទេសកម្ពុជា និងការអនុវត្តល្អជាសកលស្របតាមនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការគ្រប់គ្រងករណីដើម្បីណែនាំដល់ការឆ្លើយតបរបស់ខ្លួន រួមទាំងវិធីបញ្ជូនច្បាស់លាស់។ គ- ពង្រឹងសមត្ថភាពរបស់អាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី និងខេត្តស្តីពីតួនាទីនិងការកិច្ចច្បាស់លាស់ឬនីតិវិធីប្រតិបត្តិស្តង់ដា។	**ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • ស.អ.យ. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							
៨.៤- ការប្រមូលទិន្នន័យរដ្ឋបាលសម្រាប់ការគ្រប់គ្រងករណីដំណើរការនៅថ្នាក់ជាតិ ដោយមានការធានាច្បាស់លាស់លើការការពារការសម្ងាត់របស់ជនរងគ្រោះ។	ក- របាយការណ៍តាមកាលកំណត់ទៀងទាត់អាចរកបានពីរបាយការណ៍ប្រព័ន្ធគ្រប់គ្រងករណី។	ក- អភិវឌ្ឍ/ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធប្រមូលទិន្នន័យរដ្ឋបាល រួមទាំងប្រព័ន្ធឌីជីថល ដែលមានការធានាលើការការពារទិន្នន័យ និងការរក្សាការសម្ងាត់។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • រដ្ឋបាលថ្នាក់	X	X	X	X	X	X	• ថ្នាក់ដឹក • អង្គការដៃគូ

	ខ- ចំនួនវិធានការដែលបានធ្វើឡើងដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានដល់វិធានការឆ្លើយតប ឬវិធានការទប់ស្កាត់ ដោយផ្អែកលើមេរៀនពីទិន្នន័យរដ្ឋបាល។	ខ- អភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវាពាក់ព័ន្ធ និងការចាត់ចែងករណីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីការគ្រប់គ្រងករណី និងដំណើរការប្រព័ន្ធប្រមូលទិន្នន័យ។ គ- បង្កើតប្រព័ន្ធរាយការណ៍ដែលផ្តល់ទិន្នន័យសម្រាប់ការវិភាគតាមដំណាក់កាលដែលគាំទ្រដល់ការកំណត់រកនិន្នាការនៃប្រភេទអំពើហិង្សា ជនប្រព្រឹត្ត សេវាដែលបានស្វែងរក និងទទួលបាន និងការបញ្ជូនដែលបានធ្វើឡើង ដែលអាចត្រូវបានបែងចែកតាមផ្នែកដូចជា អាយុ ការងារ ទីតាំងនៃអំពើហិង្សា និងផ្នែកផ្សេងៗទៀត។ ឃ- រៀបចំកិច្ចប្រជុំទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលបានសិក្សា និងបន្តកែលម្អលើការគ្រប់គ្រងករណី និងការប្រមូលទិន្នន័យរដ្ឋបាល។ ង- ប្រើប្រាស់ទិន្នន័យពីការវិភាគដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋាន	ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							

		ដល់ការរៀបចំគោលនយោបាយ ឬការកែលម្អប្រព័ន្ធទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។								
៨.៥- ប្រព័ន្ធប្រមូលទិន្នន័យរដ្ឋបាល និងការរាយការណ៍តាមវិស័យ ត្រូវបានបង្កើតឡើង និងមានដំណើរការ។	ក- របាយការណ៍តាមកាលកំណត់ទៀងទាត់អាចរកបានពីវិស័យយ៉ាងហោចណាស់ចំនួនពីរទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការអនុវត្តតាមការព្រមព្រៀងលើសំណុំទិន្នន័យអប្បបរមាដែលបានកំណត់។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ២	ក- រៀបចំប្រព័ន្ធសម្រាប់រាយការណ៍តាមវិស័យស្តីពីទិន្នន័យអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ខ- ពិនិត្យមើលទិន្នន័យពីប្រព័ន្ធផ្សេងៗតាមកាលកំណត់ ដើម្បីកំណត់ពីនិន្នាការ ភាពរាំងស្ទះ និងផ្នែកផ្សេងៗសម្រាប់ការកែលម្អ។ គ- ទស្សនកិច្ចសិក្សាពីបណ្តាប្រទេសដែលបានអនុវត្តការងារនេះ។ ឃ- រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយលើការអនុវត្តប្រព័ន្ធប្រមូលទិន្នន័យជារៀងរាល់ត្រីមាស និងឆ្នាំ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ម.ផ. • ក.ស.ប. • ក.យ. • អ.យ.ក. • នគរបាលជាតិ • រដ្ឋបាលថ្នាក់ក្រោមជាតិ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		ង-កែលម្អប្រព័ន្ធឆ្លើយតបដោយផ្អែកលើមេរៀនពីការវិភាគទិន្នន័យតាមវិស័យ។								

យុទ្ធសាស្ត្រគន្លឹះ : សេវាសុខាភិបាល

លទ្ធផលទី៩ : ការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីសម្រាប់ប្រព័ន្ធសុខាភិបាល កាន់តែមានភាពប្រសើរឡើង។

សូចនាករលទ្ធផលនិងដំណើរការ៖

៩ក- ចំនួនស្ត្រីដែលត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រព័ន្ធសុខាភិបាល និងបានបញ្ជូនទៅរកសេវាសមស្របនានាមានការកើនឡើង(ទិន្នន័យអ្នកប្រើប្រាស់សេវា)។

៩ខ- សមាមាត្រនៃអ្នករស់រានមានជីវិតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបង្ហាញពីការពេញចិត្តចំពោះសេវាដែលបានផ្តល់ (ទិន្នន័យអ្នកប្រើប្រាស់សេវា)។

លទ្ធផលគន្លឹះ	**សូចនាករសមិទ្ធកម្មគន្លឹះ**	**សកម្មភាពគន្លឹះ**	**ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត**	**រយៈពេល**						**ប្រភពធនធាន**
				២៥	**២៦**	**២៧**	**២៨**	**២៩**	**៣០**	
៩.១- ការពង្រឹងសមត្ថភាពអ្នកផ្តល់សេវាថែទាំសុខភាពជួរមុខ (នៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ឆ្មប) ក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្របតាមពិធីសារថ្នាក់ជាតិ។	ក- ចំនួនមូលដ្ឋានសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលស្តីពីការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្របតាមការអនុវត្តល្អ និងពិធីសារថ្នាក់ជាតិ និងអន្តរជាតិ។ ចំណុចដៅ : មូលដ្ឋានសុខាភិបាល ចំនួន២០៤ ត្រូវបានបណ្តុះបណ្តាល	ក- អភិវឌ្ឍសមត្ថភាពអ្នកផ្តល់សេវាថែទាំសុខភាពជួរមុខនៅគ្រប់កម្រិតស្តីពីបទដ្ឋានអប្បបរមានៃការផ្តល់សេវាទាំងអស់និងពិធីសារស្តីពីការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិស័យសុខាភិបាល។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ស.ប. **ស្ថាប័នដៃគូចូលរួម៖** • មន្ទីរសុខាភិបាល • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
៩.២- គំរូកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដំណើរការនៅតាមមន្ទីរពេទ្យបង្អែកខេត្ត គោលដៅ និងខេត្តថ្មីៗ នៅថ្នាក់ខេត្ត	ក- ចំនួនកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្មីដែលបានបង្កើតឡើង។	ក- ធ្វើបច្ចុប្បន្នកម្មតួនាទីនិងភារកិច្ចសម្រាប់កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ស.ប.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

ដើម្បីបង្កើនលទ្ធភាពក្នុងការទទួលបានសេវាសុខភាពដែលមានការសម្របសម្រួល និងប្រកបដោយគុណភាព និងការបញ្ជូនទៅរកសេវាពាក់ព័ន្ធសំខាន់ៗ សម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ខ- ភាគរយកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបំពេញមុខងារស្របតាមនីតិវិធីប្រតិបត្តិស្តង់ដា និងគោលការណ៍ណែនាំថ្នាក់ជាតិ មានការកើនឡើង។ គ- កំណើនចំនួននៃការបញ្ជូនទៅរកសេវាសំខាន់ៗផ្សេងទៀត ដើម្បីឱ្យជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទទួលសេវាសុខភាព (ការបញ្ជូនទៅក្រសួងកិច្ចការនារី សេវាផ្នែកច្បាប់ និងសេវាផ្សេងៗ)។ ចំណុចដៅ : ចំនួនកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ៥	ដើម្បីពង្រឹងនិងផ្សារភ្ជាប់កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅនឹងសេវាគ្រប់គ្រងករណីនិងវិធីបញ្ជូន។ កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រស្ថិតក្រោមផ្នែកវេជ្ជសាស្ត្រ សង្គមរបស់មន្ទីរពេទ្យបង្អែក ដូចមានចែងក្នុងសេចក្តីណែនាំប្រតិបត្តិស្តីពីការអភិវឌ្ឍមន្ទីរពេទ្យបង្អែក។ ខ- ពង្រីកកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅបណ្តាខេត្តផ្សេងទៀត ដែលមានការឆ្លើយតបដោយមានការសម្របសម្រួល និងកំពុងមានការរៀបចំការគ្រប់គ្រងករណី។ គ- ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធស្តីពីគោលការណ៍ណែនាំស្តីពីតួនាទីនិងភារកិច្ចក្នុងការអនុវត្តឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ស្ថាប័នដៃគូចូលរួម ៖ • មន្ទីរពេទ្យបង្អែក • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							

		ឃ- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាថែទាំសុខភាពស្តីពីបទដ្ឋានអប្បបរមាសម្រាប់ឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងពិធីសារសម្រាប់ការថែទាំស្ត្រីនិងកុមារដែលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងប្រព័ន្ធសុខាភិបាល។ ង- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយជារៀងរាល់ឆ្នាំ និងតាមដានជាប្រចាំលើការអនុវត្តឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។								
៩.៣- សមត្ថភាពរបស់គណៈកម្មការវេជ្ជបណ្ឌិតផ្នែកពិនិត្យកោសល្យវិច័យដែលធ្វើការត្រួតពិនិត្យកោសល្យវិច័យ ត្រូវបានពង្រឹង ដើម្បីផ្តល់សេវាស្របតាមបទដ្ឋានជាតិ និងផ្តល់សក្តីកម្មដើម្បីគាំទ្រដល់ការផ្តន្ទាទោសជនប្រព្រឹត្ត។	ក- គោលការណ៍ណែនាំស្តីពីការធ្វើកោសល្យវិច័យ ដែលបានធ្វើបច្ចុប្បន្នកម្ម និងកែសម្រួល។ ចំណុចដៅ : ១ ខ- គណៈកម្មការវេជ្ជបណ្ឌិតផ្នែកពិនិត្យកោសល្យវិច័យដែលមានសមត្ថភាព និងផ្តល់ការត្រួតពិនិត្យកោសល្យវិច័យ	ក- បច្ចុប្បន្នកម្មលើគោលការណ៍ណែនាំស្តីពីការធ្វើកោសល្យវិច័យ ស្របតាមបទដ្ឋានជាតិ និងបទដ្ឋានកម្រិតសកល។ ខ- ពង្រឹងសមត្ថភាពគណៈកម្មការវេជ្ជបណ្ឌិតផ្នែកពិនិត្យកោសល្យវិច័យ ដើម្បីផ្តល់ការត្រួតពិនិត្យកោសល្យវិច័យ	**ស្ថាប័នដឹកនាំ៖** • ក.ស.ប. **ស្ថាប័នដៃគូចូលរួម៖** • មន្ទីរពេទ្យបង្អែក • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	ស្របតាមគោលការណ៍ណែនាំស្តីពីការធ្វើកោសល្យវិច័យដែលបានធ្វើបច្ចុប្បន្នកម្ម ។ គ- អ្នកជំនាញថែទាំសុខភាពដែលផ្តល់ការត្រួតពិនិត្យកោសលវិច័យ កាន់តែមានទំនុកចិត្តចំពោះការផ្តល់សក្ខីកម្មក្នុងតុលាការ។	ស្របតាមគោលការណ៍ណែនាំស្តីពីការធ្វើកោសលវិច័យដែលបានធ្វើបច្ចុប្បន្នកម្មនៅគ្រប់រាជធានី ខេត្ត។ គ- អភិវឌ្ឍសមត្ថភាពអ្នកជំនាញដូចជាបុគ្គលិកថែទាំសុខភាពស្តីពីការផ្តល់សក្ខីកម្មក្នុងតុលាការលើករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។							

យុទ្ធសាស្ត្រគន្លឹះ : នគរបាលនិងយុត្តិធម៌

លទ្ធផលទី១០ : ស្ត្រីនិងក្មេងស្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលបានយុត្តិធម៌។

សូចនាករលទ្ធផលនិងដំណើរការ៖

១០ក- សមាមាត្រជនរងគ្រោះដោយអំពើហិង្សាក្នុងរយៈពេល១២ខែមុន ដែលបានរាយការណ៍ពីភាពរងគ្រោះ ទៅអាជ្ញាធរមានសមត្ថកិច្ច (**SDG** 16.3.1)។

១០ខ- សមាមាត្រនៃអ្នករស់រានមានជីវិតពីអំពើហិង្សាដែលបង្ហាញពីការពេញចិត្តចំពោះអ្នកផ្តល់សេវានគរបាលនិងសេវាយុត្តិធម៌ (ទិន្នន័យអ្នកប្រើប្រាស់សេវា)។

លទ្ធផលគន្លឹះ	**សូចនាករសមិទ្ធកម្មគន្លឹះ**	**សកម្មភាពគន្លឹះ**	**ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត**	**រយៈពេល**						**ប្រភពធនធាន**
				២៥	**២៦**	**២៧**	**២៨**	**២៩**	**៣០**	
១០.១- ប្រតិបត្តិការអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌(អាជ្ញាធរមូលដ្ឋាន នគរបាល កងរាជអាវុធហត្ថ ព្រះរាជអាជ្ញាចៅក្រម)អនុវត្តកិច្ចការពារផ្លូវច្បាប់កាន់តែមានប្រសិទ្ធភាពចំពោះករណីអំពើហិង្សាលើស្ត្រី រួមទាំងការលេចឡើងនូវបញ្ហាប្រឈមថ្មី បទល្មើសថ្មី ដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិទ្យា	ក- ចំនួននៃការបណ្តុះបណ្តាលការហ្វឹកហ្វឺន និងការណែនាំសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗក្នុងផ្នែកយុត្តិធម៌(អាជ្ញាធរមូលដ្ឋាន នគរបាល កងរាជអាវុធហត្ថ មេធាវី ចៅក្រម ព្រះរាជអាជ្ញា)។	ក- ធ្វើបច្ចុប្បន្នកម្មកញ្ចប់បណ្តុះបណ្តាលទៅតាមភាពសមស្របដើម្បីធានាការរួមបញ្ចូលការអនុវត្តដែលឆ្លើយតបនឹងយេនឌ័រ និងបទល្មើសថ្មី ដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្របសម្រួលការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	**ស្ថាប័នដឹកនាំ៖** • ក.យ. • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • អាជ្ញាធរមានសមិត្តកិច្ច	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

ដើម្បីសម្របសម្រួលការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយអនុលោមតាមគោលការណ៍យកចិត្តទុកដាក់អំពីយេនឌ័រ។	ខ- ចំនួននៃការចេញសេចក្តីសម្រេចរដ្ឋបាល និងដីកាការពារមានការកើនឡើង។ គ- ការសម្រុះសម្រួលមិនត្រូវបានប្រើនៅក្នុងករណីនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ។	ខ- ផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ច មេធាវី ចៅក្រម និងព្រះរាជអាជ្ញា អំពីព័ត៌មានទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានស្តង់ដាដែលឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងបទល្មើសថ្មីដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្របសម្រួលការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការគំរាមកំហែងតាមអ៊ីនធឺណិត។ គ-បញ្ចប់និងអនុម័តគោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទគ្រួសារប្រកបដោយការឆ្លើយតបយេនឌ័រ និងការត្រួតពិនិត្យករណីអំពើហិង្សាលើស្ត្រី។ ឃ- អភិវឌ្ឍសមត្ថភាពអ្នកផ្តល់សេវាជួរមុខទាំងអស់អំពីហានិភ័យនានានៃការសម្រុះសម្រួលដើម្បីធានាថាការសម្រុះសម្រួលមិនត្រូវបាន	• អាជ្ញាធរមូលដ្ឋាន • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល								

		អនុវត្តនៅក្នុងករណីនៃអំពើហិង្សាលើស្ត្រីដែលមានចរិតលក្ខណៈព្រហ្មទណ្ឌ។								
១០.២- នគរបាលប៉ុស្តិ៍រដ្ឋបាលកំពុងឆ្លើយតបនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័របានទាន់ពេលវេលា ដោយអនុវត្តវិធីសាស្ត្រការងារនគរបាល និងសហគមន៍ដែលមានប្រសិទ្ធភាពនិងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនឃុំ សង្កាត់ដែលអនុវត្តវិធីសាស្ត្រការងារនគរបាល និងសហគមន៍(អនុវត្តទម្រង់ទាំង៤)។ ខ- ប្រជាពលរដ្ឋមានការពេញចិត្តកាន់តែខ្លាំងឡើងចំពោះសេវានគរបាល រួមទាំងភាពទាន់ពេលវេលា និងទំនាក់ទំនងកាន់តែប្រសើរ។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១	ក- ពង្រឹងសមត្ថភាពនគរបាលស្តីពីការអនុវត្តវិធីសាស្ត្រការងារនគរបាលនិងសហគមន៍ក្នុងការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ខ- ពង្រឹងសមត្ថភាពនគរបាលស្តីពីបទដ្ឋានអប្បបរមានៃសេវាសំខាន់ៗ គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពនិងការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជំនាញសេវាឆ្លើយតប។ គ- អភិវឌ្ឍនិងពង្រឹងសមត្ថភាពស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅគ្រប់កម្រិតដែលឆ្លើយតបនឹងយេនឌ័រ ស្របតាមច្បាប់ពាក់ព័ន្ធជាធរមាន និងការអនុវត្តល្អ ។	**ស្ថាប័នដឹកនាំ៖** • នគរបាលជាតិ • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ស.ប. • ក.ក.ន. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

១០.៣- ស្ត្រីដែលជាជនរងគ្រោះដោយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ អាចទទួលបានជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃពីមេធាវីដែលទទួលការបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានទទួលជំនួយផ្លូវច្បាប់ពីមេធាវីដែលត្រូវបានបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ធ្វើបច្ចុប្បន្នកម្មធនធានបណ្តុះបណ្តាលសម្រាប់មេធាវីស្តីពីក្របខ័ណ្ឌច្បាប់ និងឌីណាមិកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើផែនការសុវត្ថិភាព និងវិធីសាស្ត្រផ្សេងទៀតដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះក្នុងសេវាផ្លូវច្បាប់។ ខ- បណ្តុះបណ្តាលស្តីពីឌីណាមិកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្របខ័ណ្ឌច្បាប់ និងដំណោះស្រាយនានា ដើម្បីឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	**ស្ថាប័នដឹកនាំ៖** • ក.យ. • គ.ស.ម.ក • គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • ស.អ.យ. • ក.ស.ប. • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រគន្លឹះ : សេវាសង្គម

លទ្ធផលទី១១ : បង្កើនលទ្ធភាពសម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ក្នុងការទទួលបានសេវាសង្គមដែលមានការសម្របសម្រួលប្រកបដោយគុណភាព។

សូចនាករលទ្ធផលនិងដំណើរការ៖

១១ក- ចំនួនជនរងគ្រោះដោយអំពើហិង្សាលើស្ត្រីដែលមានលទ្ធភាពទទួលបានសេវាសមស្របនិងមានគុណភាពទាន់ពេលវេលា មានការកើនឡើង។

១១ខ- សមាមាត្រនៃអ្នករស់រានមានជីវិតពីអំពើហិង្សាដែលបង្ហាញពីការពេញចិត្តចំពោះអ្នកផ្តល់សេវាសង្គម (ទិន្នន័យអ្នកប្រើប្រាស់សេវា)។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
១១.១- ជនរងគ្រោះមានលទ្ធភាពទទួលបានព័ត៌មាន និងសេវា ការបញ្ជូនទៅកាន់	ក- ចំនួនអ្នកចូលប្រើព័ត៌មានតាមមធ្យោបាយផ្សេងៗមានការ	ក- បង្កើនការយល់ដឹងអំពីសេវាដែលអាចរកបាន និងចំណុច	**ស្ថាប័នដឹកនាំ៖** • ក.ក.ន.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

ជម្រកសុវត្ថិភាព ការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គម ការគាំទ្រផ្នែកសម្ភារៈ និងសេវាចាំបាច់ផ្សេងៗ។	កើនឡើង(អនឡាញ អេប និងបណ្តាញសង្គម)។ ខ- កំណើននៃចំនួនជនរងគ្រោះដែលស្វែងរកជំនួយតាមបណ្តាញទូរសព្ទជំនួយ និងអ្នកផ្តល់សេវាជួរមុខផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាល។	ចាប់ផ្តើមសំខាន់ៗ ដើម្បីទទួលបានសេវានិងកិច្ចការពារផ្សេងៗ ដូចជាលេខទូរសព្ទជំនួយ លេខទូរសព្ទបន្ទាន់ ដោយធានាថាព័ត៌មានត្រូវបានផ្សព្វផ្សាយដល់ស្ត្រីនិងក្មេងស្រីដែលមានសារៈតារអត្តសញ្ញាណចម្រុះ រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រី។ ខ- អនុវត្តកម្មវិធីបច្ចេកវិទ្យានានា(ប្រព័ន្ធឆ្លើយតបដោយស្វ័យប្រវត្តិ អេបសុវត្ថិភាពយើង My Journey និងអេបតាមទូរសព្ទដៃផ្សេងៗទៀត) ដើម្បីបង្កើនការផ្សព្វផ្សាយនិងលទ្ធភាពទទួលបានព័ត៌មានអំពីសេវាសំខាន់ៗ។ គ- អភិវឌ្ឍសមត្ថភាពដើម្បីធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាផ្សេងៗទាក់ទងនឹងបណ្តាញទូរសព្ទជំនួយ ដើម្បីធានាឱ្យមានការដាក់បញ្ចូលពលករទេសន្តរប្រវេសន៍ជាស្ត្រី និងក្រុមអត្តសញ្ញាណចម្រុះ។	**ស្ថាប័នដៃគូចូលរួម៖** • ក.ប.ទ. • ស.អ.យ. • ក.ស.ប. • រដ្ឋបាលថ្នាក់ក្រោមជាតិ • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							

១១.២- បញ្ជីអ្នកផ្តល់សេវាជាលក្ខណៈឌីជីថល ដែលបានធ្វើបច្ចុប្បន្នកម្មជាប្រចាំសម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ អាចចូលប្រើបានសម្រាប់ជនរងគ្រោះនិងអ្នកផ្តល់សេវា។	ក- បញ្ជីអ្នកផ្តល់សេវាជាលក្ខណៈឌីជីថលកំពុងដំណើរការ និងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់។ សូមពិនិត្យមើលសូចនាករ ១១.១-	ក- រៀបចំបញ្ជីអ្នកផ្តល់សេវាសំខាន់ៗទាំងអស់ក្នុងផ្នែកសុខាភិបាល នគរបាល និងយុត្តិធម៌ និងសេវាសង្គម រួមទាំងសេវាដែលបានផ្តល់ទីតាំង វិធីទំនាក់ទំនង និងការបញ្ជូន។ ខ- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាដែលមានរាយនាមក្នុងបញ្ជីអ្នកផ្តល់សេវាជាលក្ខណៈឌីជីថល ស្តីពីការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្សារភ្ជាប់នឹងវិធីបញ្ជូន។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
១១.៣- ជនរងគ្រោះកាន់តែមានភាពងាយស្រួលក្នុងការទទួលបានជម្រកសុវត្ថិភាពរយៈពេលខ្លីបណ្តោះអាសន្ននៅក្នុងសហគមន៍។	ក- ឯកសារណែនាំសម្រាប់ជម្រកសុវត្ថិភាពក្នុងសហគមន៍បានអនុវត្ត។	ក- បង្កើតជម្រើសសម្រាប់ផ្តល់ជម្រកសុវត្ថិភាព រយៈពេលខ្លីបណ្តោះអាសន្ននៅក្នុងសហគមន៍។ ខ- អនុវត្តការសាកល្បងជម្រកសុវត្ថិភាពក្នុងរយៈពេលខ្លីនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ស.ប. • មន្ទីរកិច្ចការនារី • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

១១.៤- ជនរងគ្រោះមានជម្រើសកាន់តែច្រើនក្នុងការបង្កើតចំណូល។	ក- ចំនួនគម្រោងផ្តោតលើការបង្កើនប្រាក់ចំណូលជាពិសេសសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ពាក់ព័ន្ធនឹងចំណុច ២.៣-។	ក- បង្កើនជម្រើសសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងការបង្កើតប្រាក់ចំណូល តាមរយៈរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

គោលបំណង : ច្បាប់និងគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ត្រូវបានតាក់តែងឡើងដោយផ្អែកលើទស្សនៈយេនឌ័រ និងការពារសិទ្ធិជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងជនប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

យុទ្ធសាស្ត្រគន្លឹះ : ការពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្តៈ

លទ្ធផលទី១២ : ក្របខ័ណ្ឌគតិយុត្តនៅកម្ពុជាក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ត្រូវបានពង្រឹងបន្ថែម។

សូចនាករលទ្ធផលនិងជំណើរការៈ

១២ក- ចំនួនច្បាប់និងបទប្បញ្ញត្តិនៅកម្ពុជាទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលអនុលោមទៅនឹងច្បាប់តំបន់ឬច្បាប់អន្តរជាតិ។

១២ខ- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានពិនិត្យ ហើយសិក្សាវាយតម្លៃនៃការអនុវត្តច្បាប់នេះ។

១២គ- កំណែទម្រង់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ត្រូវបានអនុម័តនិងប្រកាសផ្សព្វផ្សាយ។

លទ្ធផលគន្លឹះ	**សូចនាករសមិទ្ធកម្មគន្លឹះ**	**សកម្មភាពគន្លឹះ**	**ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត**	**រយៈពេល**						**ប្រភពធនធាន**
				២៥	**២៦**	**២៧**	**២៨**	**២៩**	**៣០**	
១២.១- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានធ្វើវិសោធនកម្មនិងបោះពុម្ពផ្សាយ ស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ។	ក- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានធ្វើវិសោធនកម្ម។	ក- បង្កើតក្រុមការងារនិងអនុវត្តផែនទីបង្ហាញផ្លូវឆ្ពោះទៅធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.យ.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ១	និងរៀបចំផែនការធ្វើការប៉ាន់ប្រមាណ និងបែងចែកធនធានសម្រាប់ការអនុវត្ត។ ខ- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ គ- ប្រកាសផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះដែលបានធ្វើវិសោធនកម្ម។ ឃ- ពង្រឹងសមត្ថភាពអ្នកអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។	**ស្ថាប័នដៃគូចូលរួម៖** • ក.ម.ផ. • ក.ប • ស.អ.យ. • ក.ស.ប. • អ.យ.ក. • មន្ទីរកិច្ចការនារី • អាជ្ញាធរមូលដ្ឋាន • អាជ្ញាធរមានសមត្ថកិច្ច • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							
១២.២- អ្នកពាក់ព័ន្ធសំខាន់ៗត្រូវបានបង្កើនការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់អំពីអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា តាមរយៈការវិវត្តនៃសង្គមបច្ចុប្បន្នដែលត្រូវចាត់ទុកថាជាបទល្មើស ដែលភ្ជាប់ទៅនឹងការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនិងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្របសម្រួលការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- ចំនួនកម្មវិធីអភិវឌ្ឍន៍សមត្ថភាពបណ្តុះបណ្តាល ស្តីពីក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ : ៥ ខ- កំណើននៃការផ្តល់សេវាដល់អ្នករស់រានមានជីវិតពីអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា	ក- ពិនិត្យមើលក្របខ័ណ្ឌច្បាប់និងឯកសារពាក់ព័ន្ធនឹងអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យាតាមរយៈការវិវត្តនាសង្គមបច្ចុប្បន្នដែលត្រូវចាត់ទុកថាជាបទល្មើស។ ខ- កំណត់យុទ្ធសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការការពារពីអំពើហិង្សា	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.យ. • ក.ម.ផ. **ស្ថាប័នដៃគូចូលរួម៖** • កបទ.សអ • ក.ប.ទ. • ក.ម.ផ. • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	រួមទាំងសំណុំរឿងដែលបានជំនុំជម្រះ។ គ- អនុម័តនិងប្រកាសផ្សព្វផ្សាយច្បាប់ស្តីពីបច្ចេកវិទ្យាព័ត៌មាន។	តាមប្រព័ន្ធបច្ចេកវិទ្យាសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ។ គ- រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់អ្នកពាក់ព័ន្ធ។ ឃ- ច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាបានអនុម័តនិងអនុវត្ត។	• អង្គការសង្គមស៊ីវិល							
យុទ្ធសាស្ត្រគន្លឹះ : ការពិនិត្យលើគោលនយោបាយនិងការពង្រឹងស្ថាប័ន **លទ្ធផលទី១៣ : ក្របខ័ណ្ឌគោលនយោបាយត្រូវបានកែលម្អ និងសម្របសម្រួលបានយ៉ាងល្អ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីកាន់តែមានប្រសិទ្ធភាព។** សូចនាករលទ្ធផល និងដំណើរការ៖ ១៣ក- ចំនួនគោលនយោបាយតាមវិស័យដែលពាក់ព័ន្ធត្រូវបានពិនិត្យ។ ១៣ខ- ចំនួនគោលនយោបាយដែលត្រូវបានពិនិត្យ និងឆ្លើយតបចំពោះស្ត្រីនិងក្មេងស្រី និងក្រុមដែលងាយរងគ្រោះ។									
លទ្ធផលគន្លឹះ	**សូចនាករសមិទ្ធកម្មគន្លឹះ**	**សកម្មភាពគន្លឹះ**	**ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត**	**រយៈពេល**						**ប្រភពធនធាន**
				២៥	២៦	២៧	២៨	២៩	៣០	
១៣.១- ការភ្ជាប់ទំនាក់ទំនងរវាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាមួយនឹងក្របខ័ណ្ឌគាំពារសង្គម ដូចមានចែង ក្នុងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ និង	ក- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ក្របខ័ណ្ឌគាំពារសង្គម និងការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី	ក- ផ្តល់ធាតុចូលទៅក្នុងដំណើរការនៃរៀបចំផែនការផ្សេងទៀត ដូចជាកិច្ចគាំពារសង្គម ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ស.អ.យ. • ក.ផ.ក. **ស្ថាប័នដៃគូចូលរួម៖** • ក្រុមប្រឹក្សាជាតិគាំពារសង្គម	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

ផែនការសកម្មភាពជាតិស្តីពីស្ត្រីសន្តិភាព និងសន្តិសុខ ត្រូវបានពង្រឹង។	សន្តិភាព និងសន្តិសុខ ត្រូវមានសង្គតិភាព។ ខ- របាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ គ- ផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចនៅថ្នាក់ឃុំ សង្កាត់។	ខ- ធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដាក់បញ្ចូលផ្នែកយេនឌ័រនិងកិច្ចការពារជនរងគ្រោះក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ គ- ផ្តល់ការណែនាំបច្ចេកទេសស្តីពីការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងការត្រៀមចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចនៅថ្នាក់ឃុំ សង្កាត់។	• មូលនិធិជាតិជំនួយសង្គម • ដៃគូអភិវឌ្ឍ							
១៣.២- គោលនយោបាយតាមវិស័យពាក់ព័ន្ធផ្សេងៗ ត្រូវបានលើកកម្ពស់ការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅក្នុងគោលនយោបាយពាក់ព័ន្ធតាមវិស័យនៃក្រុមការងារ	ក- ចំនួនគោលនយោបាយតាមវិស័យដែលឆ្លើយតបចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។	ក- លើកកម្ពស់ការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅក្នុងគោលនយោបាយពាក់ព័ន្ធតាមវិស័យនៃក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។	**ស្ថាប័នដឹកនាំ៖** • គ.ជ.គ.ម. **ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • រដ្ឋបាលថ្នាក់	X	X	X	X	X	X	• ជវិការដ្ឋ • អង្គការដៃគូ

គ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ។	ខ- ចំនួនគោលនយោបាយដែលបានអនុវត្តនៅក្នុងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយដែលឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។		ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល • កាកបាទក្រហមកម្ពុជា							
១៣.៣- យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ ត្រូវបានបង្កើតឡើងនិងអនុវត្ត។	ក- យុទ្ធសាស្ត្រស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ត្រូវបានបង្កើតនិងអនុវត្ត។ ខ- ផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ត្រូវបានបង្កើតនិងអនុវត្ត។	ក- ធ្វើការវិភាគស្ថានភាពដើម្បីស្វែងយល់ពីអត្រាប្រែប្រួលបុព្វហេតុ និងផលវិបាកនៃអាពាហ៍ពិពាហ៍កុមារនៅកម្ពុជា។ ខ- ប្រមូលមតិយោបល់និងអនុសាសន៍ដើម្បីកាត់បន្ថយអាពាហ៍ពិពាហ៍នៅវ័យក្មេង និងក្រុមយុវជនពីភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងទីភ្នាក់ងាររាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកដឹកនាំសហគមន៍ និងបុគ្គលរងផលប៉ះពាល់។ គ- ផ្សព្វផ្សាយនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ជ.ក. • ស.អ.យ. • ក.យ. • ក.ម.ផ. • អ.យ.ក. • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

យុទ្ធសាស្ត្រទី៤ : ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

គោលបំណង : ដើម្បីអភិវឌ្ឍប្រព័ន្ធដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ប្រមូល តាមដាន វិភាគ និងរាយការណ៍ទិន្នន័យអំពើហិង្សាលើស្ត្រីដោយផ្អែកលើភស្តុតាងច្បាស់លាស់។

យុទ្ធសាស្ត្រគន្លឹះ : ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

លទ្ធផលទី១៤ : ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងប្រព័ន្ធប្រមូលនិងតាមដានទិន្នន័យគ្រប់ជ្រុងជ្រោយត្រូវបានបង្កើតឡើង ដែលរួមបញ្ចូលទាំងទិន្នន័យទទួលបានពីការសិក្សាស្តីពីអត្រាប្រាំឡង់នៃអំពើហិង្សាលើស្ត្រី។

សូចនាករលទ្ធផលនិងដំណើរការ៖

១៤ ក- ការប្រមូលនិងផ្តល់ទិន្នន័យទាក់ទងនឹងអំពើហិង្សាលើស្ត្រីរបស់តួអង្គពាក់ព័ន្ធបានទាន់ពេលវេលា។

១៤ ខ- ស្ថាប័នអនុវត្តនីមួយៗបង្កើតផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលរួមបញ្ចូលលទ្ធផល លទ្ធផលគន្លឹះ និងសូចនាករសមស្របពីផែនការសកម្មភាពជាតិលើកទី៤។

១៤ គ- ស្ថាប័នអនុវត្តនីមួយៗផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំលើផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ខ្លួន។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវនិងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៦	២៧	២៨	២៩	៣០	
១៤.១- ផែនការនិងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី របស់សមាជិកក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រកាន់តែសកម្មឡើង។	ក- ចំនួនផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលត្រូវបានបង្កើតឡើង ដោយក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗ។ ខ- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ ដោយក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗដោយផ្អែកលើផែនការប្រតិបត្តិប្រចាំឆ្នាំ។	ក- បង្កើតក្របខ័ណ្ឌការត្រួតពិនិត្យ និងវាយតម្លៃដែលកំណត់ដំណើរការសម្រាប់ត្រួតពិនិត្យតាមដានវឌ្ឍនភាព លើការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ (ផែនការការងារ របាយការណ៍ការវាយតម្លៃ ប្រភពព័ត៌មាន ។ល។)ក្នុងឆ្នាំទី១ (២០២៥)។ ខ- ធ្វើបច្ចុប្បន្នកម្មនិងពង្រឹងការប្រើប្រាស់ផែនការប្រតិបត្តិ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ផ.ក. • ក.ស.ប. • ក.ម.ផ. • ក.ស.ហ.វ. • ក.យ. • ក.ទ.ច. • ក.ឆ.ស.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	គ- ចំនួនរបាយការណ៍ប្រចាំឆ្នាំ ដែលបូកសរុបទិន្នន័យពី ក្រសួងសាមី។ ឃ- ចំនួនផែនការប្រតិបត្តិ ប្រចាំឆ្នាំ។	ប្រចាំឆ្នាំដល់សមាជិកក្រុម ការងារបច្ចេកទេសឆ្លើយតប ចំពោះអំពើហិង្សាទាក់ទងនឹង យេនឌ័រដើម្បីជានាគាពបន្សុីគ្នា នឹងចំណុចអាទិភាពនៃផែនការ សកម្មភាពជាតិលើកទី៤។ គ- ពង្រឹងប្រព័ន្ធរាយការណ៍ប្រចាំ ឆ្នាំ ដោយផ្អែកលើផែនការ ប្រតិបត្តិប្រចាំឆ្នាំ។ ឃ- អភិវឌ្ឍសមត្ថភាពស្តីពីការ រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងប្រព័ន្ធរាយការណ៍របាយ ការណ៍ប្រចាំឆ្នាំ។ ង- ពង្រឹងសមត្ថភាពក្រុមការងារ ត្រួតពិនិត្យនិងវាយតម្លៃរៀង រាល់ឆ្នាំ។								
១៤.២- យន្តការរាយការណ៍ទិន្នន័យរដ្ឋបាល ត្រូវបានបង្កើតឡើង សម្រាប់ប្រព័ន្ធ គ្រប់គ្រងករណីដែលអនុវត្តនៅក្រសួង កិច្ចការនារី ដែលផ្តល់ព័ត៌មានវិភាគអំពី និន្នាការក្នុងការស្វែងរកជំនួយ។	ក- ចំនួនរបាយការណ៍ប្រចាំឆ្នាំ ដែលផ្តល់ទិន្នន័យអំពីជនរង គ្រោះស្វែងរកសេវាតាមរយៈ ក្រសួងកិច្ចការនារីនិងមន្ទីរ កិច្ចការនារី។ ទិន្នន័យដើមគ្រា : ៤ ខេត្ត ចំណុចដៅ : ២៥រាជធានី ខេត្ត។	ក- ពង្រឹងការអនុវត្តប្រព័ន្ធ គ្រប់គ្រងទិន្នន័យរដ្ឋបាល ករណីជាលក្ខណៈឌីជីថល ដើម្បីកត់ត្រា និងរាយការណ៍ អំពីសំណុំទិន្នន័យដែលបាន កំណត់យកពីគ្រប់ខេត្តនិង ស្រុកទាំងអស់។ ខ- ពង្រឹងសមត្ថភាពប្រើប្រាស់ ទិន្នន័យដែលប្រមូលបាន	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • មន្ទីរកិច្ចការនារី • រដ្ឋបាលថ្នាក់ ក្រោមជាតិ • ក្រុមការងារឆ្លើយ តបជាពហុវិស័យ	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

		ដើម្បីណែនាំដល់ការកែលម្អសេវាសម្រាប់ជននៅរស់ពីអំពើហិង្សាលើស្ត្រី រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រី។	ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។							
១៤.៣- ទិន្នន័យរដ្ឋបាលសម្រាប់ប្រៀបធៀបនឹងវិស័យនានា។	ក- ចំនួនរបាយការណ៍ដែលមានទិន្នន័យពីវិស័យពាក់ព័ន្ធនីមួយៗដែលអាចប្រៀបធៀបបានដោយផ្អែកលើសំណុំទិន្នន័យអប្បបរមា។ ទិន្នន័យដើមគ្រា : ០ ចំណុចដៅ: របាយការណ៍ប្រចាំឆ្នាំ(៤ឆ្នាំ)។	ក- ពង្រឹងការរាយការណ៍និងរៀបចំរបាយការណ៍។ ខ- ទិន្នន័យតាមវិស័យមានការបែងចែកតាមភេទ អាយុ ប្រភេទអំពើហិង្សា ស្ថានភាពពិការភាព ប្រវត្តិទេសន្តរប្រវេសន៍ និងកត្តាផ្សេងៗទៀតត្រូវបានចងក្រង និងប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យប្រើបាស់។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ស.អ.យ. • ក.ប • ក.ម.ផ. • ក.យ • មន្ទីរកិច្ចការនារី • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
១៤.៤- ការវាយតម្លៃផ្អែកលើកស្តុតាង ដើម្បីរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិលើកទី៤។	ក- របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងបញ្ចប់ការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ ត្រូវបានផ្សព្វផ្សាយ។	ក- វាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងបញ្ចប់នៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល			X			X	• អង្គការដៃគូ

១៤.៥- សមត្ថភាពរបស់មន្ត្រីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី និងអ្នកពាក់ព័ន្ធក្នុងការប្រើប្រាស់ស្ថិតិអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ សម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីត្រូវបានពង្រឹង។	ក- ចំនួនគោលនយោបាយដែលទទួលបានទិន្នន័យអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីណែនាំដល់ការរៀបចំគោលនយោបាយ។ ខ- ចំនួនសេវាសំខាន់ៗដែលត្រូវបានកែលម្អដោយផ្អែកលើការយល់ដឹងអំពីគម្លាតដែលរំលេចដោយទិន្នន័យ។	ក- កសាងសមត្ថភាពស្តីពីការប្រើប្រាស់ទិន្នន័យអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំគោលនយោបាយ និងកម្មវិធីសម្រាប់អ្នកដែលមានសាវតារអត្តសញ្ញាណចម្រុះរួមទាំងស្ត្រីនិងក្មេងស្រី ។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • មន្ទីរកិច្ចការនារី • រដ្ឋបាលថ្នាក់ក្រោមជាតិ • ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
១៤.៦- ការផ្តល់កស្តុតាង ដើម្បីជួយដល់ការកែលម្អគុណភាពសេវាកម្ម។	ក- ចំនួនដងនៃការចុះត្រួតពិនិត្យតាមដាន។ ខ- ចំនួននៃការកែលម្អសេវាដែលធ្វើឡើងដោយផ្អែកលើអនុសាសន៍នៃការត្រួតពិនិត្យតាមដាន។	ក- អភិវឌ្ឍសមត្ថភាព និងអនុវត្តការត្រួតពិនិត្យស្តង់ដាសេវាកម្មអប្បបរមា ដោយផ្តោតលើអ្នកផ្តល់សេវាជួរមុខ។ ខ- កែលម្អការផ្តល់សេវាដោយផ្អែកលើមតិកែលម្អពីការត្រួតពិនិត្យឧបករណ៍ពិនិត្យតាមដានចំនួន ២ ដែលបានបង្កើត និងអនុវត្ត គឺ (១)ការបង្កើតនិងដាក់ឱ្យប្រើប្រាស់បទដ្ឋានសេវាពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង(២)ការប្រមូលទិន្នន័យពីការឆ្លុះបញ្ចាំងដំណើរ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. **ស្ថាប័នដៃគូចូលរួម៖** • ក.ស.ប. • ក.ម.ផ. • មន្ទីរកិច្ចការនារី • រដ្ឋបាលថ្នាក់ក្រោមជាតិ • ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ • ដៃគូអភិវឌ្ឍ	X	X	X	X	X	X	• អង្គការដៃគូ

		ការរបស់ក្រុមការងារឆ្លើយតប អំពើហិង្សាទាក់ទងនឹងយេនឌ័រ។	• អង្គការសង្គមស៊ីវិល							

យុទ្ធសាស្ត្រគន្លឹះ : ការរៀនសូត្រនិងការសិក្សាស្រាវជ្រាវ

លទ្ធផលទី១៥ : ការកែលម្អកស្តុតាងស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលអាចរកបានប្រើប្រាស់បាន និងប្រកបដោយគុណភាព ត្រូវបានកែលម្អ ដើម្បីជួយដល់ការរៀបចំគោលនយោបាយ កម្មវិធី និងកិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់។

សូចនាករលទ្ធផលនិងដំណើរការ៖

១៥ក- ចំនួននៃកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ឬឆ្លើយតបចំពោះ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលផ្អែកលើភស្តុតាង ត្រូវបានរៀបចំឡើង ឬសម្របតាមដោយផ្អែកលើការស្រាវជ្រាវ ឬរបកគំហើញនៃការវាយតម្លៃថ្មីៗ។

លទ្ធផលគន្លឹះ	សូចនាករសមិទ្ធកម្មគន្លឹះ	សកម្មភាពគន្លឹះ	ស្ថាប័នទទួលខុសត្រូវ និងអនុវត្ត	រយៈពេល						ប្រភពធនធាន
				២៥	២៥	២៥	២៥	២៥	២៥	
១៥.១- ទិន្នន័យអត្រាប្រហ៊ាឡង់អាចរកបានតាមកាលកំណត់សម្រាប់ការវិភាគដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ និងផ្តល់ព័ត៌មានអំពីការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធី។	ក- ការសិក្សាអត្រាប្រហ៊ាឡង់ឆ្លើយតបស្របតាមស្តង់ដាសកល។	ក- គាំទ្រដល់ការបញ្ចូលផ្នែកអំពើហិង្សាក្នុងគ្រួសារនៅក្នុងការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាលើកក្រោយ។ ខ- បង្កើនលទ្ធភាពប្រើប្រាស់ទិន្នន័យអត្រាប្រហ៊ាឡង់ ដើម្បីតាមដាននិងគាំទ្រការរៀបចំគោលនយោបាយក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។	**ស្ថាប័នដឹកនាំ៖** • ក.ក.ន. • ក.ផ.ក/វ.ជ.ស. **ស្ថាប័នដៃគូចូលរួម៖** • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ
១៥.២- ការសិក្សាស្រាវជ្រាវដោយផ្អែកលើមូលដ្ឋានភស្តុតាងត្រូវបានប្រើប្រាស់ដើម្បីលើកឡើងពីវិធានការទប់ស្កាត់និងឆ្លើយតប។	ក- ចំនួននៃការសិក្សាបែបគុណវិស័យអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។	ក- ធ្វើការស្រាវជ្រាវលើការអនុវត្តផ្នែកសំខាន់ៗដើម្បីផ្តល់ជាមូលដ្ឋានព័ត៌មានដល់ការ	**ស្ថាប័នដឹកនាំ៖** • ក.ក.ន.	X	X	X	X	X	X	• ថវិការដ្ឋ • អង្គការដៃគូ

	ខ- ចំនួនវិធានការទប់ស្កាត់ឬវិធានការឆ្លើយតបដែលផ្អែកតាមការស្រាវជ្រាវបច្ចុប្បន្ន។	រៀបចំគោលនយោបាយនិងកម្មវិធីស្តីពី៖ • និយាមសង្គមដែលបង្កគ្រោះថ្នាក់ ដែលជាកត្តាជំរុញឱ្យកើតមានអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា • ភ្ជាប់ទំនាក់ទំនងរវាងអំពើហិង្សាលើស្ត្រីនិងអំពើហិង្សាលើកុមារ • ការកំណត់រកឧបសគ្គក្នុងការទទួលបានសេវាសំខាន់ៗ។ • ការធ្វើផែនទីនិងការកំណត់រកការអនុវត្តល្អៗក្នុងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ • ការប្រើប្រាស់បច្ចេកវិទ្យាដែលនាំឱ្យមានអំពើហិង្សាទាក់ទងយេនឌ័រ។	**ស្ថាប័នដៃគូចូលរួម៖** • ក.ស.ប. • ស.អ.យ. • អ.យ.ក. • ក.ធ.ស. • ក.ផ.ក. • ក.ម.ផ. • ក.យ. • មន្ទីរកិច្ចការនារី • រដ្ឋបាលថ្នាក់ក្រោមជាតិ • ដៃគូអភិវឌ្ឍ • អង្គការសង្គមស៊ីវិល							
១៥.៣- ទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រីក្នុងពន្ធនាគារ ត្រូវបានប្រមូលនិងចងក្រង។	ក- ចំនួនសកម្មភាពដើម្បីឆ្លើយតបទៅនឹងស្ថានភាពរបស់ស្ត្រីនៅក្នុងពន្ធនាគារដែលបានផ្តល់ព័ត៌មានតាមរយៈការប្រមូលទិន្នន័យ។	ក- ផ្តល់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រដល់ក្រុមការងារចុះប្រមូលទិន្នន័យ ដោយស្វែងយល់ពីស្ថានភាពរបស់ស្ត្រីនៅក្នុងពន្ធនាគារ។	**ស្ថាប័នដឹកនាំ៖** • ក.ម.ផ. • ក.យ. • គ.ស.ម.ក.	X	X	X	X	X	X	• ប៊ីការដ្ឋ • អង្គការដៃគូ

		ខ- ចុះត្រួតពិនិត្យស្ថានភាពស្ត្រី និងកុមារនៅក្នុងពន្ធនាគារ។ គ- ទទួលដោះស្រាយនិងអង្កេតលើបណ្តឹងពីជនជាប់ឃុំតាមរយៈប្រអប់បណ្តឹងរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។	**ស្ថាប័នដៃគូចូលរួម៖** • ក.ក.ន. • ក.ជ.ក.ស. • គ.ស.ម.ក • រដ្ឋបាលថ្នាក់ក្រោមជាតិ							

៤- ការវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ល.រ.	លិខិតបទដ្ឋានគតិយុត្ត	ក្របខ័ណ្ឌពេលវេលា					
		២០២៥	២០២៦	២០២៧	២០២៨	២០២៩	២០៣០
១	ផែនទីបង្ហាញផ្លូវឆ្ពោះទៅធ្វើវិសោធនកម្ម ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុង គ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបាន រៀបចំ	x					
២	ពិនិត្យនិងកែសម្រួលច្បាប់ស្តីពីការទប់ ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារ ជនរងគ្រោះ ឆ្នាំ២០០៥ និងអនុម័តនិង អនុវត្ត		x	x	x	x	x
៣	ច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធ បច្ចេកវិទ្យា ត្រូវបានអនុម័តនិងអនុវត្ត	x	x	x	x	x	x
៤	ផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការ មានផ្ទៃពោះនៅវ័យដំទង់កំពុងត្រូវបាន រៀបចំនិងអនុម័តនិងអនុវត្ត	x	x	x	x	x	x
៥	ពង្រីកនិងពង្រឹងក្រុមការងារឆ្លើយតប ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំង ថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ	x	x	x	x	x	x
៦	ពង្រីកនិងពង្រឹងកន្លែងផ្តល់សេវាចម្រុះ ឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹង យេនឌ័រនៅតាមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត	x	x	x	x	x	x
៧	សេចក្តីព្រាងផែនទីចង្ហាញផ្លូវឆ្ពោះទៅ រៀបចំ ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាពនិងសន្តិសុខនៅកម្ពុជា កំពុងត្រូវ បានរៀបចំ	x	x				
៨	ផែនការសកម្មភាពជាតិស្តីពីស្ត្រីសន្តិភាព និងសន្តិសុខនៅកម្ពុជា នឹងត្រូវរៀបចំ		x	x	x	x	x
៩	បង្កើតក្រុមការងារតាមស្ថាប័ន អង្គភាព រោងចក្រ ក្រុមហ៊ុន និងសហគ្រាស ដើម្បី ទទួលបាយការណ៍អំពីការបៀតបៀនផ្លូវ ភេទនៅកន្លែងធ្វើការ និងមានភាតព្វកិច្ច រាយការណ៍និងដាក់ពាក្យបណ្តឹងទៅ នគរបាលនិងតុលាការ	x	x	x	x	x	x

១០	ពិនិត្យមើលក្របខ័ណ្ឌច្បាប់និងឯកសារពាក់ព័ន្ធនឹងអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យាតាមរយៈការវិវត្តនាសង្គមបច្ចុប្បន្នដែលត្រូវចាត់ទុកថាជាបទល្មើស	x	x	x	x	x	x

៥- គម្រោងចំណាយ

ដើម្បីអនុវត្តផែនការសកម្មភាពជាតិនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាព និងដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងស្របតាមលទ្ធភាពនៃការវិភាជថវិកាប្រចាំឆ្នាំ ព្រមទាំងអាចប្រើប្រាស់ថវិកាដែលទទួលបានពីដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន។

៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីជានាការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ប្រកបដោយជោគជ័យ ចាំបាច់ត្រូវមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាសេនាធិការសម្រាប់តាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ប្រព័ន្ធប្រមូលទិន្នន័យតាមដានការអនុវត្ត ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល គឺជាឧបករណ៍សម្រាប់តាមដាននិងវាយតម្លៃ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនិងភាពប្រឈមនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដោយរួមមានការកំណត់អំពីព័ត៌មានដើមគ្រា ការស្រាវជ្រាវអំពីស្ថានភាពតាមតម្រូវការ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការវាយតម្លៃចុងក្រោយ។

៦.១- ការតាមដាន ត្រួតពិនិត្យ និងការតាមដានបន្ត

ផ្អែកលើសកម្មភាពនិងសូចនាករនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នឹងសម្របសម្រួលដំណើរការរៀបចំ ប្រមូល និងពិនិត្យឡើងវិញលើផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។

ផែនការប្រតិបត្តិប្រចាំឆ្នាំ : ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័ន និងអង្គការនីមួយៗដែលចូលរួមក្នុងក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបញ្ចូលផែនការការងារនិងថវិកាសម្រាប់សកម្មភាពពាក់ព័ន្ធក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

របាយការណ៍ប្រចាំឆ្នាំ : ក្រសួង ស្ថាប័ន និងអង្គការនីមួយៗ នឹងផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដោយប្រើប្រាស់ទម្រង់ស្តង់ដា។

លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នឹងរៀបចំរបាយការណ៍បូកសរុបប្រចាំឆ្នាំស្តីពីវឌ្ឍនភាព គម្លាត និងបញ្ហាប្រឈមនានា។

កិច្ចប្រជុំឆ្នុះបញ្ចាំង : ជាកិច្ចប្រជុំដើម្បីតាមដានវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ ដែលមានលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានតួនាទីសម្របសម្រួលនិងរៀបចំកិច្ចប្រជុំនេះជារៀងរាល់៣ខែម្តង ដោយមានការចែករំលែកវឌ្ឍនភាពពីសមាជិកពីក្រសួង ស្ថាប័ន និងអង្គការដៃគូ សង្គមស៊ីវិលពាក់ព័ន្ធ។

៦.២- ការពិនិត្យមើលពាក់កណ្តាលអាណត្តិនិងការវាយតម្លៃចុងក្រោយ

ការពិនិត្យមើលពាក់កណ្តាលអាណត្តិនឹងត្រូវធ្វើនៅឆ្នាំ២០២៨ ដោយអ្នកវាយតម្លៃឯករាជ្យ នៅពេលអនុវត្តផែនការនេះបានពាក់កណ្តាល។ លទ្ធផលរកឃើញដែលទទួលបាន នឹងប្រើប្រាស់សម្រាប់ធ្វើបច្ចុប្បន្នកម្មឬកែលម្អការអនុវត្ត។ ការពិនិត្យមើលពាក់កណ្តាលអាណត្តិនេះ នឹងផ្តោតលើការសិក្សារៀនសូត្រនិងកែលម្អដោយផ្អែកលើការអនុវត្តផែនការសកម្មភាពជាតិលើកទី៤ជាក់ស្តែង។

ការវាយតម្លៃចុងក្រោយ នឹងត្រូវធ្វើនៅឆ្នាំ២០៣០ ដើម្បីផ្តល់ព័ត៌មានអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមដែលនៅសេសសល់ និងតម្រង់ទិសការរៀបចំផែនការសកម្មភាពនាពេលអនាគត។

លើសពីនេះ ទិន្នន័យផ្សេងទៀត ដូចជាទិន្នន័យអត្រាប្រហ៊ាឡង់ ដែលបានពីការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា នឹងត្រូវប្រើប្រាស់ ដើម្បីវាស់វែងវឌ្ឍនភាពនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

៧- សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ ត្រូវបានរៀបចំឡើង ផ្អែកលើកត្តាជោគជ័យ បទពិសោធ និងមេរៀនដែលបានមកពីការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣។ កិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់ដែលបានដាក់ចេញនៅក្នុងផែនការសកម្មភាពជាតិនេះ មានគោលបំណងលើកកម្ពស់ការសម្របសម្រួលនិងអភិក្រមគ្រប់ជ្រុងជ្រោយ ដែលផ្តោតសំខាន់លើការផ្លាស់ប្តូរជាវិជ្ជមាននៅតាមទីកន្លែងនិងស្ថានភាពផ្សេងៗ។ នៅក្នុងផ្នែកកិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ មានគោលបំណងកសាងភាពជោគជ័យផ្អែកលើការអភិវឌ្ឍបទដ្ឋាននានានិងការកែលម្អកិច្ចសម្របសម្រួលឱ្យកាន់តែប្រសើរឡើង ការអភិវឌ្ឍសមត្ថភាពដៃគូពាក់ព័ន្ធសំខាន់ៗក្នុងកិច្ចសហការផ្តល់សេវាជួយជនរងគ្រោះឱ្យកាន់តែល្អប្រសើរជាងមុន ដោយផ្អែកតាមអភិក្រមផ្តោតលើជនរងគ្រោះ និងកិច្ចអន្តរាគមន៍ប្រកបដោយបរិយាបន្ន។ ផែនការនេះនឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងការយល់ដឹងការអនុវត្ត និងការជំរុញការអនុវត្តច្បាប់និងគោលនយោបាយនានានៅថ្នាក់ក្រោមជាតិ។ ច្បាប់និងគោលនយោបាយ នឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនិងចំណុចខ្វះខាត ដោយផ្អែកលើការអនុវត្តជាក់ស្តែងនិងស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ។ ក្រៅពីនេះ ប្រព័ន្ធប្រមូលនិងតាមដានទិន្នន័យជាក់លាក់មួយ នឹងត្រូវបានបង្កើតនិងដាក់ឱ្យប្រើប្រាស់ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០។



សង្ខាតុក្រម

១- ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទតាមអនឡាញ សំដៅដល់ការកេង**ប្រវ័ញ្ច**ផ្លូវភេទនិងការរំលោភបំពានលើកុមារ ដោយប្រើប្រាស់ផ្នែកណាមួយឬទាំងស្រុងនៃបច្ចេកវិទ្យាតាមអ៊ីនធឺណិតឬបណ្តាញទំនាក់ទំនងឌីជីថលផ្សេងទៀត។

២- ការគ្រប់គ្រងករណី សំដៅលើដំណើរការសហការជាពហុវិស័យដែលប៉ាន់ប្រមាណ ធ្វើផែនការអនុវត្ត សម្របសម្រួល ត្រួតពិនិត្យនិងវាយតម្លៃជម្រើស និងសេវានានា ដើម្បីបំពេញតម្រូវការរបស់បុគ្គលម្នាក់ៗ។

៣- ការឆ្លើយតបយេនឌ័រ សំដៅលើវិធីសាស្ត្រមួយដែលព្យាយាមកំណត់និងដោះស្រាយយ៉ាងសកម្មនូវតម្រូវការជាក់លាក់ សិទ្ធិ និងបទពិសោធរបស់ស្ត្រី ក៏ដូចជាបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ ជាពិសេស នៅក្នុងបរិបទដែលមានវិសមភាពយេនឌ័រនិងអតុល្យភាពនៃអំណាច។ វិធីសាស្ត្រនេះជានាថា គោលនយោបាយ នីតិវិធី និងការអនុវត្ត ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់សមភាព សុវត្ថិភាព និងការចូលរួម ខណៈពេលដែលការទទួលស្គាល់និងដោះស្រាយឧបសគ្គជារចនាសម្ព័ន្ធ និងជាវប្បធម៌ក្នុងការឆ្ពោះទៅកាន់សមធម៌។ នៅក្នុងបរិបទនៃការសម្រុះសម្រួល និងការត្រួតពិនិត្យ/ការបញ្ជូនបន្តក្នុងករណីដែលអំពើហិង្សាត្រូវបានសង្ស័យឬកើតឡើង វិធីសាស្ត្រនេះផ្តោតលើដំណើរការដែលចាត់ទុកជនរងគ្រោះជាចម្បង ដែលផ្តល់អាទិភាពដល់ស្វ័យភាពការការពារ និងការលុបបំបាត់អំពើហិង្សានិងគ្រោះថ្នាក់។

៤- កត្តារួមចំណែកឬកត្តាហានិភ័យ សំដៅលើកត្តារួមចំណែក ឬកត្តាហានិភ័យបង្កើនហានិភ័យអំពើហិង្សា ឬធ្វើឱ្យកាន់តែកើតមាន។ កត្តាទាំងនេះធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងនូវមូលហេតុនៃអំពើហិង្សា ដែលអំពើហិង្សាកើតឡើងជាធម្មតា។ ទាំងអស់នេះរួមបញ្ចូលការសេពគ្រឿងស្រវឹង អំពើហិង្សានៅវ័យកុមារភាពរបស់បុរស ស្ថានភាពជីវិតដូចជាការពឹងផ្អែកលើផ្នែកហិរញ្ញវត្ថុ ភាពឯកោជាមួយនឹងប្រព័ន្ធគាំទ្រមិនល្អ កុមារមានចំនួនលើសពីប្រាំនាក់ពិការភាពនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ស្ថានភាពចំណាកស្រុកក្នុងចំណោមផ្សេងៗទៀត។

៥- ការត្រួតត្រាដោយបង្ខិតបង្ខំ សំដៅដល់ទម្រង់មួយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលសកម្មភាពអាកប្បកិរិយាចលនា និងការធ្វើទំនាក់ទំនងរបស់ជនដែលរួចផុតពីគ្រោះថ្នាក់ក្នុងចំណោមអំពើផ្សេងទៀត ត្រូវបានគេតាមដានត្រួតពិនិត្យ និងត្រួតត្រា។ អាកប្បកិរិយាបង្ខិតបង្ខំនិងការត្រួតត្រា អាចត្រូវបានប្រើប្រាស់មកលើជនដែលរួចផុតពីគ្រោះថ្នាក់ ឱ្យកើតមានអារម្មណ៍ភ័យខ្លាច ពឹងផ្អែក និងឯកោ។

៦- ការបង្ការទប់ស្កាត់ សំដៅលើវិធានការដើម្បីបញ្ឈប់អំពើហិង្សាមុនពេលវាចាប់ផ្តើម។ ការបង្ការទប់ស្កាត់ជួយសម្រួលដល់ការផ្លាស់ប្តូរដោយដោះស្រាយមូលហេតុមូលដ្ឋាន។ វាផ្តោតលើសកម្មភាពទាំងឡាយ ដើម្បីផ្លាស់ប្តូរនិយាមសង្គមការអនុវត្ត និងរចនាសម្ព័ន្ធដែលបង្កើតឱ្យមានវិសមភាពយេនឌ័រ។

៧- ការបៀតបៀនផ្លូវភេទ សំដៅលើអាកប្បកិរិយាដែលគេមិនចង់បាន មិនស្វាគមន៍ ឬមិនបានទទួលការស្វាគមន៍នៃលក្ខណៈផ្លូវភេទ ដែលអាចធ្វើឱ្យមនុស្សម្នាក់មានអារម្មណ៍អាម៉ាស់ កិតក្យ ឬអាក់អន់ចិត្ត។ ការបៀតបៀនផ្លូវភេទអាចមានទម្រង់ជាច្រើន ដូចជាពាក្យសម្តី ឬមិនមែនពាក្យសម្តី ឬរូបរាងកាយ ឬការចែករំលែករូបភាពអាសអាភាស។

៨- ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង សំដៅលើការរៀបអាពាហ៍ពិពាហ៍ផ្លូវការ ឬការរស់នៅជុំគ្នាជាប្តីប្រពន្ធមិនផ្លូវការណាមួយរវាងកុមារអាយុក្រោម១៨ឆ្នាំ និងមនុស្សពេញវ័យ ឬកុមារផ្សេងទៀត។

៩- ឱណាមិកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ សំដៅទៅលើគំរូនៃអំណាច និងការត្រួតត្រាដែលមានឫសគល់នៅក្នុងទំនាក់ទំនងយេនឌ័រមិនស្មើភាពគ្នា និងនិយាមសង្គមដែលបង្កគ្រោះថ្នាក់ ដែលបង្ហាញពីរបៀបដែលអំពើហិង្សាកើនឡើងនិងស្ថិតស្ថេរ ក៏ដូចជារបៀបដែលអ្នកនៅរស់រានមានជីវិតពីអំពើហិង្សាបានរងគ្រោះ និងការស្វែងរកគាំទ្រ។ សក្តានុពលទាំងនេះដំណើរការទាំងទៅលើបុគ្គល ទំនាក់ទំនង សហគមន៍ និងសង្គម ហើយមានឥទ្ធិពលធ្ងន់ធ្ងរនិភ័យនៃអំពើហិង្សា និងប្រសិទ្ធភាពនៃការឆ្លើយតបផងដែរ។

១០- អំពើហិង្សាទាក់ទងនឹងយេនឌ័រ សំដៅទៅលើស្ត្រី ដោយសារតែនាងជាស្ត្រី ឬដែលបង្កផលប៉ះពាល់ដល់ស្ត្រីលើសលប់។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ការរងទុក្ខ អំពើនៃការគំរាមកំហែង ការបង្ខិតបង្ខំ និងការដកហូតសេរីភាពផ្សេងទៀត។

១១- អំពើហិង្សាលើស្ត្រី សំដៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលនាំឱ្យកើតមានឬអាចបណ្តាលឱ្យមានទុក្ខលំបាកខាងផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តចំពោះស្ត្រី រួមទាំងអំពើគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពដោយបំពានមិនថាកើតឡើងក្នុងទីសាធារណៈឬជីវិតឯកជននោះឡើយ។ ពាក្យថា «ស្ត្រី» នៅទីនេះមានន័យគ្របដណ្តប់ទាំងបុគ្គលដែលកំណត់អត្តសញ្ញាណខ្លួនឯង ឬត្រូវបានចាត់ទុកថាជាស្ត្រី។ អាស្រ័យហេតុនេះ អំពើហិង្សាលើស្ត្រីបានគ្របដណ្តប់ទូទៅ ដោយមិនលើកលែងនូវទង្វើដូចខាងក្រោម៖

- អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងក្នុងគ្រួសារ រួមទាំងការវាយដំ ការរំលោភបំពានផ្លូវភេទលើក្មេងស្រីក្នុងគ្រួសារ អំពើហិង្សាទាក់ទងនឹងថ្លៃបណ្ណាការ ការរំលោភសេពសន្តវៈក្នុងចំណងអាពាហ៍ពិពាហ៍ ការកាត់ប្រដាប់ភេទស្ត្រី និងទំនៀមទម្លាប់ប្រពៃណីផ្សេងទៀត ដែលបង្កគ្រោះថ្នាក់ដល់ស្ត្រី អំពើហិង្សាមិនមែនលក្ខណៈប្តីប្រពន្ធ និងអំពើហិង្សាទាក់ទងនឹងការកេងប្រវ័ញ្ច
- អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងក្នុងសហគមន៍ទូទៅ រួមមានការរំលោភសេពសន្តវៈ ការរំលោភបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទ និងការបំភិតបំភ័យនៅកន្លែងធ្វើការ នៅក្នុងស្ថាប័នអប់រំ និងកន្លែងផ្សេងទៀត ការជួញដូរស្ត្រី និងពេស្យាចារដោយបង្ខំ
- អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលប្រព្រឹត្តដោយរដ្ឋ ឬការយោគយល់ដោយរដ្ឋគ្រប់ទីកន្លែងដែលបានកើតឡើង។

១២- អំពើហិង្សាក្នុងគ្រួសារឬអំពើហិង្សាពីដៃគូស្និទ្ធស្នាល សំដៅលើសកម្មភាពប្រព្រឹត្តលើផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្នែកសេដ្ឋកិច្ច ឬសកម្មភាពគំរាមកំហែងដែលមានឥទ្ធិពលលើមនុស្សម្នាក់ទៀត ដោយរាប់បញ្ចូលទាំងអាកប្បកិរិយាដែលបន្លាច បំភិតបំភ័យ គំរាមបំភ័យ បញ្ឆោត បំបាក់មុខ ស្តីបន្ទោស ធ្វើឱ្យរងរបួស ឬបួសនរណាម្នាក់។ អំពើហិង្សានេះអាចកើតឡើងក្នុងទំនាក់ទំនងជាច្រើនរួមទាំងគូស្នេហ៍ដែលបានរៀបការ រស់នៅជាមួយគ្នា ឬណាត់ជួប។ អំពើហិង្សាក្នុងគ្រួសារប៉ះពាល់ដល់មនុស្សគ្រប់មជ្ឈដ្ឋានសេដ្ឋកិច្ចសង្គម និងកម្រិតអប់រំ។

១៣- អំពើហិង្សាលើកុមារ សំដៅលើ «គ្រប់ទម្រង់នៃអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្ត ការរងរបួស ឬការរំលោភបំពាន ការមិនអើពើ ឬការថែទាំដោយការធ្វេសប្រហែស ការធ្វើទុក្ខបុកម្នេញ ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ» ទៅលើបុគ្គលណាម្នាក់ដែលមានអាយុក្រោម១៨ឆ្នាំ។

១៤- អំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរយៈបច្ចេកវិទ្យា សំដៅលើអំពើណាមួយដែលត្រូវបានប្រព្រឹត្ត ជួយធ្វើឱ្យកាន់តែធ្ងន់ធ្ងរ ឬពង្រីកកាន់ច្រើនដោយការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានឬឧបករណ៍ឌីជីថលផ្សេងទៀត ដែលនាំឱ្យកើត ឬអាចកើតឡើងមកលើផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងប៉ះពាល់ដល់សង្គម នយោបាយ ឬសេដ្ឋកិច្ច ឬការរំលោភសិទ្ធិនិងសេរីភាពផ្សេងទៀត។

១៥- យេនឌ័រ សំដៅលើលក្ខណៈ (តួនាទី ឥរិយាបថ អាកប្បកិរិយា ការទទួលខុសត្រូវ និងគុណតម្លៃនានា) និងឱកាសដែលវប្បធម៌និងសង្គមដាក់កំណត់ឱ្យបុរសនិងស្ត្រីអនុវត្តដោយឡែកពីគ្នា។ ការកំណត់លក្ខណៈឱកាស និងទំនាក់ទំនងទាំងនេះត្រូវបានមនុស្សគ្រប់រូបរៀនសូត្រពីវា តាមរយៈដំណើរការនៃការធ្វើទំនាក់ទំនងគ្នានៅក្នុងសង្គម។ តួនាទីយេនឌ័រនេះមានភាពជាក់លាក់ទៅតាមពេលវេលា បរិបទ និងអាចធ្វើការផ្លាស់ប្តូរបាន។ លក្ខណៈនិច្ចយសំខាន់ៗផ្សេងទៀតសម្រាប់ការវិភាគផ្នែកសង្គមវប្បធម៌ រួមមានវណ្ណៈ ពូជសាសន៍ កម្រិតនៃភាពក្រីក្រ ក្រុមជាតិពន្ធុ និងអាយុ។ ដោយទៅតាមកេទសំដៅទៅលើតែលក្ខណៈនិច្ចយផ្នែកជីវសាស្ត្ររបស់បុរសនិងស្ត្រីដែលមានមកពីកំណើត និងមិនអាចផ្លាស់ប្តូរបាន។

១៦- វិធីសាស្ត្រផ្តោតលើអ្នកនៅរស់រានមានជីវិត សំដៅលើគ្រប់ដំណើរការដែលផ្តល់ឱ្យអ្នកនៅរស់រានមានជីវិតនូវសិទ្ធិតម្រូវការ ជម្រើស ការសម្រេចចិត្ត និងការប្តេជ្ញាចិត្តដោយខ្លួនឯង។ វិធីសាស្ត្រនេះបង្កើតបរិយាកាសគាំទ្រ ដែលសិទ្ធិ និងអត្តសញ្ញាណចម្រុះ ត្រូវបានគោរព ហើយត្រូវបានប្រព្រឹត្តដោយសេចក្តីថ្លៃថ្នូរ និងការគោរពចំពោះអ្នកនៅរស់រានមានជីវិត។

១៧- អ្នកនៅរស់រានមានជីវិត សំដៅលើជនឬបុគ្គលដែលធ្លាប់រងគ្រោះដោយអំពើហិង្សា។ ពាក្យ **អ្នកនៅរស់រានមានជីវិត** ជាទូទៅត្រូវបានប្រើប្រាស់នៅក្នុងផ្នែកផ្តល់ជំនួយផ្លូវចិត្តនិងសង្គម ព្រោះវាបង្កប់នូវភាពធន់របស់អ្នកដែលធ្លាប់រងគ្រោះដោយអំពើហិង្សា។ ជនរងគ្រោះ គឺជាពាក្យដែលត្រូវបានប្រើជាញឹកញាប់នៅក្នុងផ្នែកច្បាប់ និងផ្នែកវេជ្ជសាស្ត្រ ដោយទទួលស្គាល់ថា អំពើហិង្សាទាក់ទងនឹងយេនឌ័រមានទម្រង់ជាច្រើន គឺជាបទល្មើស។

គន្ថនិទ្ទេស

[9] UN Women (2018) *Ending Violence Against Women* Website
ក្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រី ឆ្នាំ២០១៨ : គេហទំព័របញ្ឈប់អំពើហិង្សាលើស្ត្រី។

[2] អំពើហិង្សាដៃគូស្និទ្ធស្នាល (IPV) សំដៅលើឥរិយាបថណាមួយក្នុងទំនាក់ទំនងស្និទ្ធស្នាល ដែលបង្កឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទដល់អ្នកនៅក្នុងទំនាក់ទំនងនោះ។ នេះរួមបញ្ចូលទាំងអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត រួមទាំងឥរិយាបថត្រួតត្រានិង អំពើហិង្សាសេដ្ឋកិច្ច។ អំពើហិង្សាក្នុងគ្រួសារមានលក្ខណៈស្រដៀងគ្នានឹងពាក្យអំពើហិង្សាដៃគូស្និទ្ធស្នាលដែរ ដោយវាសំដៅលើអំពើហិង្សាក្នុងទំនាក់ទំនងស្និទ្ធស្នាល។ នៅក្នុងប្រទេសកម្ពុជា ក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ អំពើហិង្សាក្នុងគ្រួសារត្រូវបានកំណត់និយមន័យថាជាអំពើហិង្សារវាងប្តីឬប្រពន្ធ លើកូនក្នុងបន្ទុកឬមនុស្សដែលរស់នៅក្នុងផ្ទះតែមួយនិងជាអ្នកនៅក្នុងបន្ទុកគ្រួសារ។ និយមន័យចង្អៀតនេះបណ្តាលឱ្យមានការជាក់កំហិតលើទិន្នន័យ ឬភាពខុសគ្នាខ្លះនៃទិន្នន័យ ដែលនឹងត្រូវកំណត់នៅពេលពាក់ព័ន្ធ។

[3] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh.
ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[4] https://www.unwomen.org/sites/default/files/2023-04/Technology-facilitated-violence-against-women-Taking-stock-of-evidence-and-data-collection-en.pdf
អំពើហិង្សាលើស្ត្រីតាមរយៈបច្ចេកវិទ្យា : ការចាប់យកកស្តុតាងនិងការប្រមូលទិន្នន័យ។

[5] UN Women and World Health Organization (2022) Expert Group Meeting Report: Technology Facilitated Violence against women: Toward a common definition.
របាយការណ៍កិច្ចប្រជុំក្រុមអ្នកជំនាញរបស់ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រី និងអង្គការសុខភាពពិភពលោក ឆ្នាំ២០២២ : អំពើហិង្សាលើស្ត្រីតាមរយៈបច្ចេកវិទ្យា : ឆ្ពោះទៅកេនិយមន័យទូទៅ។

[6] UN Women (2023) Brief: The state of evidence and data collection on technology-facilitated violence against women | Publications | UN Women – Headquarters
កស្តុតាងនិងការប្រមូលទិន្នន័យរបស់ផ្ទៃស្តីពីអំពើហិង្សាលើស្ត្រីតាមរយៈបច្ចេកវិទ្យា។

[7] ECPAT, Interpol and UNICEF (2022) *Disrupting Harm in Cambodia: Evidence on Online Child Sexual Exploitation and Abuse.* Global Partnership to End Violence against Women
ការបង្កគ្រោះថ្នាក់នៅកម្ពុជា : កស្តុតាងស្តីពីការរំកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

[8] Center for Private Enterprise (2024) *Technology-Facilitated Online Gender Based Violence and Harassment: A Khmer English Glossary.* Phnom Penh.
អំពើហិង្សាទាក់ទងនឹងយេនឌ័រនិងការបៀតបៀនតាមរយៈបច្ចេកវិទ្យា : សទ្ទានុក្រមខ្មែរ/អង់គ្លេស។

[9] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh.
ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[10] Plan International, Ministry of Women's Affairs (2024) *The Research Study on Child, Early and Forced Marriages and Unions (CEFMU) in Cambodia.* Phnom Penh
ការសិក្សាស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីនិងអង្គការកែនទៅលើការរៀបការនៅវ័យក្មេងនិងការមានផៃពោះនៅវ័យជំទង់ ឆ្នាំ២០២៤។

[11] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh.
ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[12] Ibid.

[13] OHCHR (2022) *Report on Gender Based Violence against Indigenous Women* . Phnom Penh.

[14] Astury, J., Walji F. (2013) *Triple Jeopardy: Gender-based Violence and Human Rights Violations Experienced by Women with Disabilities in Cambodia.* Phnom Penh: Australian Aid.
ការប្រឈមហ្មឺងគ្រោះថ្នាក់ច្រើនដង : អំពើហិង្សាផ្អែកលើយេនឌ័រនិងការរំលោភសិទ្ធិមនុស្សបទពិសោធន៍ដោយស្ត្រីមានពិការភាពនៅកម្ពុជា។

[15] Ibid.

[16] Ministry of Women's Affairs (2014) *Cambodia Violence Against Children Survey.* Phnom Penh.របាយការណ៍ស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីឆ្នាំ២០១៤ស្តីពីអំពើហិង្សាលើកុមារ។

[17] International Labour Organisation (ILO) (2012) *Action-oriented research on gender equality and the working and living conditions of garment factor workers in Cambodia.* ILO Regional Office for Asia and the Pacific.
ការស្រាវជ្រាវតាមសកម្មភាពលើសមភាពយេនឌ័រនិងលក្ខខណ្ឌការងារ និងការរស់នៅរបស់កម្មកររោងចក្រកាត់ដេរនៅកម្ពុជា។

[18] Chuemchit, et. al. (2024). *Discrimination and violence against women migrant workers during the COVID 19 pandemic: A mixed methods study.* PLoS.2024 May 3:19(5).
ការរើសអើងនិងអំពើហិង្សាលើពលករចំណាកស្រុកជាស្ត្រីក្នុងប្រទេសថៃ អំឡុងពេលជំងឺរាតត្បាតជំងឺកូវីដ១៩ : ការសិក្សាវិធីសាស្ត្រចម្រុះ។

[19] Seewald, K., Kry, S., & En, M. (2024). Voice and visibility: A participatory exploration of minority women's human rights in Cambodia. Phnom Penh: Women Peace Makers.
សំឡេងនិងការមើលឃើញ : ការស្វែងយល់ដោយការចូលរួមពីសិទ្ធិស្ត្រីជនជាតិភាគតិចនៅកម្ពុជា : អង្គការនារីដើម្បីសន្តិភាពឆ្នាំ២០២៤។

[20] UNFPA (2023). *Harmful Social Norms that drive Gender Based Violence in Cambodia*
និយមសង្គមនិងកេទដែលបង្កគ្រោះថ្នាក់ដែលជំរុញឱ្យមានអំពើហិង្សាផ្អែកលើមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាឆ្នាំ២០២៣។

[21] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh.
ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[22] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh.
ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[23] Ministry of Women's Affairs (2015*) National Study on Women's Health and Life Experiences Cambodia.* Phnom Penh.
ការសិក្សាថ្នាក់ជាតិស្តីពីសុខភាពស្ត្រីនិងបទពិសោធជីវិតកម្ពុជារបស់ក្រសួងកិច្ចការនារី ឆ្នាំ២០១៥។

[24] Plan International, Ministry of Women's Affairs (2024) *The Research Study on Child, Early and Forced Marriages and Unions (CEFMU) in Cambodia.* Phnom Penh
ការសិក្សាស្រាវជ្រាវរបស់ក្រសួងកិច្ចការនារីនិងអង្គការផ្លែនទៅលើការរៀបការនៅវ័យក្មេងនិងការរៀបការនៅវ័យជំទង់ឆ្នាំ២០២៤។

[២៥] ការវាយតម្លៃលើផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

[២៦] សេចក្តីព្រាងរបាយការណ៍ពិនិត្យការឆ្លើយតបរបស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធចំពោះសេចក្តីសង្កេតនិងសន្និដ្ឋាន (COB) របស់ CEDAW។

[២៧] See https://add.org.uk/
គាំទ្រអំណាច និងភ្នាក់ងារនៃចលនាយុត្តិធម៌ពិការ ដោយ ADD Cambodia.

[២៨] ការវាយតម្លៃលើផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ ឆ្នាំ២០១៩-២០២៣។

[២៩] ការវាយតម្លៃលើផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីកត់សម្គាល់សហគ្រាស ក្រុមហ៊ុន រោងចក្រ ចំនួន៥៦។

[៣០] Community policing is an approach to policing that Intended to prevent crime before it happens rather than responding to crime after it occurs, Focuses on creating a safe social environment, engages residents to determine which criminal activities they are most affected by, creating an accurate law enforcement priority list shaped by the people who live in the area and, encourages residents to participate with law enforcement in order to keep their own community safe.
ប៉ូលីសសហគមន៍គឺជាវិធីសាស្ត្រមួយសម្រាប់ប៉ូលីសដែលមានគោលបំណងទប់ស្កាត់ឧក្រិដ្ឋកម្មមុនពេលកើតឡើងជាជាងការឆ្លើយតបនឹងឧក្រិដ្ឋកម្មបន្ទាប់ពីកើតឡើងផ្តោតលើការបង្កើតបរិយាកាសសង្គមប្រកបដោយសុវត្ថិភាពចូលរួមជាមួយប្រជាពលរដ្ឋដើម្បីកំណត់នូវសកម្មភាពឧក្រិដ្ឋកម្មដែលពួកគេរងផលប៉ះពាល់ខ្លាំងជាងគេបង្កើតបញ្ជីអាទិភាពនៃការអនុវត្តច្បាប់ត្រឹមត្រូវដែលបង្កើតដោយប្រជាជនដែលរស់នៅក្នុងតំបន់ និងលើកទឹកចិត្តអ្នកស្រុកឱ្យចូលរួមជាមួយការអនុវត្តច្បាប់ដើម្បីការពារសុវត្ថិភាពរបស់ពួកគេ។

[៣១] UNFPA Cambodia | HARMFUL SOCIAL & GENDER NORMS THAT DRIVE GENDER BASED-VIOLENCE IN CAMBODIA
និយមសង្គមនិងភេទដែលបង្កគ្រោះថ្នាក់ដែលជំរុញឱ្យមានអំពើហិង្សាផ្អែកលើមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

[៣២] RESPECT Women: Preventing violence against women | Publications | UN Women – Asia-Pacific
ក្របខ័ណ្ឌ RESPECT : ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | UN Women

[៣៣] RESPECT Women: Preventing violence against women | Publications | UN Women – Asia-Pacific
ក្របខ័ណ្ឌ RESPECT : ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | UN Women

[៣៤] Primary prevention takes actions to stop violence before it starts. Primary prevention facilitates change by addressing the underlying causes. It focuses on actions to change social norms, practices and structures that produce gender inequality
ការទប់ស្កាត់ជាបឋមចាត់វិធានការដើម្បីបញ្ឈប់អំពើហិង្សាមុនពេលចាប់ផ្តើម។ ការបង្ការបឋមជួយសម្រួលដល់ការផ្លាស់ប្តូរដោយដោះស្រាយមូលហេតុមូលដ្ឋាន។ ផ្តោតលើសកម្មភាពដើម្បីផ្លាស់ប្តូរនិយមសង្គម ការអនុវត្ត និងរចនាសម្ព័ន្ធដែលបង្កើតឱ្យមានវិសមភាពយេនឌ័រ។

[៣៥] OHCHR comments
អនុសាសន៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។

[៣៦] WHO "Female genital mutilation (FGM) comprises all procedures that involve partial or total removal of the external female genitalia, or other injury to the female genital organs for non-medical reasons." Accessed at Female genital mutilation (who.int)

ការកាត់អវយវៈបន្តពូជស្ត្រីសំដៅដល់នីតិវិធីទាំងឡាយណាដែលពាក់ព័ន្ធនឹងការកាត់យកផ្នែកខ្លះ ឬទាំងស្រុង ឬផ្នែកខាងក្រៅណាមួយនៃអវយវៈបន្តពូជរបស់ស្ត្រី ឬការធ្វើឱ្យរងរបួសផ្សេងៗដល់ប្រដាប់បន្តពូជស្ត្រី មិនស្ថិតក្នុងគោលបំណងវេជ្ជសាស្ត្រ។ (អង្គការសុខភាពពិភពលោក (WHO-Female genital mutilation)

[៣៣] National Institute of Statistics (2022) *Cambodia Demographic and Health Survey 2021-22.* Phnom Penh
ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ភ្នំពេញ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២២។

[៣៤] CEDAW General Recommendation 35: D 32B "Ensure that gender-based violence against women is not mandatorily referred to alternative dispute resolution procedures, including mediation and conciliation. The use of those procedures should be strictly regulated and allowed only when a previous evaluation by a specialized team ensures the free and informed consent of victims/survivors and that there are no indicators of further risks to the victims/survivors or their family members. Procedures should empower the victims/survivors and be provided by professionals specially trained to understand and adequately intervene in cases of gender-based violence against women, ensuring adequate protection of the rights of women and children and that interventions are conducted with no stereotyping or revictimization of women. Alternative dispute resolution procedures should not constitute an obstacle to women's access to formal justice."

អនុសាសន៍ទូទៅរបស់ CEDAW 35: D 32B បានបញ្ជាក់ពីការទទួលខុសត្រូវរបស់រដ្ឋហត្ថលេខី ត្រូវប្រកាសដថាអំពើហិង្សាទាក់ទងនឹងយេនឌ័រមិនត្រូវជ្រើសរើសការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមរយៈការសម្របសម្រួលនិងការផ្សះផ្សាមកប្រើប្រាស់នោះឡើយ។ រាល់ការប្រើប្រាស់នីតិវិធីទាំងនេះគម្បីត្រូវមានការកំណត់ឱ្យបានដាក់លាក់ពីលក្ខខណ្ឌដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ និងត្រូវមានការវាយតម្លៃពីក្រុមការងារជំនាញដោយទទួលបានការយល់ព្រមឬអនុញ្ញាតពី ជនរងគ្រោះ ព្រមទាំងធានាថាមិនបង្ករហានិភ័យដល់ជនរងគ្រោះ ឬសមាជិកគ្រួសាររបស់ពួកគេនៅពេលអនាគត។ នីតិវិធីទាំងនេះ ចាំបាច់ត្រូវអនុវត្តដោយផ្តោតលើសិទ្ធិជនរងគ្រោះ និងធានាថាអ្នកអនុវត្តនីតិវិធីទាំងនេះបានទទួលការបណ្តុះបណ្តាល ព្រមទាំងមានចំណេះដឹងពីសិទ្ធិរបស់ស្ត្រីរងគ្រោះ និងកុមារ ពាក់ព័ន្ធនឹងការអន្តរាគមន៍ការសម្របសម្រួលក្នុងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយធានាថាពួកគេមិនរងគ្រោះម្តងទៀត។ នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនគួរត្រូវបានប្រើប្រាស់ជាឧបសគ្គរារាំងក្នុងលទ្ធភាពក្នុងការទទួលបានយុត្តិធម៌របស់ជនរងគ្រោះឡើយ។

[៣៥] សូមមើល RESPECT Women: Preventing violence against women | UN Women – Headquarters
ក្របខ័ណ្ឌ RESPECT : ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | UN Women

[៤០] Ending-Online-Sexual-Exploitation-and-Abuse.pdf

បញ្ឈប់ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធបច្ចេកវិទ្យា។

[៤១] Whatissh.PDF

[៤២] Violence against children
អំពើហិង្សាលើកុមារ។



សូមអរគុណដល់ដៃគូពាក់ព័ន្ធ
ចូលរួមគាំទ្រ ក្នុងការបោះពុម្ព និងផ្សព្វផ្សាយ
ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៤
ឆ្នាំ២០២៥-២០៣០

































ក្រសួងកិច្ចការនារី

ផ្លូវទ្រុងមាន់ កូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល៖ info@mowa.gov.kh
វេបសាយ៖ www.mowa.gov.kh
ហ្វេសប៊ុក៖ www.facebook.com/mowa.gov.kh